ក្រសួងមហាផ្ទៃ

សាលាជាតិរដ្ឋបាលមូលដ្ឋាន

របាយការណ៍ស្រាវជ្រាវ

# ការផ្តួចផ្តើម
# របស់ក្រុមប្រឹក្សានៅ
# រដ្ឋបាលថ្នាក់ក្រោមជាតិ
# ក្នុងការរៀបចំលិខិតបទដ្ឋាន
# និងគោលនយោបាយនៅមូលដ្ឋាន

ឆ្នាំ២០២៥

# អារម្ភកថា

ក្នុងរយៈពេលជាងម្ភៃឆ្នាំកន្លងមកនេះ កម្ពុជាបាននិងកំពុងយកចិត្តទុកដាក់ក្នុងការជំរុញការអនុវត្ត កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដែលជាកំណែទម្រង់មានគោលដៅជាយុទ្ធសាស្ត្រដើម្បីពង្រឹង និងពង្រីកលទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន ព្រមទាំងជំរុញការអភិវឌ្ឍ និងកាត់បន្ថយភាពក្រីក្រនៅមូលដ្ឋានសំដៅលើកកម្ពស់គុណភាពជីវិតរបស់ប្រជាពលរដ្ឋនៅមូលដ្ឋានប្រកបដោយភាពសុខដុម វិបុលភាព និងសមធម៌សង្គម។ កំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការបាននាំមកនូវការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលជាតំណាងប្រជាពលរដ្ឋ ក្នុងការចាត់ចែងកិច្ចការនានានៅមូលដ្ឋាន ដើម្បីសម្រេចគោលបំណងក្នុងការបង្កើត ការជំរុញ និងការធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ព្រមទាំងដើម្បីបំពេញមុខងារ ភារកិច្ចរបស់ក្រុមប្រឹក្សា តាមរយៈការប្រើប្រាស់សិទ្ធិអំណាចខាងបញ្ញត្តិ និងសិទ្ធិអំណាចខាងប្រតិបត្តិប្រកបដោយប្រសិទ្ធភាព ភាពឆ្លើយតប តម្លាភាព គណនេយ្យភាព និងបរិយាបន្ន។

ក្នុងន័យនេះ ក្រុមប្រឹក្សាត្រូវយកចិត្តទុកដាក់រៀបចំ *ដីកា* និង *សេចក្តីសម្រេច* ដែលជាលិខិតបទដ្ឋានគតិយុត្តចាំបាច់របស់ក្រុមប្រឹក្សា ក្នុងការគ្រប់គ្រង ចាត់ចែងកិច្ចការនានានៅមូលដ្ឋាន សំដៅធានាបាននូវបរិយាកាសរស់នៅ ក៏ដូចបរិយាកាសសេដ្ឋកិច្ច-សង្គមប្រកបដោយផាសុកភាព ការលើកទឹកចិត្ត ការយោគយល់និងគោរពគ្នាទៅវិញទៅមក មានអភិបាលកិច្ចល្អនិងសេវាសាធារណៈល្អ មានសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈល្អ ព្រមទាំងប្រកបដោយសមធម៌សង្គម និងបរិយាបន្ន។

ទោះយ៉ាងនេះក្តី យើងសង្កេតឃើញថា ការរៀបចំលិខិតបទដ្ឋានដោយក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីបម្រើផលប្រយោជន៍ និងសេចក្តីត្រូវការជាក់ស្តែងនៅមូលដ្ឋាននីមួយៗរបស់ក្រុមប្រឹក្សាហាក់នៅមានកម្រិតនៅឡើយ។

របាយការណ៍ស្រាវជ្រាវស្តីពី ***ការផ្តួចផ្តើមរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការរៀបចំលិខិតបទដ្ឋាននិងគោលនយោបាយនៅមូលដ្ឋាន*** រៀបចំឡើងក្នុងគោលបំណងកំណត់អំពីកត្តាសំខាន់ៗដែលមានឥទ្ធិពលលើការផ្តួចផ្តើមរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការដាក់ចេញនូវលិខិតបទដ្ឋាន និងគោលនយោបាយនៅមូលដ្ឋាន។ របាយការណ៍ស្រាវជ្រាវបានរកឃើញនូវបញ្ហាចម្បងៗចំនួន៣ ដែលរាំងស្ទះដល់ការផ្តួចផ្តើមរបស់ក្រុមប្រឹក្សាក្នុងការរៀបចំដីកា និងឬលិខិតបទដ្ឋាននានានៅមូលដ្ឋាន ក្នុងនោះរួមមាន កត្តាប្រព័ន្ធនយោបាយ កត្តាថវិកា និងកត្តាសមត្ថភាព។ ជាមួយការរកឃើញទាំងនេះ របាយការណ៍ស្រាវជ្រាវក៏បានលើកអនុសាសន៍គោលនយោបាយមួយចំនួន ដើម្បីជាគន្លឹះដំណោះស្រាយក្នុងការជំរុញការរៀបចំលិខិតបទដ្ឋានគតិយុត្តនៅមូលដ្ឋានដោយក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

ក្នុងនាមថ្នាក់ដឹកនាំនៃសាលាជាតិរដ្ឋបាលមូលដ្ឋាន និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសម្តែងគារវកិច្ចដ៏ខ្ពង់ខ្ពស់និងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុតជូនចំពោះ **ឯកឧត្តមអភិសន្តិបណ្ឌិត ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ព្រមទាំងថ្នាក់ដឹកនាំក្រសួងមហាផ្ទៃគ្រប់លំដាប់ថ្នាក់ ដែលតែងតែ

ផ្ដល់ការដឹកនាំតម្រង់ទិសប្រកបដោយគតិបណ្ឌិត និងផ្ដល់ការគាំទ្រជាបន្តបន្ទាប់ដល់សាលាជាតិរដ្ឋបាលមូលដ្ឋាន ក្នុងការអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់ថ្នាក់ និងអង្គការដៃគូដែលបានផ្ដល់ការសម្របសម្រួល ការគាំទ្រ និងការចូលរួមយ៉ាងសកម្មក្នុងការស្រាវជ្រាវនេះតាំងពីដើមរហូតដល់ចប់។ ជាមួយនេះ ខ្ញុំសូមវាយតម្លៃខ្ពស់ និងកោតសរសើរដោយស្មោះ ចំពោះក្រុមការងារស្រាវជ្រាវនៃនាយកដ្ឋានស្រាវជ្រាវនិងផ្សព្វផ្សាយ នៃសាលាជាតិរដ្ឋបាលមូលដ្ឋាន ដែលបានខិតខំអស់ពីកម្លាំងកាយ ប្រាជ្ញា និងស្មារតីក្នុងការចុះសិក្សាស្រាវជ្រាវរៀបចំរបាយការណ៍នេះ។

ខ្ញុំសង្ឃឹមថា របាយការណ៍ស្រាវជ្រាវនេះ នឹងក្លាយជាធនធានចំណេះដឹងបន្ថែមទៀតសម្រាប់ទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ ក៏ដូចថ្នាក់ដឹកនាំ មន្ត្រីរាជការ អ្នកស្រាវជ្រាវ និងសាធារណជន សំដៅរួមចំណែកកាន់តែសកម្មថែមទៀត ក្នុងការអនុវត្តឱ្យបានជោគជ័យនូវកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាលកម្ពុជា។

របាយការណ៍នេះមិនមានភាពល្អឥតខ្ចោះនោះទេ ហេតុនេះ ក្រុមការងារនឹងរង់ចាំទទួលមតិកែលម្អ និងអនុសាសន៍នានា សំដៅធានាឱ្យការស្រាវជ្រាវខាងមុខកាន់តែល្អប្រសើរ និងឆ្លើយតបថែមទៀត។

**នាយកសាលាជាតិរដ្ឋបាលមូលដ្ឋាន**



**សូ មុនីរក្សា**

រៀបចំដោយក្រុមការងារស្រាវជ្រាវនៃនាយកដ្ឋានស្រាវជ្រាវ និងផ្សព្វផ្សាយ នៃសាលាជាតិរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ដែលមានសមាសភាពដូចខាងក្រោម៖

១. **លោក សុខ សួរ** ប្រធាននាយកដ្ឋានស្រាវជ្រាវ និងផ្សព្វផ្សាយ
២. **លោក ណាំ ទីរីរ៉ូ** ប្រធានការិយាល័យស្រាវជ្រាវ និងអភិវឌ្ឍន៍អភិបាលកិច្ចមូលដ្ឋាន នៃនាយកដ្ឋានស្រាវជ្រាវ និងផ្សព្វផ្សាយ
៣. **លោក ជា វិបុល** អនុប្រធានការិយាល័យស្រាវជ្រាវ និងអភិវឌ្ឍន៍អភិបាលកិច្ចមូលដ្ឋាន នៃនាយកដ្ឋានស្រាវជ្រាវ និងផ្សព្វផ្សាយ
៤. **កញ្ញា អ៊ឹង ហៀកឡាយ** មន្ត្រីការិយាល័យស្រាវជ្រាវ និងអភិវឌ្ឍន៍អភិបាលកិច្ចមូលដ្ឋាន នៃនាយកដ្ឋានស្រាវជ្រាវ និងផ្សព្វផ្សាយ

លទ្ធផលនៅក្នុងរបាយការណ៍ស្រាវជ្រាវនេះ គឺជាលទ្ធផលដែលរកឃើញដោយក្រុមការងារស្រាវជ្រាវតាមរយៈការប្រមូលនិងវិភាគទិន្នន័យពីក្រុមគោលដៅផ្ទាល់នៅមូលដ្ឋាន ពោលគឺមិនបានឆ្លុះបញ្ចាំងពីទស្សនៈរបស់សាលាជាតិរដ្ឋបាលមូលដ្ឋាន និងក្រសួងមហាផ្ទៃឡើយ។

# សេចក្ដីសង្ខេបរបាយការណ៍ស្រាវជ្រាវ

## ១. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះរៀបចំឡើងក្នុងគោលបំណងស្វែងយល់អំពីប្រភេទ និងកត្តាចម្បងៗដែលមានឥទ្ធិពលលើគំនិតផ្ដួចផ្ដើមរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការដាក់ចេញលិខិតបទដ្ឋាន និងគោលនយោបាយនៅមូលដ្ឋាន ជាពិសេសកំណត់នូវកត្តាសំខាន់ៗ ដែលមានឥទ្ធិពលទៅលើការផ្ដួចផ្ដើមរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ លទ្ធផលនៃការស្រាវជ្រាវនេះនឹងក្លាយជាធាតុចូលសម្រាប់ក្រសួង ស្ថាប័នជំនាញ និងអ្នកពាក់ព័ន្ធនានា ក្នុងការគាំទ្រ និងជំរុញក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យរៀបចំ និងដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្ត ឬគោលនយោបាយរបស់ខ្លួន សំដៅឆ្លើយតបទៅនឹងតម្រូវការនៅមូលដ្ឋាន ដែលមានលក្ខណៈដោយឡែកនិងជាក់លាក់ ប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធ។ ជាមួយគ្នានេះ លទ្ធផលនៃការស្រាវជ្រាវនេះអាចនឹងក្លាយជាធាតុចូលសម្រាប់ការរៀបចំកម្មវិធីបណ្ដុះបណ្ដាល និងសកម្មភាពអភិវឌ្ឍន៍សមត្ថភាពនានា ដើម្បីពង្រឹងសមត្ថភាពរបស់មន្ត្រីនៃរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងរៀបចំនិងដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយរបស់ខ្លួនឱ្យកាន់តែមានប្រសិទ្ធភាព។

## ២. វិធីសាស្ត្រស្រាវជ្រាវ

វិធីសាស្ត្រស្រាវជ្រាវបែបគុណវិស័យត្រូវបានប្រើប្រាស់ដើម្បីប្រមូលទិន្នន័យជាក់លាក់ពាក់ព័ន្ធការអនុវត្តជាក់ស្ដែង បទពិសោធន៍ បញ្ហាប្រឈម ឧបសគ្គ និងតម្រូវការជាក់លាក់នានាដែលរដ្ឋបាលថ្នាក់ក្រោមជាតិបាននិងកំពុងជួបប្រទះ សំដៅកំណត់នូវកត្តានានាដែលមានឥទ្ធិពលលើគំនិតផ្ដួចផ្ដើមរបស់ក្រុមប្រឹក្សាក្នុងការរៀបចំនិងដាក់ចេញលិខិតបទដ្ឋាន និងគោលនយោបាយនៅមូលដ្ឋាន។ ដោយផ្អែកលើតំណាងភូមិសាស្ត្រ និងប្រជាសាស្ត្រ ខេត្តចំនួនបួន (ខេត្តតាកែវ ខេត្តកំពង់ចាម ខេត្តបាត់ដំបង និងខេត្តព្រះវិហារ) ក្រុង ស្រុកចំនួន៨ និង ឃុំ/សង្កាត់ចំនួន៨ សរុបចំនួន២០គោលដៅ ត្រូវបានជ្រើសរើសសម្រាប់ការសិក្សាស្រាវជ្រាវនេះ។

សម្រាប់គំរូអ្នកចូលរួមត្រូវបានកំណត់រួមមាន ប្រធានក្រុមប្រឹក្សា ខេត្ត ក្រុង ស្រុក សមាជិកក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ អភិបាល ឬអភិបាលរងខេត្ត ក្រុង ស្រុក ក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក មេឃុំ និងចៅសង្កាត់។ ជារួម ក្នុងការសិក្សាស្រាវជ្រាវនេះ ផ្ដោតសំខាន់ទៅលើក្រុមគោលដៅជាអ្នកអនុវត្តនិងគ្រប់គ្រងផ្ទាល់នៅមូលដ្ឋាន ដែលមានសមាសភាពចូលរួមសរុបចំនួន១០០រូប ដោយត្រូវបានបែងចែកជាចំនួន៤៣ក្រុមគោលដៅសម្រាប់ការសម្ភាសជាបុគ្គល និងជាក្រុម។

ការប្រមូលទិន្នន័យត្រូវបានធ្វើឡើងតាមរយៈការសម្ភាសផ្ទាល់ដោយប្រើប្រាស់បញ្ជីសំណួរគន្លឹះ។ ការចុះប្រមូលទិន្នន័យត្រូវបានធ្វើឡើងរយៈពេល៦សប្ដាហ៍ ដោយចាប់ផ្ដើមពីអំឡុងសប្ដាហ៍ទី២ នៃខែតុលា រហូតដល់សប្ដាហ៍ទី៤ នៃខែវិច្ឆិកា ឆ្នាំ២០២៤។ ការសម្ភាសត្រូវបានធ្វើឡើងដែលមានរយៈពេលចន្លោះពី ៤៥នាទីទៅ៦០នាទី ជាមួយនឹងការកត់ត្រា និងការថតសម្លេងនៃកិច្ចសម្ភាសន៍ ដោយបានស្នើសុំការអនុញ្ញាតជាមុន ហើយអ្នកចូលរួមមានសិទ្ធិស្នើសុំបញ្ឈប់ការសម្ភាសក្នុងករណីដែលអ្នកចូលរួមមិនពេញចិត្តក្នុងការឆ្លើយសំណួរបន្ត។ ទិន្នន័យដែលទទួលបានត្រូវយកទៅវិភាគដោយប្រើប្រាស់ការវិភាគខ្លឹមសារ

ដោយមានការចាប់ក្រុមនៃខ្លឹមសារដែលទទួលបានដើម្បីកំណត់យកបញ្ហាសំខាន់ ក៏ដូចជាទស្សនទាន សម្រាប់យកទៅផ្តល់អនុសាសន៍នានា។

## ៣. លទ្ធផលនៃការស្រាវជ្រាវ

លទ្ធផលនៃការសម្ភាស បានឆ្លុះបញ្ចាំងពីបញ្ហាសំខាន់ៗដែលជះឥទ្ធិពលយ៉ាងខ្លាំងដល់ដំណើរការធ្វើសេចក្តីសម្រេចចិត្ត និងភាពជាអ្នកដឹកនាំនៅក្នុងក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ។ ការរកឃើញទី១ បានបង្ហាញថា កត្តានយោបាយមានឥទ្ធិពលខ្លាំងទៅលើការដឹកនាំនៅមូលដ្ឋាន ជាពិសេសលើការសម្រេចចិត្តនៅមូលដ្ឋាន ដោយសារឥទ្ធិពលនៃកត្តានយោបាយបានគ្របដណ្តប់លើការដឹកនាំ និងសម្រេចចិត្តនៅមូលដ្ឋាន។ ក្នុងនោះ ក្រុមគោលដៅដែលភាគច្រើនជាសមាជិកក្រុមប្រឹក្សាក្រុង ស្រុក បានលើកឡើងថា សិទ្ធិអំណាចក្នុងការដឹកនាំ និងសម្រេចចិត្តត្រូវបានកាត់បន្ថយ ឬរារាំងដោយក្រុម ឬបុគ្គលដែលមានសិទ្ធិអំណាចផ្នែកនយោបាយខ្លាំងនៅមូលដ្ឋាន។ ចំណុចសំខាន់មួយទៀត ដែលទទួលបានពីការសម្ភាស គឺបញ្ហានៃការយល់ដឹងមិនគ្រប់គ្រាន់ទាក់ទងនឹងការអនុវត្តសិទ្ធិអំណាច ដែលច្បាប់បានកំណត់សម្រាប់សមាជិកក្រុមប្រឹក្សា។ ក្រុមគោលដៅដែលភាគច្រើនជាគណៈអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិបានលើកឡើងថា ឥទ្ធិពលនយោបាយមិនមែនជាកត្តាដែលនាំឱ្យមានការកាត់បន្ថយសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាទេ ប៉ុន្តែការមិនយល់ដឹងពីការប្រើប្រាស់សិទ្ធិអំណាចរបស់ខ្លួនក្នុងនាមជាក្រុមប្រឹក្សាទៅវិញទេ ដែលធ្វើឱ្យពួកគាត់មិនអាចប្រាស់សិទ្ធិអំណាចបានពេញលេញ។ ចំណុចនេះបានបង្ហាញឱ្យឃើញពីការយល់ឃើញផ្សេងគ្នារវាងទស្សនៈរបស់ក្រុមប្រឹក្សា និងគណៈអភិបាលទៅលើការដឹកនាំ និងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

ការរកឃើញទី២ បានបង្ហាញថា ក្រុមគោលដៅភាគច្រើនបានយល់ស្របថា ថវិកាដែលទទួលបានពីថ្នាក់ជាតិនៅមានកម្រិតទាប ដែលនាំឱ្យក្រុមប្រឹក្សាមិនមានកញ្ចប់ថវិកាគ្រប់គ្រាន់ និងអាចទាញយកប្រើប្រាស់បានសម្រាប់ធ្វើការរៀបចំ និងដាក់ចេញនូវដីកា ឬគម្រោងធ្វើអ្វីមួយដើម្បីឆ្លើយតបទៅនឹងតម្រូវការប្រជាពលរដ្ឋនៅមូលដ្ឋានបានជាក់ស្តែងឡើយ។ ឆ្លើយតបនឹងបញ្ហានេះ ក្រុមគោលដៅជាសមាជិកក្រុមប្រឹក្សា បានស្នើសុំឱ្យរដ្ឋបាលថ្នាក់ជាតិពិចារណាក្នុងការបែងចែកកញ្ចប់ថវិកាមួយកញ្ចប់ទៀតដាច់ដោយឡែក សម្រាប់តែក្រុមប្រឹក្សាប្រើប្រាស់ក្នុងការផ្តួចផ្តើមរៀបចំ និងដាក់ចេញនូវដីកា និងសកម្មភាពនានា ក្នុងការចុះបេសកកម្មនៅមូលដ្ឋាន ដើម្បីបម្រើដល់សកម្មភាពក្នុងការរៀបចំគោលនយោបាយនៅមូលដ្ឋាន។ ការស្នើសុំនេះ ត្រូវបានលើកឡើងដោយសារមូលហេតុនៃការខ្វះលទ្ធភាពរបស់ក្រុមប្រឹក្សាផ្ទាល់ក្នុងការចាត់ចែងថវិកាប្រចាំឆ្នាំ សម្រាប់ការអនុវត្តមុខងាររបស់ខ្លួន។ ចុងក្រោយ ការទទួលបានចំណូលបន្ថែមនៅមូលដ្ឋានផ្ទាល់ត្រូវបានយល់ស្រប និងគាំទ្រពីក្រុមគោលដៅថា នឹងជួយជំរុញការអភិវឌ្ឍនៅមូលដ្ឋាន និងជំរុញការដាក់ចេញនូវដីកា ឬគោលនយោបាយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិផ្ទាល់តាមរយៈចំណូលដែលទទួលបានបន្ថែមនៅមូលដ្ឋាន។

ការរកឃើញទី៣ បានបង្ហាញថា បញ្ហាកង្វះបទពិសោធន៍នៃការរៀបចំការវិភាគតម្រូវការ និងតាក់តែងដីកាបានរាំងស្ទះដល់ការដាក់ចេញនូវដីកានៅមូលដ្ឋានដែលបញ្ហានេះទទួលស្គាល់ដោយសមាជិកក្រុមប្រឹក្សាផ្ទាល់ទាក់ទងនឹងការយល់ដឹងទៅលើបច្ចេកទេស នៃការរៀបចំការងារទាំងនេះ។ ផ្អែកតាម លទ្ធផលនៃការស្រាវជ្រាវបានបង្ហាញថាសមត្ថភាពរបស់ក្រុមគោលដៅភាគច្រើនជាក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រុង ស្រុក ឃុំ សង្កាត់នៅមានកម្រិត ពាក់ព័ន្ធចំណេះដឹង និងជំនាញក្នុងការផ្តួចផ្តើមរៀបចំ

និងដាក់ចេញនូវដីកា ឬគោលនយោបាយនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ ជាមួយគ្នានេះ សមាជិកក្រុមប្រឹក្សាភាគច្រើនបានលើកឡើងថា ពួកគាត់មិនសូវទទួលបានការបណ្តុះបណ្តាលឡើយនៅក្នុងអាណត្តិការងាររបស់ខ្លួន ដែលជាហេតុធ្វើឱ្យពួកគេមិនសូវបានយល់ដឹងពីការវិវត្តនៃការងារមួយចំនួន ឬនៅតែអនុវត្តតាមសកម្មភាពដដែលៗតាមទម្លាប់។ ដើម្បីដោះស្រាយនូវបញ្ហាទាំងនេះ ក្រុមគោលដៅបានស្នើសុំឱ្យមានការគាំទ្របន្ថែមពីរដ្ឋបាលថ្នាក់ជាតិ និងភាគីពាក់ព័ន្ធ ទៅលើការផ្តល់វគ្គបណ្តុះបណ្តាលជំនាញដល់ក្រុមគោលដៅជាសមាជិកក្រុមប្រឹក្សា ដើម្បីឱ្យក្រុមប្រឹក្សាអាចមានលទ្ធភាពក្នុងការអនុវត្តតួនាទីភារកិច្ចរបស់ខ្លួនកាន់តែមានប្រសិទ្ធភាព។

## ៤. អនុសាសន៍

ឆ្លងតាមការសិក្សាស្រាវជ្រាវនេះ អាចកំណត់នូវអនុសាសន៍គោលនយោបាយមួយចំនួនដូចខាងក្រោម៖

១. ពង្រឹងការអនុវត្តតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សា និងគណៈអភិបាលស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងលិខិតបទដ្ឋានគតិយុត្តមានជាធរមាន។

២. លើកកម្ពស់ភាពជាម្ចាស់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការធ្វើសេចក្តីសម្រេចចិត្ត ពាក់ព័ន្ធការបម្រើសេវាសាធារណៈ និងការអភិវឌ្ឍនៅមូលដ្ឋាន ដោយត្រូវកាត់បន្ថយឥទ្ធិពលពីកត្តាខាងក្រៅនានាទាំងផ្នែកដឹកនាំ និងនយោបាយ។

៣. ជំរុញក្រុមប្រឹក្សា និងបុគ្គលិកនៅរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យពង្រីកគំនិតផ្តួចផ្តើមក្នុងការអនុវត្តមុខងារដែលបានផ្ទេរនៅតាមមូលដ្ឋាន ដោយមិនត្រូវពឹងផ្អែក ឬផ្តោតទាំងស្រុងទៅលើថវិកា ដែលត្រូវបានវិភាជន៍។

៤. លើកកម្ពស់សមត្ថភាពរបស់ក្រុមប្រឹក្សា និងបុគ្គលិកនៅរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធការផ្តួចផ្តើម និងវិភាគរៀបចំគោលនយោបាយ តាមរយៈការបណ្តុះបណ្តាល ការបំពេញការងារ និងការរៀនសូត្រពីបទពិសោធន៍នានាទាំងក្នុងនិងក្រៅប្រទេស។

៥. ផ្តល់លទ្ធភាពបន្ថែមដល់រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យកាន់តែទូលំទូលាយទាំងសមត្ថកិច្ច និងហិរញ្ញវត្ថុ តាមរយៈការផ្ទេរមុខងារជាក់លាក់កាន់តែច្រើន និងការផ្ទេរធនធានហិរញ្ញវត្ថុសមស្របដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។

៦. រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវផ្លាស់ប្តូរឥរិយាបថក្នុងការបំពេញតួនាទី ភារកិច្ចរបស់ខ្លួនដោយពុំត្រូវរង់ចាំការណែនាំលម្អិត ការចង្អុលបង្ហាញបន្ថែមពីថ្នាក់ជាតិ និងឬការរង់ចាំរហូតដល់មានធនធានគ្រប់គ្រាន់។

# មាតិកា


អារម្ភកថា ........ i
សេចក្ដីសង្ខេបរបាយការណ៍ស្រាវជ្រាវ ........ iv
មូលន័យសង្ខេប ........ ១
១. សេចក្ដីផ្ដើម ........ ១
១.១ សាវតារ ........ ១
១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ៣
១.៣ គោលបំណងនៃការស្រាវជ្រាវ ........ ៣
១.៤ សារៈសំខាន់នៃការស្រាវជ្រាវ ........ ៣
១.៥ និយមន័យនៃពាក្យគន្លឹះ និងវិសាលភាពនៃការស្រាវជ្រាវ ........ ៤
២. ការរំលឹកទ្រឹស្ដី ........ ៤
២.១ ការគ្រប់គ្រងតាមបែបវិមជ្ឈការនៅមូលដ្ឋាន ........ ៤
២.២ វិមជ្ឈការហិរញ្ញវត្ថុ ........ ៦
២.៣ ការផ្ទេរមុខងារ ........ ៨
២.៤ ការរៀបចំលិខិតបទដ្ឋាន និងគោលនយោបាយនៅមូលដ្ឋាន ........ ១០
២.៥ ការសន្មត(Propositions) ........ ១១
២.៦ ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ........ ១៣
៣. វិធីសាស្ត្រស្រាវជ្រាវ ........ ១៣
៣.១ ប្រភេទនៃការស្រាវជ្រាវ ........ ១៣
៣.២ ការជ្រើសរើសសំណាក ........ ១៣
៣.៣ វិធីសាស្ត្រប្រមូលទិន្នន័យ ........ ១៤
៣.៤ វិធីសាស្ត្រវិភាគទិន្នន័យ ........ ១៤
៤. លទ្ធផល និងការពិភាក្សា ........ ១៥
៥. សេចក្ដីសន្និដ្ឋាន និងអនុសាសន៍ ........ ២៩
៥.១ សេចក្ដីសន្និដ្ឋាន ........ ២៩
៥.២ អនុសាសន៍ ........ ៣០
៥.៣ ការស្រាវជ្រាវនាពេលអនាគត ........ ៣០
គន្ថនិទ្ទេស ........ ៣១
ឧបសម្ព័ន្ធ ........ ៣៥

# របាយការណ៍ស្រាវជ្រាវ ស្តីពី
# ការផ្តួចផ្តើមរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការរៀបចំលិខិតបទដ្ឋាន និងគោលនយោបាយនៅមូលដ្ឋាន


## មូលន័យសង្ខេប

ប្រទេសកម្ពុជាបានចាប់ផ្តើមអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការតាំងពីឆ្នាំ២០០២ ក្នុងគោលបំណងពង្រឹងនិងពង្រីកការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅមូលដ្ឋាន។ ផ្ទុះបញ្ចាំងពីកំណែទម្រង់នេះ ការអនុវត្តការងាររបស់ក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិ ពាក់ព័ន្ធនឹងការដាក់ចេញដីកានិងគោលនយោបាយនានានៅមូលដ្ឋាននៅតែជាបញ្ហាប្រឈម និងមិនទាន់មានការសិក្សាច្បាស់លាស់នៅឡើយ។ ការសិក្សាស្រាវជ្រាវនេះមានគោលបំណងស្វែងយល់អំពីប្រភព និងកត្តាដែលមានឥទ្ធិពលលើការផ្តួចផ្តើមរបស់ក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការដាក់ចេញលិខិតបទដ្ឋាន និងគោលនយោបាយនៅមូលដ្ឋាន។ ការសិក្សាស្រាវជ្រាវនេះប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវបែបគុណវិស័យតាមរយៈការចុះសម្ភាសប្រមូលទិន្នន័យផ្ទាល់នៅតាមរដ្ឋបាលគោលដៅដើម្បីធ្វើការប្រមូលព័ត៌មានសម្រាប់យកទៅវិភាគខ្លឹមសារសម្រាប់បង្ហាញលទ្ធផល។ ជាលទ្ធផល កត្តាប្រឈមសំខាន់ៗចំនួនបីត្រូវបានរកឃើញ។ កត្តាប្រឈមទី១ គឺឥទ្ធិពលនៃប្រព័ន្ធនយោបាយ និងការកង្វះសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាក្នុងការគ្រប់គ្រង និងចាត់ចែងការងារ។ កត្តាប្រឈមទី២ គឺការវិភាជន៍ថវិកាមិនគ្រប់គ្រាន់ពីថ្នាក់ជាតិ និងកត្តាគ្មានចំណូលផ្ទាល់នៅមូលដ្ឋាន។ កត្តាប្រឈមទី៣ គឺកត្តាសមត្ថភាពនៅមានកម្រិតរបស់សមាជិកក្រុមប្រឹក្សា និងខ្វះការគាំទ្រការអភិវឌ្ឍសមត្ថភាពពីរដ្ឋបាលថ្នាក់ជាតិ និងភាគីពាក់ព័ន្ធ។



***ពាក្យគន្លឹះ:*** *រដ្ឋបាលថ្នាក់ក្រោមជាតិ ដីកា គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ ព្រះរាជាណាចក្រកម្ពុជា។*


## ១. សេចក្តីផ្តើម

### ១.១ សាវតារ

កម្ពុជាបានចាប់ផ្តើមអនុវត្តគោលនយោបាយកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការនៅក្នុងឆ្នាំ២០០២ នៅថ្នាក់ឃុំ សង្កាត់ ដែលជារដ្ឋបាលថ្នាក់ក្រោមបំផុតនៅក្នុងប្រព័ន្ធរដ្ឋបាលរបស់ខ្លួន ក្នុងគោលបំណងពង្រឹងពង្រីកការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងដើម្បីផ្តល់នូវសេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានកាន់តែល្អប្រសើរ និងបានពង្រីកការអនុវត្តគោលនយោបាយកំណែទម្រង់នេះនៅរដ្ឋបាលថ្នាក់ខ្ពស់បន្ទាប់ ដែលរួមមានរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នៅឆ្នាំ២០០៩។ យោងតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ក្នុងឆ្នាំ២០០១ និង ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ២០០៨ និងលិខិតបទដ្ឋានពាក់ព័ន្ធ កំណែទម្រង់

វិមជ្ឈការ និងវិសហមជ្ឈការ ផ្តោតសំខាន់លើការធ្វើកំណែទម្រង់ផ្នែកនយោបាយ និងផ្នែករដ្ឋបាលតាមរយៈការរៀបចំឱ្យមានក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់ថ្នាក់ដើម្បីតំណាងឱ្យប្រជាពលរដ្ឋនៅមូលដ្ឋានតាមរយៈការបោះឆ្នោតដោយផ្ទាល់ និងមិនផ្ទាល់ និងការផ្ទេរសិទ្ធិ អំណាចនិងមុខងារជាបន្តបន្ទាប់ដល់ក្រុមប្រឹក្សាទាំងនោះ។ តាមរយៈការធ្វើកំណែទម្រង់ផ្នែកសារពើពន្ធ ធនធានហិរញ្ញវត្ថុត្រូវបានផ្ទេរពីថ្នាក់ជាតិជាបន្តបន្ទាប់ទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ជាមួយការផ្តល់សិទ្ធិអំណាចក្នុងការទទួលចំណូលនៅមូលដ្ឋាន។ តាមរយៈការធ្វើកំណែទម្រង់ផ្នែករដ្ឋបាល មុខងារនិងសិទ្ធិអំណាចត្រូវបានផ្ទេរទៅឱ្យក្រុមប្រឹក្សាក្នុងការរៀបចំនិងគ្រប់គ្រងបុគ្គលិករបស់ខ្លួនក្នុងការអនុវត្តមុខងារប្រកបដោយប្រសិទ្ធភាព សំដៅពង្រឹង និងពង្រីកលទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន ជំរុញកិច្ចអភិវឌ្ឍន៍មូលដ្ឋាន និងការកៀរគរធនធាននៅមូលដ្ឋានសំដៅកាត់បន្ថយភាពក្រីក្រ។

ចក្ខុវិស័យរបស់រាជរដ្ឋាភិបាលសម្រាប់កំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិក្នុងរយៈពេល១០ឆ្នាំខាងមុខ (ឆ្នាំ២០២១ ដល់ឆ្នាំ២០៣០) គឺ "ប្រជាពលរដ្ឋទទួលបានសេវាសាធារណៈ និងផលប្រយោជន៍ពីការអភិវឌ្ឍមូលដ្ឋានដែលផ្តល់ដោយរដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយបរិយាបន្ន និងសមធម៌សង្គម ដែលរួមចំណែកសម្រេចឱ្យបាននូវគោលបំណងដ៏ទូលំទូលាយក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមជាតិ និងប្រែក្លាយប្រទេសកម្ពុជាឱ្យទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០"។ ស្របតាមគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវគ្រប់គ្រងតាមគោលការណ៍នៃរដ្ឋបាលឯកភាព ដែលក្រុមប្រឹក្សាត្រូវមានម្ចាស់ការក្នុងការគ្រប់គ្រង ចាត់ចែងមុខងារ និងធនធាន ព្រមទាំងមានសមត្ថភាពសមស្របក្នុងការសម្របសម្រួលនូវសកម្មភាពនៃការផ្តល់សេវានិងការអភិវឌ្ឍដែលមាននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងដែលត្រូវបានធ្វើឡើងដោយក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល សំដៅឆ្លើយតបសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។ ការបង្កើតរដ្ឋបាលឯកភាពនៅរដ្ឋបាលថ្នាក់ក្រោមជាតិ គឺដើម្បីពង្រឹងអង្គឯកភាពរបស់រដ្ឋក្នុងការសម្របសម្រួលប្រកបដោយប្រសិទ្ធភាពនូវរាល់សកម្មភាពរដ្ឋបាលសាធារណៈនៅក្នុងដែនដីរបស់ខ្លួន។

ក្នុងការអនុវត្តកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការក្នុងរយៈពេលជាង២០ឆ្នាំនៅថ្នាក់ឃុំ សង្កាត់ និងប្រមាណ១៥ឆ្នាំ នៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ កម្ពុជាសម្រេចបាននូវសមិទ្ធផលសំខាន់ៗ ដែលក្នុងនោះមានការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិទៅតាមកាលកំណត់ ការកែសម្រួលរចនាសម្ព័ន្ធនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ការផ្ទេរមុខងារ ធនធានហិរញ្ញវត្ថុនិងទ្រព្យសម្បត្តិ បុគ្គលិក និងសិទ្ធិអំណាចនិងភាពជាម្ចាស់ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិកាន់តែច្រើនដើម្បីអនុវត្ត គ្រប់គ្រង និងចាត់ចែងមុខងារ ធនធាន និងសិទ្ធិអំណាចទាំងនោះ ដើម្បីអាចឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនៅមូលដ្ឋានកាន់តែល្អប្រសើរជាងមុន។ សមិទ្ធផលទាំងនេះបានចូលរួមចំណែកក្នុងការលើកកម្ពស់ជីវភាព សុខុមាលភាព និងគុណភាពជីវិតរបស់ប្រជាពលរដ្ឋត្រូវបានកែលម្អកាន់តែល្អប្រសើរ ព្រមទាំងចូលរួមសម្រេចឱ្យបាននូវចក្ខុវិស័យរបស់កម្ពុជាក្នុងការប្រែក្លាយខ្លួនជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

ខណៈដែលសមិទ្ធផលសំខាន់ត្រូវបានសម្រេចបានជាបន្តបន្ទាប់តាមរយៈកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ នៅមានបញ្ហាប្រឈមមួយចំនួនដែលអាចនាំឱ្យក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិមិនអាចបំពេញតួនាទី ភារកិច្ចរបស់ខ្លួនបានពេញលេញ យោងតាមច្បាប់និងលិខិតបទដ្ឋានជាធរមាន។ បញ្ហាទាំងនោះរួមមានភាពមិនទាន់ស៊ីសង្វាក់គ្នាក្នុងការបំពេញតួនាទី ភារកិច្ច និងខ្សែគណនេយ្យភាពរវាងក្រុមប្រឹក្សានិងគណៈអភិបាល ការផ្ទេរបុគ្គលិក ធនធានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ ពុំទាន់មានលក្ខណៈសមស្របតាមចំនួននិងទំហំមុខងារដែលបានផ្ទេរ និងសមត្ថភាពរបស់ថ្នាក់ដឹកនាំនិងមន្ត្រីនៅមានកម្រិតបើធៀបនឹងទំហំ និងភាពស្មុគស្មាញនៃការងារ (គ.ជ.អ.ប, ២០២៣)។

មួយវិញទៀត ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ (២០០១) និងច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (២០០៨) បានកំណត់ឱ្យក្រុមប្រឹក្សាមានសិទ្ធិអំណាចខាងបញ្ញត្តិ និងខាងប្រតិបត្តិ តាមរយៈការធ្វើសេចក្ដីសម្រេចក្នុងកិច្ចប្រជុំក្រុមប្រឹក្សា។ ក្រុមប្រឹក្សាតាមរយៈកិច្ចប្រជុំរបស់ខ្លួន អាចដឹកនាំផ្តួចផ្តើមក្នុងការដាក់ចេញនូវសេចក្តីសម្រេចក្រោមទម្រង់ជាលិខិតបទដ្ឋាន ជាពិសេស ដីកា ដើម្បីឆ្លើយតបទៅនឹងសេចក្ដីត្រូវការ ជាក់ស្តែងនៅមូលដ្ឋាន ពាក់ព័ន្ធការថែរក្សាសន្តិសុខសណ្តាប់ធ្នាប់ ការការពារផលប្រយោជន៍ប្រជាពលរដ្ឋ ការលើកកម្ពស់ការបម្រើសេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន ជាដើម។ បច្ចុប្បន្ន ទោះបីជាច្បាប់បានផ្ដល់សិទ្ធិដល់ក្រុមប្រឹក្សាក្នុងការរៀបចំដាក់ចេញដីកា ដើម្បីបម្រើផលប្រយោជន៍ប្រជាពលរដ្ឋនៅមូលដ្ឋានយ៉ាងណាក្តី មានក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងចំនួនតិចតួចប៉ុណ្ណោះ ដែលបានរៀបចំដាក់ចេញដីកានៅមូលដ្ឋានតាមការផ្តួចផ្តើមរបស់ខ្លួន ដែលតម្រូវឱ្យមានការសិក្សាមួយដើម្បីស្វែងរកនៅបញ្ហាប្រឈមសំដៅលើកអនុសាសន៍។

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះមានគោលបំណងស្វែងយល់អំពីបញ្ហាប្រឈមរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការដាក់ចេញលិខិតបទដ្ឋាននិងគោលនយោបាយនៅមូលដ្ឋាន សំដៅលើកអនុសាសន៍ជំរុញការរៀបចំគោលនយោបាយ ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការជាក់ស្តែងនៅមូលដ្ឋាន។ ដើម្បីសម្រេចនូវគោលបំណងខាងលើ ការស្រាវជ្រាវនេះបានកំណត់ " តើកត្តាអ្វីខ្លះដែលមានឥទ្ធិពលទៅលើការរៀបចំគោលនយោបាយរបស់ក្រុមប្រឹក្សានៅមូលដ្ឋាន ?" ជាសំណួរស្រាវជ្រាវ។

## ១.៤ សារៈសំខាន់នៃការស្រាវជ្រាវ

លទ្ធផលនៃការស្រាវជ្រាវនេះ នឹងផ្ដល់ជាអនុសាសន៍ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការជំរុញនិងបង្កើនលទ្ធភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសក្រុមប្រឹក្សារបស់ខ្លួនក្នុងការរៀបចំនិងដាក់ចេញនូវលិខិតបទដ្ឋាន និងគោលនយោបាយនានា សំដៅលើកកម្ពស់ប្រសិទ្ធភាពនិងភាពស័ក្តិសិទ្ធនៃការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន។

លទ្ធផលនៃការស្រាវជ្រាវនេះ ក៏នឹងក្លាយជាធាតុចូលសម្រាប់ក្រសួង ស្ថាប័នជំនាញ និងអ្នកពាក់ព័ន្ធនានា ក្នុងការគាំទ្រនិងជំរុញក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យរៀបចំនិងដាក់ចេញនូវលិខិតបទដ្ឋាន និង

គោលនយោបាយរបស់ខ្លួន សំដៅឆ្លើយតបទៅនឹងតម្រូវការនៅមូលដ្ឋានដែលមានលក្ខណៈដោយឡែកនិងជាក់លាក់ប្រកបដោយប្រសិទ្ធភាព ភាពស័ក្តិសិទ្ធ ភាពឆ្លើយតប និងបរិយាបន្ន។

មួយវិញទៀត លទ្ធផលនៃការស្រាវជ្រាវនេះ នឹងអាចត្រូវប្រើប្រាស់ជាធាតុចូលក្នុងការរៀបចំកម្មវិធីបណ្តុះបណ្តាល និងសកម្មភាពអភិវឌ្ឍន៍សមត្ថភាពនានា ដើម្បីពង្រឹងសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងរៀបចំនិងដាក់ចេញនូវលិខិតបទដ្ឋាន និងគោលនយោបាយរបស់ខ្លួនឱ្យកាន់តែមានប្រសិទ្ធភាព។

### ១.៥ និយមន័យនៃពាក្យគន្លឹះ និងវិសាលភាពនៃការស្រាវជ្រាវ

រដ្ឋបាលថ្នាក់ក្រោមជាតិសំដៅទៅលើរដ្ឋបាលរាជធានី រដ្ឋបាលខេត្ត រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលខណ្ឌ និងរដ្ឋបាលឃុំ រដ្ឋបាលសង្កាត់។ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានចែកចេញជាពីរ គឺរដ្ឋបាលតំបន់ និងរដ្ឋបាលមូលដ្ឋាន ដែលរដ្ឋបាលតំបន់សំដៅទៅលើរដ្ឋបាលខេត្ត ចំណែករដ្ឋបាលមូលដ្ឋានសំដៅដល់រដ្ឋបាលរាជធានី រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលខណ្ឌ និងរដ្ឋបាលឃុំ រដ្ឋបាលសង្កាត់។

លិខិតបទដ្ឋានគតិយុត្ត គឺសំដៅដល់លិខិតទាំងឡាយដែលកំណត់នូវវិធាន បទប្បញ្ញត្តិ បទបញ្ជា ឬគោលការណ៍នានាសម្រាប់ការគ្រប់គ្រង ការតែងតាំង ការបង្កើតឡើងនូវយន្តការ និងការណែនាំអនុវត្តន៍កិច្ចការនានា។

វិមជ្ឈការ មានន័យថា ជាការប្រគល់នូវភាពជាម្ចាស់លើមុខងារ សិទ្ធិអំណាច ការទទួលខុសត្រូវ និងធនធាន (ហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងបុគ្គលិក) ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលតំណាងដោយក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋនៅថ្នាក់មូលដ្ឋាន។

វិសហមជ្ឈការ សំដៅដល់ការធ្វើប្រតិភូកម្ម មុខងារសិទ្ធិអំណាច និងធនធាន (ហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងបុគ្គលិក) ទៅអង្គភាពក្រោមបង្គាប់ ឬទៅក្រុមប្រឹក្សាប្រភេទណាមួយ ដើម្បីអនុវត្តមុខងារនោះក្នុងនាមរាជរដ្ឋាភិបាល ក្រសួង ឬស្ថាប័ន។

ការស្រាវជ្រាវនេះ មានវិសាលភាពគ្រប់ដណ្តប់ទៅលើក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិនៅទូទាំងប្រទេសកម្ពុជា។

## ២. ការរំលឹកទ្រឹស្តី

### ២.១ ការគ្រប់គ្រងតាមបែបវិមជ្ឈការនៅមូលដ្ឋាន

យោងតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ (២០០១) និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (២០០៨) រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់នីមួយៗ ត្រូវមានក្រុមប្រឹក្សារបស់ខ្លួន។ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវជ្រើសរើសឡើងតាមការបោះឆ្នោត**ជាសកល**ដោយប្រជាពលរដ្ឋនៃឃុំ សង្កាត់របស់ខ្លួន អនុលោមតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ **ចំណែក**ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុងក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌត្រូវបានជ្រើសរើសឡើងតាមការបោះឆ្នោតអសកល ស្របតាមបទបញ្ញត្តិនៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើស

ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ។ ក្រុមប្រឹក្សានីមួយៗ ត្រូវធ្វើជាតំណាង និងធ្វើសកម្មភាពក្នុងនាមប្រជាពលរដ្ឋទាំងអស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ម៉្យាងវិញទៀត ក្រុមប្រឹក្សាត្រូវមានការទទួលខុសត្រូវចំពោះក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលក្នុងនាមជាអ្នកតំណាងក្នុងការអនុវត្តមុខងារដែលត្រូវបានធ្វើប្រតិភូកម្មពីក្រសួង ស្ថាប័នទាំងនោះ។

ប្រព័ន្ធវិមជ្ឈការត្រូវបានឱ្យនិយមន័យថា គឺជាប្រព័ន្ធមួយដែលរដ្ឋបាលកណ្តាលទទួលស្គាល់នូវសិទ្ធិអំណាចក្នុងការសម្រេចចិត្តរបស់រដ្ឋបាលមូលដ្ឋាន ដោយមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ និង ច្បាប់នានា។ វិមជ្ឈការជាប្រព័ន្ធរដ្ឋបាលមួយដែលអនុញ្ញាតឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិធ្វើការគ្រប់គ្រងដោយខ្លួនឯង ដោយត្រូវគោរពគោលការណ៍ និងនីត្យានុកូលភាព។ ក្នុងន័យម្យ៉ាងទៀត វិមជ្ឈការមានន័យថា រាជរដ្ឋាភិបាលបានប្រគល់នូវភាពជាម្ចាស់ លើមុខងារ សិទ្ធិអំណាច ការទទួលខុសត្រូវ និងធនធាន (ហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងបុគ្គលិក) ឱ្យទៅក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិ ដូចជាក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់មូលដ្ឋាន។ Fox & Aranda (១៩៩៦) បានឱ្យនិយមន័យប្រព័ន្ធនយោបាយវិមជ្ឈការ ដោយសង្កត់ធ្ងន់លើតួនាទីរបស់តួអង្គនយោបាយនានាក្នុងមូលដ្ឋាន ពាក់ព័ន្ធនឹងការកំណត់បញ្ហា ដែលដំណើរការដោយភាពឯករាជ្យពីប្រព័ន្ធនយោបាយគ្រប់គ្រងនៅថ្នាក់ជាតិ។ ភាពឯករាជ្យនៃប្រព័ន្ធនយោបាយនៅមូលដ្ឋាន នឹងជួយសម្រួលដល់ការកំណត់ទិសដៅនៃដំណើរការដាក់ចេញគោលនយោបាយ និងជំរុញការអភិវឌ្ឍភាពជាតំណាងនៅតាមកម្រិតក្នុងមូលដ្ឋាន។ ជាទូទៅ គោលគំនិតនៃការធ្វើវិមជ្ឈការនយោបាយត្រូវបានពិនិត្យតាមរយៈការឆ្លុះបញ្ចាំងជាលក្ខណៈនយោបាយ ដោយផ្តោតជាចម្បងលើការប្រមូល ការរៀបចំ ការច្នៃប្រឌិត ការចូលរួម ការប្រកួតប្រជែង និងការគិតគូរពីផលប្រយោជន៍របស់ប្រជាពលរដ្ឋ។ ដំណើរការទាំងអស់នេះ គឺជាមូលដ្ឋានគ្រឹះនៃប្រព័ន្ធនយោបាយទាំងអស់ ហើយមានការប្រែប្រួលខ្លាំងឬខ្សោយអាស្រ័យទៅលើកត្តាប្រឈម និងបរិបទផ្សេងៗ។ ក្នុងនោះផងដែរ Abdullah (២០១៩) បានបញ្ជាក់បន្ថែមថា ការផ្លាស់ប្តូររបត់នយោបាយ និងការងាររដ្ឋបាលនៅមូលដ្ឋាន រួមជាមួយនឹងផ្នត់គំនិតសាធារណៈ មានឥទ្ធិពលយ៉ាងខ្លាំងដល់ការអនុវត្តការងាររបស់ក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ ចំណុចនេះ ស្របទៅនឹងការលើកឡើងរបស់ Lameck (២០២២) ដែលបានអះអាងថា ប្រព័ន្ធអភិបាលកិច្ចមូលដ្ឋាននឹងជួបប្រទះភាពប្រឈមគ្នារវាងអ្នកនយោបាយ និងមន្ត្រីអនុវត្តការងារនៅមូលដ្ឋាន ប្រសិនបើការរៀបចំមុខងារ តួនាទី ភារកិច្ចមានភាពត្រួតគ្នា ការមិនទុកចិត្តគ្នា ព្រមទាំងឥទ្ធិពលនៃការណែនាំ និងចាត់តាំងពីរដ្ឋបាលថ្នាក់ជាតិខ្លាំងពេកទៅលើរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្នុងន័យនេះ ឥទ្ធិពលគោល-នយោបាយរបស់រដ្ឋបាលថ្នាក់ជាតិនឹងរំខានដល់ការរៀបចំ និងការអនុវត្តផែនការរបស់រដ្ឋបាលមូលដ្ឋាន ដោយសារការពឹងផ្អែកខ្លាំងពេករបស់រដ្ឋបាលមូលដ្ឋាន ទៅលើគោលនយោបាយពីថ្នាក់ជាតិ និងមិនបានផ្តួចផ្តើមគិតគូរបន្ថែមពីគោលនយោបាយរបស់ខ្លួននៅមូលដ្ឋាន ដែលរារាំងការឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងមួយចំនួនរបស់សហគមន៍នៅមូលដ្ឋាន។

ផ្អែកតាមនិយមន័យ និងការអះអាងខាងលើ ការសន្និដ្ឋានអាចទាញចេញមកបានថា ការគ្រប់គ្រងតាមបែបវិមជ្ឈការមិនមែនត្រឹមតែជាការបែងចែក ឬប្រគល់សិទ្ធិអំណាចតែមួយមុខនោះទេ ប៉ុន្តែភាពឯករាជ្យ

ក៏ជាកត្តាចាំបាច់សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការធ្វើការសម្រេចចិត្ត។ ការខ្វះភាពឯករាជ្យនៅមូលដ្ឋាន នឹងជះឥទ្ធិពលដល់អភិបាលកិច្ច និងការអភិវឌ្ឍនៅមូលដ្ឋាន ដោយមូលហេតុថា ប្រសិនបើការសម្រេចចិត្ត នៅថ្នាក់ជាតិពាក់ព័ន្ធការរៀបចំប្រព័ន្ធគ្រប់គ្រង និងប្រព័ន្ធនយោបាយមានឥទ្ធិពលខ្លាំងលើការគ្រប់គ្រង ដឹកនាំនៅរដ្ឋបាលថ្នាក់ក្រោមជាតិ នឹងរាំងដល់ដំណើរការវិមជ្ឈការនៅមូលដ្ឋាន។ ជាមួយគ្នានេះ ផ្សារភ្ជាប់ ជាមួយការសន្និដ្ឋានដែលបានលើកឡើង យើងអាចក្រលេកទៅមើលការអះអាងរបស់ Schneider (២០០៣) ដែលបានលើកឡើងថា ប្រសិនបើក្រុមប្រឹក្សានៅរដ្ឋបាលមូលដ្ឋានមានតួនាទីជាអ្នកអនុវត្ត គោលនយោបាយរបស់រដ្ឋាភិបាលថ្នាក់ជាតិ ជាជាងមានតួនាទីជាស្ថាប័នសម្រេចចិត្តដែលមាន ស្វ័យភាពនៅមូលដ្ឋាន ក្រុមប្រឹក្សាទាំងនោះនឹងមិនមានសមត្ថភាពក្នុងការបំពេញតួនាទីជាតំណាងពិត ប្រាកដរបស់ប្រជាជនរបស់ខ្លួននៅមូលដ្ឋានឡើយ។ បើទោះបីជាកំណែទម្រង់វិមជ្ឈការផ្តោតទៅលើការពង្រឹង ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅរដ្ឋបាលថ្នាក់ក្រោមជាតិតាមរយៈការបង្កើតឱ្យមានក្រុមប្រឹក្សា ប៉ុន្តែការបោះឆ្នោតនៅរដ្ឋបាលថ្នាក់ក្រោមជាតិ នៅតែទទួលឥទ្ធិពលនៃការរៀបចំ និងចាត់តាំងពីគណបក្ស នយោបាយនៅរដ្ឋបាលថ្នាក់ជាតិ។

ដូចគ្នានេះ Hulst et al. (២០១៥) ក៏បានបានលើកឡើងស្របនឹងការលើកឡើងខាងលើដែលថា នៅពេលដែលអ្នកដឹកនាំគណបក្សនយោបាយនៅថ្នាក់ជាតិ នៅតែមាន ឥទ្ធិពលក្នុងការតែងតាំង ឬចាត់តាំង បេក្ខភាពថ្នាក់ដឹកនាំនៅមូលដ្ឋាន នោះនឹងបង្កើតនូវប្រព័ន្ធដឹកនាំមួយដែលរដ្ឋបាលថ្នាក់ក្រោមជាតិ នៅតែអនុវត្តទៅតាមការណែនាំ ឬបម្រើប្រយោជន៍ដល់គោលនយោបាយថ្នាក់ជាតិ ជាជាងផ្តោតលើ តម្រូវការចាំបាច់ជាក់ស្តែងនៅមូលដ្ឋាន។ ការបន្តមានឥទ្ធិពលបែបនេះ នឹងកាត់បន្ថយសិទ្ធិអំណាច និង ភាពស្របច្បាប់ ស្របតាមលទ្ធិប្រជាធិបតេយ្យរបស់ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ ក៏ដូចជារាំងសមត្ថភាព របស់ក្រុមប្រឹក្សាក្នុងភាពជាអ្នកតំណាងរបស់ប្រជាជននៅមូលដ្ឋានប្រកបដោយប្រសិទ្ធភាព។

ជារួម ការបន្តឱ្យមានឥទ្ធិពលនយោបាយ និងការដឹកនាំ គ្រប់គ្រងពីរដ្ឋបាលថ្នាក់ជាតិទៅលើរដ្ឋបាល ថ្នាក់ក្រោមជាតិនឹងបណ្តាលឱ្យមានកំណែទម្រង់វិមជ្ឈការមិនពេញលេញមួយ ដែលប៉ះពាល់ដល់ គោលការណ៍នៃការអភិវឌ្ឍតាមបែបលទ្ធិប្រជាធិបតេយ្យនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយបានកាត់បន្ថយ សិទ្ធិអំណាចនៃអាជ្ញាធរមូលដ្ឋានក្នុងការសម្រេចចិត្តដោយឯករាជ្យ និងរាំងដល់ការអភិវឌ្ឍនៅមូលដ្ឋាន ដោយសារគោលនយោបាយពីថ្នាក់ជាតិ មួយចំនួនមិនបានឆ្លើយតបទៅនឹងបញ្ហា និងតម្រូវការជាក់ស្តែង របស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

## ២.២ វិមជ្ឈការហិរញ្ញវត្ថុ

យោងតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ (២០០១) រដ្ឋបាលឃុំ សង្កាត់ មានធនធាន ហិរញ្ញវត្ថុ ថវិកា និងទ្រព្យសម្បត្តិផ្ទាល់។ រដ្ឋបាលឃុំ សង្កាត់ មានសិទ្ធិទទួលចំណូលផ្ទាល់ដែលបានមកពី ចំណូលសារពើពន្ធ ចំណូលមិនមែនសារពើពន្ធ និងកម្រៃសេវាផ្សេងៗ ដោយពន្ធទាំងនេះរាប់បញ្ចូលនូវពន្ធ លើដីធ្លី ពន្ធលើអចលនទ្រព្យ និងពន្ធនៃការជួល។ យ៉ាងណាមិញ បច្ចុប្បន្ននេះ ឃុំ សង្កាត់មិនអាចអនុវត្ត ការប្រមូលចំណូលផ្ទាល់នេះបានឡើយ ដោយហេតុថាមិនទាន់មានច្បាប់ស្តីពីការប្រមូលចំណូលនេះ។ ស្រដៀងគ្នានឹង រដ្ឋបាលឃុំ សង្កាត់ដែរ យោងតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក

ខណ្ឌ (២០០៨) រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក មានសិទ្ធិទទួលបានចំណូលពីប្រភពនៅមូលដ្ឋាន ពីប្រភពនៅថ្នាក់ជាតិ និងពីប្រភពផ្សេងៗទៀត ដោយអនុលោមទៅតាមច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលរៀបចំឡើងស្របតាមច្បាប់នេះ និងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។ បច្ចុប្បន្ន ចំណូលដ៏សំខាន់របស់រដ្ឋបាលឃុំ សង្កាត់ គឺទទួលបានមកពីការផ្ទេរពីថវិកាពីថ្នាក់ជាតិហៅថាមូលនិធិឃុំ សង្កាត់។ មូលនិធិឃុំ សង្កាត់ ត្រូវបានកំណត់ជាភាគរយនៃចំណូលចរន្តថវិការដ្ឋតាមរយៈអនុក្រឹត្យរបស់រាជរដ្ឋាភិបាល។ ដូចគ្នានឹងរដ្ឋបាលឃុំ សង្កាត់ ចំណូលសំខាន់របស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក គឺប្រភពចំណូលពីថ្នាក់ជាតិដែលបានមកពីការផ្ទេរពីថវិកាជាតិ ហៅថាថវិការាជធានី ខេត្ត និងមូលនិធិក្រុង ស្រុក។ ដោយឡែកក្រុមប្រឹក្សាខណ្ឌ និងក្រុមប្រឹក្សាសង្កាត់ក្នុងខណ្ឌ ក៏ដូចក្រុមប្រឹក្សាសង្កាត់ក្នុងក្រុង ត្រូវមានថវិកាសម្រាប់អនុវត្តមុខងារភារកិច្ចរបស់ខ្លួន ដែលស្ថិតនៅក្នុងថវិការាជធានី និងថវិកាក្រុង។

ចំណូលសំខាន់មួយទៀតរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ គឺចំណូលដែលបានមកពីការអនុវត្តមុខងារជាភ្នាក់ងារ ដែលជាចំណូលដែលបានមកពីការបំពេញភារកិច្ចក្នុងនាមក្រសួង ស្ថាប័ន ឬអង្គភាពនានារបស់រដ្ឋទៅតាមការព្រមព្រៀងគ្នា។ ជាមួយគ្នានេះ កាលពីដើមខែវិច្ឆិកា ឆ្នាំ២០២៤ រាជរដ្ឋាភិបាលបានចេញនូវអនុក្រឹត្យស្តីពីការកំណត់អត្រាចែករំលែកចំណូលពីសេវាសាធារណៈ និងចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ ពីរដ្ឋបាលថ្នាក់ជាតិជាគុណប្រយោជន៍ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយបានកំណត់ចំណូលពីសម្បទាននេសាទ ចំណូលពីការជួលទ្រព្យសម្បត្តិរដ្ឋរបស់មន្ទីរជំនាញរាជធានី ខេត្ត ចំណូលពីសម្បទានដីសេដ្ឋកិច្ច និងចំណូលពីផលព្រៃឈើត្រូវចែករំលែកពីរដ្ឋបាលថ្នាក់ជាតិជាគុណប្រយោជន៍ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។

ចំណូលដូចបានរៀបរាប់ខាងលើត្រូវបានអនុញ្ញាតឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិយកទៅប្រើប្រាស់ក្នុងការចំណាយលើចរន្តរដ្ឋបាលដែលផ្តោតលើប្រាក់បៀវត្សបុគ្គលិក និងប្រតិបត្តិការប្រចាំថ្ងៃនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងចំណាយលើការអភិវឌ្ឍមូលដ្ឋាន ដោយផ្តោតទៅលើការប្រើប្រាស់ដើម្បីអនុវត្តមុខងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

វិមជ្ឈការហិរញ្ញវត្ថុត្រូវបានផ្តល់និយមន័យថាជាការសំដៅដល់ការប្រគល់នូវការទទួលខុសត្រូវ និងអំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការធ្វើសេចក្តីសម្រេចចិត្តលើការគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ធនធានរបស់ខ្លួនតាមឆន្ទានុសិទ្ធិ ដើម្បីឆ្លើយតបនឹងតម្រូវការរបស់ប្រជាពលរដ្ឋមូលដ្ឋានដែលជាម្ចាស់ឆ្នោត។ ការធ្វើវិមជ្ឈការហិរញ្ញវត្ថុមានអត្ថប្រយោជន៍ក្នុងការបង្កើនសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការបង្កើនប្រសិទ្ធភាពសេវាសាធារណៈ ជំរុញការចូលរួមក្នុងសហគមន៍ និងការអភិវឌ្ឍនៅមូលដ្ឋាន។ សម្រាប់ការអនុវត្ត រដ្ឋបាលថ្នាក់ជាតិត្រូវរៀបចំឱ្យមានគោលការណ៍ក្នុងការប្រើប្រាស់ថវិកាឱ្យបានត្រឹមត្រូវ និងត្រូវផ្តល់សិទ្ធិអំណាចឱ្យអាជ្ញាធរមូលដ្ឋានអាចប្រមូល និងប្រើប្រាស់ធនធានហិរញ្ញវត្ថុតាមតម្រូវការ។ Roy & Richard (២០០៨) បានឱ្យនិយមន័យវិមជ្ឈការហិរញ្ញវត្ថុថាជាការផ្ទេរសិទ្ធិអំណាចសម្រេចចិត្តលើបញ្ហាហិរញ្ញវត្ថុ ការចំណាយ និងថវិកាវិភាជន៍ពីរដ្ឋាភិបាលថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ សំដៅផ្តល់សិទ្ធិអំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការបែងចែកធនធាន និងប្រើប្រាស់សម្រាប់ការអភិវឌ្ឍ ស្របតាម

តម្រូវការជាក់ស្តែងនៅមូលដ្ឋាន។ ការលើកឡើងនេះមានភាពស្របគ្នាទៅនឹងការអះអាងរបស់ Schneider (២០០៣) ដែលថា វិមជ្ឈការហិរញ្ញវត្ថុមិនមែនគ្រាន់តែជាការបង្កើនកញ្ចប់ថវិកាទៅរដ្ឋបាលថ្នាក់ក្រោមជាតិប៉ុណ្ណោះទេ ប៉ុន្តែជាការផ្តល់ឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនូវសិទ្ធិក្នុងការគ្រប់គ្រងចំណូលនៅមូលដ្ឋាន ដើម្បីសម្រេចបាននូវតុល្យភាពនៃចំណូល និងចំណាយពាក់ព័ន្ធហិរញ្ញវត្ថុ។ ការសម្រេចចិត្តរបស់រដ្ឋបាលថ្នាក់ជាតិក្នុងការគ្រប់គ្រងពន្ធលើអចលនទ្រព្យ និងប្រភពចំណូលសំខាន់ៗផ្សេងទៀត នឹងកាត់បន្ថយឯករាជ្យភាពផ្នែកហិរញ្ញវត្ថុរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលកត្តានេះអាចបណ្តាលឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិខ្វះលទ្ធភាពក្នុងការដោះស្រាយបញ្ហាអាទិភាពក្នុងមូលដ្ឋាន និងការផ្តល់សេវាចាំបាច់បន្ទាន់នៅមូលដ្ឋាន (Lameck, ២០២២)។

ក្នុងន័យម្យ៉ាងទៀត កង្វះថវិកាក្នុងការអនុវត្តមុខងារនៅមូលដ្ឋាន នឹងរាំងស្ទះដល់ដំណើរការអនុវត្តកំណែទម្រង់ ក៏ដូចការអភិវឌ្ឍនៅមូលដ្ឋាន។ Eton et al. (២០២៣) បានអះអាងថា ការកាត់បន្ថយថវិកាវិភាជន៍ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ កង្វះពេលវេលា ក្នុងការអនុវត្តថវិកា ស្មើនឹងការបរាជ័យក្នុងការឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ។ ស្រដៀងគ្នានេះដែរ Rubin & Willoughby (២០២៤) ក៏បានសន្និដ្ឋានថា ថវិកាគឺជាឧបករណ៍សំខាន់សម្រាប់រដ្ឋាភិបាលក្នុងការបង្កើត និងផ្លាស់ប្តូរគោលនយោបាយ ដែលយើងអាចសន្និដ្ឋានបានថាថវិកាពិតជាមានសារៈសំខាន់សម្រាប់ការផ្តួចផ្តើមរបស់ក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការដាក់ចេញគោលនយោបាយនៅមូលដ្ឋាន ក៏ដូចជាការអភិវឌ្ឍមូលដ្ឋានស្របតាមតម្រូវការរបស់ប្រជាពលរដ្ឋ។ ជាមួយគ្នានេះ Ye et al. (២០២៤) បានគូសបញ្ជាក់អំពីការគាំទ្ររបស់រដ្ឋបាលថ្នាក់ជាតិក្នុងការអនុវត្តវិមជ្ឈការហិរញ្ញវត្ថុ ដោយបានលើកឡើងថា ជាទូទៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានជំរុញលើកទឹកចិត្តឱ្យចូលរួមក្នុងការអនុវត្តសាកល្បងនូវគោលនយោបាយរបស់រដ្ឋបាលថ្នាក់ជាតិ ជាពិសេសពាក់ព័ន្ធការធ្វើវិមជ្ឈការហិរញ្ញវត្ថុ ឬការបែងចែកធនធានផ្ទេរពីរដ្ឋាភិបាលថ្នាក់ជាតិ ក៏ប៉ុន្តែការយកចិត្តទុកដាក់ក្នុងការគាំទ្រទៅលើសកម្មភាពនៃការអនុវត្តសាកល្បងនៅមានកម្រិតនៅឡើយ ជាពិសេសពាក់ព័ន្ធនឹងការគាំទ្រថវិកា និងធនធានផ្សេងៗទៀតដើម្បីអនុវត្តសាកល្បងនូវគោលនយោបាយទាំងនោះ។

ជារួម វិមជ្ឈការហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជានៅមានកម្រិតនៅឡើយ និងនៅទទួលឥទ្ធិពលពីថ្នាក់ជាតិ។ យោងតាមច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤ ចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២៣ ថវិកានៃរដ្ឋបាលថ្នាក់ក្រោមជាតិមានទំហំសរុបស្មើនឹង ៦ ៩៦៩ ១៥៨,៣ លានរៀល ស្មើនឹង ១៦,៨% នៃថវិកាជាតិសរុបប្រចាំឆ្នាំ២០២៤។ ម្យ៉ាងទៀត បច្ចុប្បន្ន រដ្ឋបាលថ្នាក់ក្រោមជាតិនៅតែពឹងផ្អែកខ្លាំងលើថវិកាផ្ទេរពីរដ្ឋបាលថ្នាក់ជាតិ ដោយមិនទាន់ទទួលបានសិទ្ធិអំណាចក្នុងការប្រមូលចំណូលផ្ទាល់នៅមូលដ្ឋាន។ ក្នុងន័យនេះ ដើម្បីអាចអនុវត្តកំណែទម្រង់វិមជ្ឈការបានពេញលេញ ការធ្វើវិមជ្ឈការហិរញ្ញវត្ថុគួរត្រូវបានពិចារណាក្នុងការពន្លឿន និងពង្រឹង ដើម្បីផ្តល់សិទ្ធិអំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង និងប្រើប្រាស់ធនធានហិរញ្ញវត្ថុស្របតាមតម្រូវការរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

### ២.៣ ការផ្ទេរមុខងារ

មាត្រា២៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (២០០៨) បានចែងថា "ក្រុមប្រឹក្សាមានតួនាទីចាត់ចែងកិច្ចការចាំបាច់នានា ដើម្បីសម្រេចនូវគោលបំណងក្នុងការបង្កើត ការជំរុញ

និងការធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យព្រមទាំងដើម្បីបំពេញមុខងារភារកិច្ចដែលបានប្រគល់ និងដែលបានធ្វើប្រតិភូកម្មតាមច្បាប់នេះ ឬដែលស្របតាមច្បាប់នេះ។" ក្នុងន័យនេះ ក្រុមប្រឹក្សាត្រូវចាត់វិធានការចាំបាច់នានាដើម្បីធានាថា រាល់មុខងារដែលផ្ទេរទៅឱ្យក្រុមប្រឹក្សាខេត្ត រួមទាំងមុខងារជាអាណត្តិទូទៅដែលក្រុមប្រឹក្សាខេត្តបានសម្រេចជ្រើសរើសយកមកអនុវត្ត ត្រូវបានយកទៅអនុវត្តយ៉ាងពេញលេញប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។ ការអនុវត្តមុខងារខាងលើនេះ អាចស្តែងឡើងតាមរយៈការរៀបចំផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលដែលត្រូវធ្វើបច្ចុប្បន្នភាពប្រចាំឆ្នាំ។ ទន្ទឹមនេះ ក្រុមប្រឹក្សាត្រូវធានាថាសកម្មភាពនានាដែលជាតម្រូវការចាំបាច់ក្នុងការអនុវត្តមុខងារដូចដែលបានលើកឡើងខាងលើត្រូវបានបញ្ចូលទៅក្នុងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលសាមី។ ជាមួយនេះ ក្រុមប្រឹក្សាក៏ត្រូវធ្វើការតាមដានត្រួតពិនិត្យ និងផ្តល់យោបល់ផងដែរ លើការអនុវត្តមុខងារទាំងនោះ តាមរយៈការពិនិត្យ ពិភាក្សានៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា ដែលមានគណៈអភិបាលជាអ្នកធ្វើសេចក្តីរាយការណ៍អំពីវឌ្ឍនភាព និងបញ្ហាប្រឈមនានាក្នុងការអនុវត្តមុខងារទាំងនោះ។

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (២០០៨) បានកំណត់ឱ្យរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌមានមុខងារពីរប្រភេទ គឺមុខងារជាកាតព្វកិច្ច និងមុខងារជាជម្រើស ដែលត្រូវផ្ទេរពីក្រសួង ស្ថាប័នថ្នាក់ជាតិទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌតាមរយៈលិខិតបទដ្ឋានជាធរមាន។ មុខងារជាកាតព្វកិច្ច គឺជាមុខងារដែលមានលក្ខណៈជាកាតព្វកិច្ច ហើយដែលក្រុមប្រឹក្សាត្រូវតែអនុវត្តដោយខានមិនបាន នៅពេលមុខងារប្រភេទនេះត្រូវបានផ្ទេរទៅឱ្យក្រុមប្រឹក្សា ក្នុងលក្ខណៈជាការប្រគល់ក្តី ឬជាប្រតិភូកម្មក្តី ដោយភ្ជាប់មកជាមួយនូវធនធាន(បុគ្គលិក ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ) សម្រាប់អនុវត្តមុខងារទាំងនោះ។ នៅចុងឆ្នាំ២០១៩ រាជរដ្ឋាភិបាលបានដាក់ចេញអនុក្រឹត្យលេខ ១៨២, ១៨៣ និង ១៨៤ ដើម្បីកំណត់មុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្នុងគោលបំណងលើកកម្ពស់ប្រសិទ្ធភាពក្នុងការគ្រប់គ្រងរដ្ឋបាល ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពជាក់ស្តែងរបស់ប្រជាពលរដ្ឋស្របតាមគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។ តាមរយៈអនុក្រឹត្យខាងលើ ការិយាល័យជំនាញរបស់មន្ទីរនានាត្រូវបានធ្វើសមាហរណកម្ម ឱ្យមកស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដោយក្នុងនោះបុគ្គលិកប្រមាណ ៤០ ០០០នាក់ និងមុខងារចំនួន៥៥ ក្នុងវិស័យចំនួន២០ ត្រូវបានផ្ទេរ និងប្រគល់ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។

ដោយឡែក មុខងារជាជម្រើស ជាមុខងារមិនមានលក្ខណៈជាកាតព្វកិច្ច ដែលក្រុមប្រឹក្សាអាចជ្រើសរើសយកមកអនុវត្ត ឬមិនអនុវត្តក៏បាន អាស្រ័យលើតម្រូវការជាក់ស្តែង និងឬធនធានដែលរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌនីមួយៗមាន។ មុខងារជាជម្រើសមានពីរប្រភេទគឺ មុខងារជាជម្រើសដែលក្រសួង ស្ថាប័នផ្ទេរតាមរយៈការប្រគល់ទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់តាមរយៈលិខិតបទដ្ឋានជាធរមាន និងមុខងារជាជម្រើសមួយប្រភេទទៀតដែលហៅថា អាណត្តិទូទៅ។ អាណត្តិទូទៅជាប្រភេទមុខងារជាជម្រើសដែលក្រសួង ស្ថាប័ន មិនបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ប៉ុន្តែរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់គិតថាមានការចាំបាច់នៅក្នុងមូលដ្ឋានរបស់ខ្លួន ហើយក្រសួង ស្ថា

ប័នមិនបានធ្វើ និងមិនបានជំទាស់ក្នុងការដែលរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ជ្រើសរើសមុខងារនោះយកមកធ្វើ (គ.ជ.អ.ប, ២០១៥)។

ជារួម ការផ្ទេរមុខងារមានពីរប្រភេទ គឺការផ្ទេរដោយប្រគល់ និងការផ្ទេរដោយប្រតិភូកម្ម ហើយប្រភេទទាំងពីរនេះខុសគ្នាត្រង់ភាពជាម្ចាស់ក្នុងការអនុវត្តមុខងារនីមួយៗ។ ការប្រគល់មុខងារ ជាការផ្ទេរភាពជាម្ចាស់នៃមុខងារ ការទទួលខុសត្រូវ អំណាច និងធនធានុសិទ្ធិទាំងអស់ដែលចាំបាច់ដើម្បីគ្រប់គ្រង និងអនុវត្តមុខងារឱ្យមានប្រសិទ្ធភាពខ្ពស់។ ប្រតិភូកម្មមុខងារ ជាការផ្ទេរមុខងារ ការទទួលខុសត្រូវអំណាច ធនធានុសិទ្ធិ ដើម្បីគ្រប់គ្រង និងអនុវត្តមុខងារក្នុងនាមក្រសួង ស្ថាប័ន ដែលធ្វើប្រតិភូកម្ម ប៉ុន្តែក្រសួង ស្ថាប័នដែលបានធ្វើប្រតិភូកម្មនៅតែរក្សាភាពជាម្ចាស់លើកិច្ចការដែលបានធ្វើប្រតិភូកម្មនោះដដែល។ រហូតមកដល់បច្ចុប្បន្ន តាមការសង្កេតឃើញថាមុខងារភាគច្រើនដែលអនុវត្តដោយរដ្ឋបាលថ្នាក់ក្រោមជាតិមានលក្ខណៈជាអាណត្តិទូទៅ ជាជាងមុខងារដែលបានផ្ទេរជាក់លាក់ដោយក្រសួង ស្ថាប័ន ដើម្បីឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិងាយស្រួលក្នុងការជ្រើសរើសនិងអនុវត្ត។

## ២.៤ ការរៀបចំលិខិតបទដ្ឋាន និងគោលនយោបាយនៅមូលដ្ឋាន

យោងតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (២០០៨) និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ (២០០១) ក្រុមប្រឹក្សាមានសិទ្ធិអំណាចធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ និងសេចក្តីសម្រេចខាងប្រតិបត្តិ។ ដីកា គឺជាវិធានខាងផ្លូវច្បាប់ដែលបានអនុម័តដោយក្រុមប្រឹក្សា។ យោងតាមបទប្បញ្ញត្តិនៃច្បាប់នេះ ក្រុមប្រឹក្សាប្រើប្រាស់សិទ្ធិអំណាចបញ្ញត្តិរបស់ខ្លួន តាមការធ្វើសេចក្តីសម្រេចដើម្បីដាក់ចេញនូវដីកាតាមការចាំបាច់។ ដីការបស់ក្រុមប្រឹក្សាមានវិសាលភាពដើម្បីកំណត់ ហាមឃាត់ ឬដើម្បីត្រូវពិនិត្យលើសកម្មភាព លើនីតិវិធី ឬលើកិច្ចការណាមួយដែលស្ថិតនៅក្នុងវិសាលភាពនៃមុខងារ ភារកិច្ច និងធនធានរបស់ក្រុមប្រឹក្សា។ ជាមួយគ្នានេះ យោងតាម Rohdewohld (២០២១) កំណែទម្រង់វិមជ្ឈការរបស់ប្រទេសកម្ពុជាត្រូវបានរារាំងដោយសារភាពមិនច្បាស់លាស់ក្នុងការកំណត់តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ ច្បាប់បានផ្តល់អំណាចខាងបញ្ញត្តិ និងប្រតិបត្តិដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ប៉ុន្តែការផ្ទេរមុខងារពីថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនៅមានកម្រិត និងពុំទាន់ច្បាស់លាស់។ ស្រដៀងគ្នានេះដែរ Niazi (២០១១) បានគូសបញ្ជាក់ថា ការកំណត់តួនាទីមិនច្បាស់លាស់ និងអាណត្តិកិច្ចត្រួតស៊ីគ្នារវាងរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលមូលដ្ឋានអាចនាំឱ្យការអនុវត្តការងារគ្មានប្រសិទ្ធភាព និងបង្កើតវិវាទ។

ធនាគារពិភពលោក និងអង្គការសហប្រជាជាតិ បានលើកឡើងថាសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាមូលដ្ឋានគ្រឹះសម្រាប់ដំណើរការប្រកបដោយប្រសិទ្ធភាពនៃរដ្ឋាភិបាលនានាទូទាំងពិភពលោក (World Bank, ២០០១; United Nations, ២០០៩)។ ការធ្វើវិមជ្ឈការផ្នែកនយោបាយ សារពើពន្ធ និងការទទួលខុសត្រូវការងារគ្រប់គ្រងរដ្ឋបាល អភិបាលកិច្ចនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសដែលអនុវត្តការគ្រប់គ្រងតាមបែបមជ្ឈការបានក្លាយជាប្រធានបទក្នុងការចោទជាសំណួរអំពីសមត្ថភាពរបស់មន្ត្រីនៅរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការទទួលខុសត្រូវ និងអនុវត្តមុខងារពាក់ព័ន្ធការគ្រប់គ្រងហិរញ្ញវត្ថុ និងផែនការនៅមូលដ្ឋាន។ តាមការសិក្សារបស់ Abdullah (២០១៩) បានអះអាងថា ក្រុមប្រឹក្សា

មូលដ្ឋានបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងដំណើរការដាក់ចេញគោលនយោបាយ ជាពិសេសក្នុងការកំណត់បញ្ហា ការកំណត់របៀបវារៈ ការរៀបចំគោលនយោបាយ និងការធ្វើសេចក្តីសម្រេចចិត្ត។ កត្តាសំខាន់ដូចជាលទ្ធភាពបច្ចេកទេស មតិយោបល់សាធារណៈ ការពិចារណាអំពីថវិកា និងការរួបរួមគ្នាត្រូវបានរកឃើញថាមានសារៈសំខាន់ក្នុងការបង្កើនប្រសិទ្ធភាពការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ យោងតាម Brown & Potoski (២០០៣) សមត្ថភាពមន្ត្រីរាជការនៅរដ្ឋបាលថ្នាក់ក្រោមជាតិពិតជាមានសារៈសំខាន់សម្រាប់ការអនុវត្តការទទួលខុសត្រូវកំណែទម្រង់វិមជ្ឈការប្រកបដោយប្រសិទ្ធភាព។ ការសិក្សាស្រាវជ្រាវករណីសិក្សាក្នុងប្រទេសអ៊ីស្លង់ ដោយ Hlynsdóttir (២០២៤) បានសង្កត់ធ្ងន់ពីតួនាទីដ៏សំខាន់របស់រដ្ឋាភិបាលមូលដ្ឋាន ក្នុងការបង្កើតគោលនយោបាយជាយុទ្ធសាស្ត្រ ដោយសង្កត់ធ្ងន់លើសារៈសំខាន់នៃភាពជាអ្នកដឹកនាំ សមត្ថភាពផ្នែករដ្ឋបាល និងដំណើរការនៃរចនាសម្ព័ន្ធរបស់រដ្ឋបាល។ ការស្រាវជ្រាវនេះបានបង្ហាញថារដ្ឋបាលក្រុងតូចៗបានជួបនឹងបញ្ហាប្រឈមនៃការកង្វះធនធាន និងអ្នកជំនាញបច្ចេកទេសវិជ្ជាជីវៈដែលរារាំងសមត្ថភាពរបស់ក្រុមប្រឹក្សាក្នុងការចូលរួមក្នុងការធ្វើផែនការរយៈពេលវែង ឬគោលនយោបាយ។

ជាមួយគ្នានេះ វិមជ្ឈការសារពើពន្ធ ត្រូវបានចាត់ទុកជាមូលដ្ឋានគ្រឹះមួយនៃអភិបាលកិច្ចមូលដ្ឋានប្រកប ដោយប្រសិទ្ធភាព។ យោងតាមធនាគារអភិវឌ្ឍន៍អាស៊ី (២០១៨) រដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជាបានពឹងផ្អែកខ្លាំងទៅលើការផ្ទេរសិទ្ធិអំណាចពីរដ្ឋបាលថ្នាក់ជាតិ ក៏ដូចជាការវិភាជន៍ថវិកាដែលសព្វថ្ងៃនៅមានកម្រិត។ ភាពពឹងផ្អែក និងខ្វះខាតនេះ បានដាក់កម្រិតសមត្ថភាពក្នុងការផ្តល់មូលនិធិដល់គម្រោងក្នុងមូលដ្ឋាន និងការឆ្លើយតបទៅនឹងតម្រូវការសហគមន៍។ ក្នុងន័យនេះ លទ្ធភាពក្នុងការទទួលបានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ និងអាចព្យាករណ៍បាន រួមទាំងចំណូលពីប្រភពផ្ទាល់ខ្លួន គឺជាកត្តាចំបាច់មួយដែលផ្តល់លទ្ធភាពដល់ក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការដាក់ចេញនិងអនុវត្តដីកា និងគោលនយោបាយនៅមូលដ្ឋានប្រកបដោយប្រសិទ្ធភាព។ ក្នុងនោះផងដែរ ការចូលរួមរបស់ប្រជាពលរដ្ឋ ក៏ត្រូវបានចាត់ទុកថាជាកត្តាសំខាន់មួយទៀតក្នុងការរៀបចំគោលនយោបាយនៅ រដ្ឋបាលថ្នាក់ក្រោមជាតិ និងដើម្បីធានាបានថាគោលនយោបាយនោះបានឆ្លុះបញ្ចាំងពីតម្រូវការនៅក្នុងសហគមន៍។ យោងតាម EU SPACE (២០១០) ទោះបីជាសមាជិកក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិបានយល់ដឹងអំពីសារៈសំខាន់នៃការពិគ្រោះយោបល់ជាសាធារណៈក្នុងការអនុវត្តនៅមូលដ្ឋាន ប៉ុន្តែជារឿយៗក្រុមប្រឹក្សាបរាជ័យក្នុងការអនុវត្តគោលការណ៍នៃការចូលរួមជាមួយប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព។

ជារួម ការរៀបចំតាក់តែងដីកា និងគោលនយោបាយនៅមូលដ្ឋានត្រូវការជា ចាំបាច់នូវភាពស្របច្បាប់របស់ក្រុមប្រឹក្សាក្នុងការរៀបចំ និងដាក់ឱ្យប្រើប្រាស់ដែលបានប្រគល់ដោយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា។ ក្នុងនោះផងដែរ ធនធានមនុស្ស ធនធានហិរញ្ញវត្ថុ និងការចូលរួមរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន ត្រូវបានចាត់ទុកថាជាកត្តាសំខាន់ៗ ដែលគាំទ្រដល់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការរៀបចំគោលនយោបាយនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

### ២.៥ ការសន្មត (Propositions)

ផ្អែកតាមការរំលឹកទ្រឹស្តីខាងលើ ការរៀបចំប្រព័ន្ធគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានការបែងចែកតួនាទី និងការទទួលខុសត្រូវមិនបានច្បាស់លាស់ ឬមិនបានសមស្របនាំឱ្យក្រុមប្រឹក្សាថ្នាក់

ក្រោមជាតិមិនអាចធ្វើសេចក្តីសម្រេចចិត្តពេញលេញក្នុងការរៀបចំ និងដាក់ចេញគោលនយោបាយនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ ប្រសិនបើអ្នកដឹកនាំនៅរដ្ឋបាលថ្នាក់ក្រោមជាតិទទួលឥទ្ធិពលពីអ្នកនយោបាយ ឬពីគណបក្សនយោបាយតាមរយៈការតែងតាំង ការចាត់ចែងសមាសភាពរបស់ថ្នាក់ដឹកនាំ និងអ្នកអនុវត្តការងារនៅមូលដ្ឋាន ជាពិសេសគណៈអភិបាលដែលជាអ្នកទទួលអនុវត្តដីការបស់ក្រុមប្រឹក្សា នាំឱ្យសិទ្ធិអំណាចដែលច្បាប់បានប្រគល់ជូនក្រុមប្រឹក្សាថ្នាក់ក្រោមជាតិតាមរយៈលិខិតបទដ្ឋានគតិយុត្តនានានឹងត្រូវបានកាត់បន្ថយ។ យោងតាមការសន្និដ្ឋានខាងលើ ការសន្មតទី១ ត្រូវបានលើកឡើង៖

*ការសន្មតទី១៖ "ឥទ្ធិពលផ្នែកនយោបាយ និងកង្វះសិទ្ធិអំណាចដឹកនាំនៅមូលដ្ឋានបានកាត់បន្ថយសិទ្ធិអំណាចខាងបញ្ញត្តិ និងសិទ្ធិអំណាចខាងប្រតិបត្តិរបស់ក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិ។"*

ជាមួយគ្នានេះ ការប្រគល់សិទ្ធិអំណាចក្នុងការគ្រប់គ្រង និងចាត់ចែងហិរញ្ញវត្ថុកាន់តែច្រើនទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ នឹងបង្កើនលទ្ធភាពដល់ក្រុមប្រឹក្សាក្នុងការអភិវឌ្ឍនៅមូលដ្ឋានតាមរយៈការឆ្លើយតបកាន់តែច្រើនទៅនឹងតម្រូវការជាក់ស្តែងនៅមូលដ្ឋាន។ ការកំណត់ការប្រើប្រាស់ថវិកានៅរដ្ឋបាលថ្នាក់ក្រោមជាតិ ឬការផ្ទេរថវិកាទៅរដ្ឋបាលថ្នាក់ក្រោមជាតិនៅមានកម្រិតប្រៀបធៀបទៅនឹងទំហំមុខងារដែលបានផ្ទេរទៅក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ នឹងរារាំងដល់ការផ្តួចផ្តើមក្នុងការរៀបចំ ផែនការអភិវឌ្ឍផ្ទាល់នៅមូលដ្ឋានរបស់ក្រុមប្រឹក្សាក្នុងការដាក់ចេញគោលនយោបាយ និងលិខិតបទដ្ឋាននានាដែលសមស្របទៅនឹងតម្រូវការផ្ទាល់របស់ប្រជាពលរដ្ឋក្នុងនាមជាអ្នកតំណាងនៅមូលដ្ឋាន។ យោងតាមការសន្និដ្ឋានខាងលើ ការសន្មតទី២ ត្រូវបានលើកឡើង៖

*ការសន្មតទី២៖ "ការវិភាជន៍ថវិកាមានកម្រិតទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិបានរារាំង ឬបង្អាក់ការផ្តួចផ្តើម និងការដាក់ចេញលិខិតដ្ឋាន និងគោលនយោបាយរបស់ក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិ។"*

ម្យ៉ាងទៀត សមត្ថភាពរបស់ក្រុមប្រឹក្សា និងបុគ្គលិកនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ក៏ជាកត្តាសំខាន់បំផុតមួយទៀត ដែលប្រទេសកំពុងអភិវឌ្ឍនៅទូទាំងសកលលោកបាននិងកំពុងជួបប្រទះ។ សមត្ថភាពរបស់បុគ្គលិកនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានកំណត់ថាមានឥទ្ធិពលខ្លាំងទៅលើការអនុវត្តកំណែទម្រង់វិមជ្ឈការ ក៏ដូចការអនុវត្តគោលនយោបាយ និងផែនការនានារបស់ប្រទេសជាតិ។ ប្រសិនបើរដ្ឋបាលថ្នាក់ក្រោមជាតិមិនមានធនធានមនុស្សដែលមានប្រសិទ្ធភាពសម្រាប់អនុវត្តការងារទេ ទោះបីជាមានធនធានថវិកាក៏ដោយ ក៏មិនអាចអនុវត្តការងារបានជោគជ័យដែរ។ យោងតាមការសន្និដ្ឋានខាងលើការសន្មតទី៣ ត្រូវបានលើកឡើង៖

*ការសន្មតទី៣៖ "កង្វះចំណេះដឹង និងជំនាញក្នុងការរៀបចំលិខិតបទដ្ឋានណិងគោលនយោបាយរបស់សមាជិកក្រុមប្រឹក្សា និងមន្ត្រីរាជការនៅរដ្ឋបាលថ្នាក់ក្រោមជាតិ រារាំងដល់ការផ្តួចផ្តើម និងដាក់ចេញលិខិតបទដ្ឋាន និងគោលនយោបាយនៅមូលដ្ឋាន។"*

## ២.៦ ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវអាចនឹងមានបញ្ហាពាក់ព័ន្ធនឹងភាពលំអៀងនៃទិន្នន័យដែលទទួលបានពីក្រុមគោលដៅសម្ភាសន៍ដោយមូលហេតុនៃចម្លើយមួយចំនួនផ្អែកទៅលើការចង់បានរបស់ក្រុមគោលដៅដែលបានចូលរួមនិងមិនបានឆ្លុះបញ្ចាំងពីទិដ្ឋភាពជាក់ស្តែង។ ម៉្យាងវិញទៀតការជ្រើសរើសសំណាកនៃក្រុមគោលដៅគឺត្រូវបានផ្តោតទៅលើតែក្រុមប្រឹក្សា និងគណៈអភិបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយមិនបានពង្រីកដល់អ្នករៀបចំគោលនយោបាយ ភាគីពាក់ព័ន្ធនានា និងប្រជាពលរដ្ឋនៅមូលដ្ឋានដែលនាំឱ្យទិន្នន័យទទួលបានអាចមានភាពចន្លោះប្រហោងនិងមិនគ្រប់ជ្រុងជ្រោយ។

# ៣. វិធីសាស្ត្រស្រាវជ្រាវ

## ៣.១ ប្រភេទនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ បានប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវបែបគុណវិស័យ។ វិធីសាស្ត្រស្រាវជ្រាវបែបគុណវិស័យត្រូវបានប្រើប្រាស់ដើម្បីប្រមូលទិន្នន័យជាក់លាក់ពាក់ព័ន្ធការអនុវត្តជាក់ស្តែង បទពិសោធន៍ បញ្ហាប្រឈម ឧបសគ្គ និងតម្រូវការជាក់លាក់នានាដែលរដ្ឋបាលថ្នាក់ក្រោមជាតិ និងក្រុមប្រឹក្សារបស់ខ្លួនបាននិងកំពុងជួបប្រទះ សំដៅកំណត់នូវកត្តានានាដែលមានឥទ្ធិពលលើគំនិតផ្តួចផ្តើមរបស់ក្រុមប្រឹក្សាក្នុងការរៀបចំនិងដាក់ចេញលិខិតបទដ្ឋាន និងគោលនយោបាយនៅមូលដ្ឋាន ព្រមទាំងសំណើ សំណូមពរនានាក្នុងការដោះស្រាយបញ្ហាប្រឈម ឧបសគ្គ និងតម្រូវការនៅក្នុងបរិបទនៃការរៀបចំនិងដាក់ចេញនូវលិខិតបទដ្ឋាន និងគោលនយោបាយនៅមូលដ្ឋាននេះ។

ក្នុងការប្រមូលទិន្នន័យបែបគុណវិស័យ ការសម្ភាសពាក់កណ្តាលរចនាសម្ព័ន្ធ (Semi-structure interview) ការពិភាក្សាជាក្រុម (Focus Group Discussions) និងការអង្កេតជាក់ស្តែងត្រូវបានប្រើប្រាស់។

## ៣.២ ការជ្រើសរើសសំណាក

ដោយផ្អែកលើតំណាងភូមិសាស្ត្រ ប្រជាសាស្ត្រ ខេត្តតាកែវ ខេត្តកំពង់ចាម ខេត្តបាត់ដំបង និងខេត្តព្រះវិហារ ត្រូវបានជ្រើសរើសជាខេត្តគោលដៅក្នុងការសម្ភាស។ ក្នុងខេត្តគោលដៅនីមួយៗ ក្រុងស្រុកចំនួន២ ត្រូវបានជ្រើសរើស។ ដោយឡែកនៅថ្នាក់ឃុំ សង្កាត់ ឃុំចំនួន១ ត្រូវបានជ្រើសរើសពីស្រុក និងសង្កាត់ចំនួន១ ត្រូវបានជ្រើសរើសពីក្រុង។ ជារួម រដ្ឋបាលថ្នាក់ក្រោមជាតិសរុបចំនួន២០ ត្រូវបានជ្រើសរើសសម្រាប់ការសិក្សាស្រាវជ្រាវនេះ។

សំណាកសរុបសម្រាប់ការសិក្សាស្រាវជ្រាវនេះ មានចំនួន១០០ ក្នុងនោះរួមមានសមាសភាពជាប្រធានក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក សមាជិកក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ អភិបាល ឬអភិបាលរងខេត្ត ក្រុង ស្រុក ប្រធានការិយាល័យលេខាធិការក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក មេឃុំ ចៅសង្កាត់។ ការសម្ភាសត្រូវបានធ្វើឡើងចំនួន៤៣ដង ទាំងការសម្ភាសជាបុគ្គល និងជាក្រុម។

## ៣.៣ វិធីសាស្ត្រប្រមូលទិន្នន័យ

ការប្រមូលទិន្នន័យត្រូវបានធ្វើឡើងតាមរយៈការសម្ភាស ដោយប្រើប្រាស់បញ្ជីសំណួរគន្លឹះសម្រាប់ការសម្ភាស (ឧបសម្ព័ន្ធគ១ និងគ២)។ បញ្ជីសំណួរគន្លឹះសម្រាប់សម្ភាស ត្រូវបានចែកចេញជាប្រាំផ្នែក។ ផ្នែកទី១ ជាព័ត៌មានផ្ទាល់ខ្លួន និងសាវតារពាក់ព័ន្ធនឹងឈ្មោះ ភេទ អាយុ កម្រិតសញ្ញាបត្រ និងបទពិសោធន៍ការងារ។ ផ្នែកទី២ ពាក់ព័ន្ធនឹងឥទ្ធិពលនៃប្រព័ន្ធនយោបាយក្នុងការដាក់ចេញគោលនយោបាយ។ ផ្នែកទី៣ ពាក់ព័ន្ធហិរញ្ញវត្ថុក្នុងការគាំទ្រដល់ការដាក់ចេញនូវគោលនយោបាយ។ ផ្នែកទី៤ ពាក់ព័ន្ធនឹងការអភិវឌ្ឍសមត្ថភាពដើម្បីអាចដាក់ចេញគោលនយោបាយនៅថ្នាក់ក្រោមជាតិ និងផ្នែកទី៥ ពាក់ព័ន្ធនឹងសំណូមពរ និងអនុសាសន៍ផ្សេងៗ។ ជាមួយគ្នានេះ អ្នកស្រាវជ្រាវបានរៀបចំនូវតារាងដើម្បីប្រមូលទិន្ន័យចំនួននិងប្រភេទដីកាដែលបានដាក់ចេញដោយរដ្ឋបាលខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ សម្រាប់ធ្វើការវិភាគពីចំនួនដីកាដែលបានដាក់ចេញដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។

ការចុះសម្ភាសន៍ប្រមូលទិន្នន័យត្រូវបានធ្វើឡើងនៅរដ្ឋបាលខេត្ត ក្រុង ស្រុក ឃុំ សង្កាត់គោលដៅផ្ទាល់ ដែលត្រូវបានជូនដំណឹងជាមុន តាមរយៈការរៀបចំលិខិតរដ្ឋបាលពីសាលាជាតិរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ជម្រាបជូនទៅអភិបាលខេត្តគោលដៅ ដើម្បីចាត់ចែងផ្សព្វផ្សាយបន្តទៅក្រុមគោលដៅ ដែលត្រូវបានកំណត់ពីក្រុមការងារស្រាវជ្រាវ ដើម្បីរដ្ឋបាលខេត្តអាចអញ្ជើញចំគោលដៅដែលក្រុមការងារបានកំណត់។ ក្រុមគោលដៅទាំងអស់បានយល់ព្រមក្នុងការផ្តល់បទសម្ភាសន៍ជាមួយក្រុមការងារដោយស្ម័គ្រចិត្ត និងដោយមិនទទួលបានប្រាក់កម្រៃ ឬអត្ថប្រយោជន៍ណាមួយឡើយ។

ការចុះប្រមូលទិន្នន័យត្រូវបានធ្វើឡើងរយៈពេល៦សប្តាហ៍ ដោយចាប់ផ្តើមចាប់ពីសប្តាហ៍ទី២ នៃខែតុលា រហូតដល់សប្តាហ៍ទី៤នៃ ខែវិច្ឆិកា ឆ្នាំ២០២៤។ ការសម្ភាសន៍ត្រូវបានធ្វើឡើងដោយមានរយៈពេលចន្លោះពី៤៥នាទីដល់៦០នាទី ជាមួយនឹងការកត់ត្រា និងការថតសម្លេងនៃកិច្ចសម្ភាសន៍ដោយបានស្នើសុំការអនុញ្ញាតជាមុន ហើយអ្នកចូលរួមមានសិទ្ធិស្នើសុំបញ្ចប់ការសម្ភាសក្នុងករណីដែលអ្នកចូលរួមមិនពេញចិត្តក្នុងការឆ្លើយសំណួរបន្ត។

នៅអំឡុងកិច្ចសម្ភាសន៍ អ្នកចូលរួមតាមត្រូវបានសួរនូវសំណួរដែលបានផ្ញើជូនជាគម្រូមុនការសម្ភាសរយៈពេលមួយសប្តាហ៍ និងត្រូវបានផ្តោតទៅលើការលើកឡើងអំពីទស្សនៈ និងការយល់ឃើញផ្ទាល់ពាក់ព័ន្ធនឹងការអនុវត្តទាំងវិជ្ជមាន និងអវិជ្ជមានដើម្បីស្វែងរកនូវបញ្ហារួមមួយ ក៏ដូចជាស្រង់នូវពាក្យសម្តីសំខាន់ៗសម្រាប់ធ្វើការវិភាគបញ្ជាក់ជាមួយនឹងការសន្មតដែលត្រូវបានលើកឡើង។ ក្រៅពីការស្តាប់ចម្លើយ ក្រុមការងារក៏បានធ្វើការកត់សំគាល់តាមរយៈការអង្កេតផ្ទាល់ពីការលើកឡើង របស់ក្រុមគោលដៅតាមរយៈកាយវិការ ពាក្យសម្តី និងការយល់ដឹងដែលអាចយកមកធ្វើជាមូលដ្ឋាន ក្នុងការវិភាគផងដែរ។

## ៣.៤ វិធីសាស្ត្រវិភាគទិន្នន័យ

ទិន្នន័យដែលទទួលបានត្រូវយកទៅវិភាគ ដោយប្រើប្រាស់ការវិភាគខ្លឹមសារតាមរយៈការចាប់ក្រុមនៃខ្លឹមសារដែលទទួលបានដើម្បីកំណត់យកបញ្ហាសំខាន់ ក៏ដូចជាទស្សនទានសម្រាប់យកទៅផ្តល់

អនុសាសន៍នានា។ ការវិភាគទិន្នន័យត្រូវបានធ្វើឡើងជាបីដំណាក់កាលធំៗ ដោយដំណាក់កាលទីមួយ បន្ទាប់ពីបញ្ចប់ការសម្ភាសប្រមូលទិន្នន័យ ក្រុមការងារបានចាប់ផ្ដើមរៀបចំបម្លែងការសម្ភាសជាសម្លេង ដែលបានថតទុកទៅជាអត្ថបទសម្រាប់ការចាប់ខ្លឹមសារ។ ដំណាក់កាលទីពីរ ចាប់ផ្ដើមធ្វើការស្រង់យកខ្លឹមសារសំខាន់ៗពីចម្លើយនៃការសម្ភាសរៀបចំទៅក្នុងតារាងវិភាគមួយ ដើម្បីធ្វើការកំណត់នូវខ្លឹមសារ ដើម្បីធ្វើការផ្ទៀងផ្ទាត់ជាមួយការសន្មតទាំងបីដែលត្រូវបានលើកឡើង។ និងដំណាក់កាលទីបី គឺធ្វើការវិភាគនូវចំនួនពាក្យ និងខ្លឹមសារដែលបានលើកឡើងដូចគ្នា ឬស្រដៀងគ្នាដើម្បីបញ្ជាក់ពីការគាំទ្រ ឬមិនគាំទ្រដល់ការសន្មត ក៏ដូចជាស្រង់នូវខ្លឹមសារដែលបានលើកឡើងពីក្រុមគោលដៅផ្ទាល់ដើម្បីធ្វើជាទិន្នន័យសម្រាប់ការបង្ហាញលទ្ធផល និងការពិភាក្សា។ ជាមួយគ្នានេះ លទ្ធផលដែលបានមកពីការអង្កេតក៏ត្រូវបានយកមកបញ្ចូលទៅក្នុងចំណុចនានានៃខ្លឹមសារដែលមានភាពប្រទាក់ក្រឡាគ្នាផងដែរ។

## ៤. លទ្ធផល និងការពិភាក្សា

ការសិក្សាស្រាវជ្រាវនេះត្រូវបានរៀបចំឡើងនៅតាមបណ្ដាក្រុមគោលដៅនៃរដ្ឋបាលខេត្តចំនួន៤ រដ្ឋបាលក្រុង ស្រុក ចំនួន៨ ឃុំ សង្កាត់ ចំនួន៨ (ឧបសម្ព័ន្ធ ខ១)។ ផ្អែកតាមលទ្ធផលនៃការចុះសម្ភាសក្រុមគោលដៅដែលបានចូលរួមសរុបមានចំនួន១០០រូប ដែលក្នុងនោះមានការចូលរួមពីអភិបាល និងអភិបាលរងខេត្ត ក្រុង ស្រុក ចំនួន១២រូប ក្រុមប្រឹក្សាខេត្តចំនួន១២រូប ក្រុមប្រឹក្សាក្រុង ស្រុកចំនួន៤៤រូប និងក្រុមប្រឹក្សាឃុំ សង្កាត់ ចំនួន៣២រូប។ ទិន្នន័យ (ឧបសម្ព័ន្ធ ខ៣) បានបង្ហាញថា ក្នុងចំណោមក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ ដែលចូលរួមសម្ភាសន៍ មានសមាជិកក្រុមប្រឹក្សាដែលបំពេញការងារចាប់ពី១ឆ្នាំដល់៥ឆ្នាំ មានចំនួន ៣៩%, ចាប់ពី៥ឆ្នាំដល់១០ឆ្នាំ មានចំនួន២៧%, ចាប់ពី១០ឆ្នាំដល់ក្រោម ២០ឆ្នាំ មានចំនួន២២% និងលើសពី២០ឆ្នាំ មានចំនួន១៣%។ ជារួម នៅក្នុងកិច្ចសម្ភាសន៍ ក្រុមគោលដៅបានបង្ហាញអំពីទស្សនៈ និងការយល់ឃើញក៏ដូចជា បានបង្ហាញពីកង្វល់នានាពាក់ព័ន្ធការអនុវត្តការងារ បញ្ហាប្រឈម ក៏ដូចបានលើកឡើងនូវអនុសាសន៍ និងសំណូមពរ ដែលត្រូវបានប្រើប្រាស់ដើម្បីជាមូលដ្ឋានក្នុងការវិភាគ និងត្រូវបានដាក់បញ្ចូលក្នុងរបាយការណ៍ស្រាវជ្រាវនេះ។

ជាមួយគ្នានេះ អ្នកស្រាវជ្រាវបានសង្កេតឃើញថា ក្រុមគោលដៅដែលជាគណៈអភិបាលហាក់បង្ហាញពីភាពវិជ្ជមានច្រើនចំពោះការគ្រប់គ្រង និងអនុវត្តការងារនៅមូលដ្ឋានដោយពុំសូវបង្ហាញអំពីកង្វល់ ឬបញ្ហាប្រឈមច្រើនឡើយ លើកលែងតែបញ្ហាថវិកាដែលត្រូវបានលើកយកមកពិភាក្សាច្រើនជាមួយក្រុមការងារ។ ផ្ទុយទៅវិញ ក្រុមគោលដៅដែលជាសមាជិកក្រុមប្រឹក្សាក្រុង ស្រុក ហាក់បានបង្ហាញនូវផលលំបាក និងបញ្ហាប្រឈមច្រើនពាក់ព័ន្ធការគ្រប់គ្រង និងអនុវត្តការងារនៅមូលដ្ឋាន ដូចដែលបានលើកឡើងនៅក្នុងការសន្មតទាំងបី ដែលខុសពីក្រុមគោលដៅជាក្រុមប្រឹក្សាឃុំ សង្កាត់ដែលបង្ហាញពីកង្វល់ភាគច្រើនពាក់ព័ន្ធនឹងកត្តាសមត្ថភាពនៅមានកម្រិត។

យោងតាមលទ្ធផលនៃការសម្ភាស រហូតមកទល់បច្ចុប្បន្ននេះរដ្ឋបាលថ្នាក់ក្រោមជាតិភាគច្រើនបានដាក់ចេញដីកាដែលមានលក្ខណៈឯកត្តភូត និងដីកាដែលមានលក្ខណៈជាបទបញ្ជាទូទៅដែលតម្រូវឱ្យដាក់ចេញដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្ត។ យោងតាមទិន្នន័យ (ឧបសម្ព័ន្ធ ខ១) ក្នុងចំណោម

ខេត្ត ក្រុង ស្រុក ឃុំ សង្កាត់គោលដៅទាំង២០ ដែលត្រូវបានជ្រើសរើស មានការដាក់ចេញនូវដីកាដែលមានលក្ខណៈជាបទបញ្ជាទូទៅ តាមធន្ទានុសិទ្ធិ ឬតម្រូវការដាក់ស្តែងនៅមូលដ្ឋាន មានតែចំនួន២លើកប៉ុណ្ណោះពីក្នុងចំណោមរដ្ឋបាលគោលដៅទាំង២០។ ចំនួននេះ បានបង្ហាញពីភាពនៅមានកម្រិតរបស់ក្រុមប្រឹក្សាក្នុងការដាក់ចេញនូវដីកានៅមូលដ្ឋាន និងចាំបាច់ត្រូវគិតគូរឡើងវិញក្នុងការជំរុញការដាក់ចេញដីកាដែលមានលក្ខណៈជាបទបញ្ជាទូទៅតាមធន្ទានុសិទ្ធិ ឬតម្រូវការដាក់ស្តែងនៅមូលដ្ឋាន។

ចំណុចខាងក្រោមបង្ហាញពីលទ្ធផលនៃការស្រាវជ្រាវ ដែលបានមកពីទិន្នន័យនៃការសម្ភាស និងការពិភាក្សាទៅតាមការសន្មតនីមួយៗ។

***ការសន្មតទី១៖ "ឥទ្ធិពលផ្នែកនយោបាយ និងកង្វះអំណាចដឹកនាំនៅមូលដ្ឋានបានកាត់បន្ថយអំណាចខាងបញ្ញត្តិ និងអំណាចខាងប្រតិបត្តិរបស់ក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិ។"***

យោងតាមលទ្ធផលក្នុងតារាងទី២ (ឧបសម្ព័ន្ធ ក) ក្នុងចំណោមការសម្ភាសជាមួយក្រុមគោលដៅទាំង៤៣លើក មានការលើកឡើងអំពីឥទ្ធិពលនៃប្រព័ន្ធនយោបាយទៅលើដំណើរការ នៃការដឹកនាំគ្រប់គ្រងរបស់ក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិចំនួន១៤លើក ស្មើនឹង៣៣%។ ក្រុមគោលដៅ បានបង្ហាញថា កត្តានយោបាយមានឥទ្ធិពលខ្លាំងទៅលើការដឹកនាំនៅមូលដ្ឋាន ជាពិសេសលើការដឹកនាំ និងការសម្រេចចិត្តនៅមូលដ្ឋាន។

> *"ពាក់ព័ន្ធជាមួយនឹងប្រព័ន្ធនយោបាយនេះ បើប្រៀបធៀបជាមួយនឹងការដឹកនាំកិច្ចការរដ្ឋបាល យើងឃើញថាមានលក្ខណៈស្មុគស្មាញបន្តិចដែរ ដូចយើងបានដឹងហើយថារដ្ឋបាលស្រុកមានអភិបាលជាប្រធានបក្ស ហើយប្រធានក្រុមប្រឹក្សាជាអនុប្រធាន។ បើយើងមើលទៅវារាងផ្ទុយគ្នាបន្តិចក្នុងតួនាទី ដឹកនាំនៅសាលាស្រុក ហើយដោយសារឥទ្ធិពលគណបក្សគ្របដណ្តប់ទៅលើការដឹកនាំនៅរដ្ឋបាលស្រុកពេកធ្វើឱ្យសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាអាចរៀងថយបន្តិច"។ (អភិបាលរងក្រុង ស្រុក)។*

ការរៀបចំឋានានុក្រមដឹកនាំក្នុងគណបក្សនយោបាយ និងរចនាសម្ព័ន្ធគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ (រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) បានបង្ហាញពីភាពមិនស៊ីសង្វាក់គ្នាជាមួយនឹងប្រព័ន្ធនៃការគ្រប់គ្រងរដ្ឋបាល (ពាក់ព័ន្ធនឹងតួនាទីប្រធានគណបក្សនៅមូលដ្ឋានដែលជាទូទៅអាចជាប្រធានក្រុមប្រឹក្សា ឬជាអភិបាល) ដែលនាំឱ្យប៉ះពាល់ដល់ស្វ័យភាព និងប្រសិទ្ធភាពនៃការអនុវត្តការងាររបស់ក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសពាក់ព័ន្ធនឹងទំនាក់ទំនងតួនាទី និងសិទ្ធិអំណាចរវាងមន្ត្រីនយោបាយ និងថ្នាក់ដឹកនាំនៃរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានការបែងចែកមិនទាន់សមស្រប ជាហេតុធ្វើឱ្យប៉ះពាល់ដល់សិទ្ធិអំណាចរបស់ក្រុមប្រឹក្សាលើការធ្វើសេចក្តីសម្រេចចិត្តសំខាន់ៗមួយចំនួន។

ជាមួយគ្នានេះ បញ្ហានៃការកំណត់សិទ្ធិអំណាចរវាងអាជ្ញាធរដែលមានតួនាទីនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងនៅក្នុងគណបក្សបានធ្វើឱ្យប៉ះពាល់ដល់ការដឹកនាំនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានលើក ឡើងផងដែរនៅក្នុងការសម្ភាស។ ក្នុងនោះ ការលើកឡើងពីក្រុមគោលដៅជាសមាជិកក្រុមប្រឹក្សាអំពីឥទ្ធិពលនៃប្រព័ន្ធនយោបាយបានធ្វើឱ្យដំណើរការធ្វើសេចក្តីសម្រេចរបស់រដ្ឋបាលមូលដ្ឋានក្លាយជាកម្មវត្ថុ

នៃសម្ពាធពីខាងក្រៅដែលនាំឱ្យការសម្រេចចិត្តគ្មានប្រសិទ្ធភាព និងមិនឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង។

*"ប្រព័ន្ធដឹកនាំនៅរដ្ឋបាលស្រុក និងប្រព័ន្ធដឹកនាំគណបក្សនៅរដ្ឋបាលស្រុកគួរស្វែងរកការដោះស្រាយមួយដែលអាចអោយភាគីទាំងសងខាងអាចអនុវត្តការងារបានរលូន និងគ្មានសម្ពាធជាពិសេសក្នុងពេលរៀបចំបញ្ជីឈ្មោះលេខរៀងបោះឆ្នោតរបស់សមាជិកក្រុមប្រឹក្សា"។(សមាជិកក្រុមប្រឹក្សាក្រុង ស្រុក)។*

*"សមាជិកក្រុមប្រឹក្សាមានសម្ពាធក្នុងពេលលើកដៃសម្រេចក្នុងកិច្ចប្រជុំក្រុមប្រឹក្សាដោយសារឥទ្ធិពលនៃប្រព័ន្ធនយោបាយក្នុងការឈរឈ្មោះនាអាណត្តិក្រោយ"។ (សមាជិកក្រុមប្រឹក្សាខេត្ត)។*

ជារួម ក្រុមគោលដៅដែលភាគច្រើនជាសមាជិកក្រុមប្រឹក្សាបានបង្ហាញពីការចង់បាននូវសិទ្ធិអំណាចផ្នែកនយោបាយបន្ថែមសម្រាប់ធ្វើការសម្រេចចិត្ត និងការដឹកនាំនៅមូលដ្ឋាន ដែលក្រុមគោលដៅយល់ឃើញថាពួកគាត់មិនទាន់ទទួលបានសមស្រប និងគួរតែទទួលបានសិទ្ធិអំណាចមួយនេះសម្រាប់ការដឹកនាំនៅមូលដ្ឋាន។

ដោយសារឥទ្ធិពលនៃកត្តានយោបាយបានគ្របដណ្តប់លើការដឹកនាំ និងសម្រេចចិត្តនៅមូលដ្ឋាន ក្រុមគោលដៅដែលភាគច្រើនគឺជាសមាជិកក្រុមប្រឹក្សាក្រុង ស្រុក បានលើកឡើងថាសិទ្ធិអំណាចក្នុងការដឹកនាំ និងសម្រេចចិត្តត្រូវបានកាត់បន្ថយ ឬរារាំងដោយមានការជ្រៀតជ្រែកពីក្រុម ឬបុគ្គលដែលមានសិទ្ធិអំណាចផ្នែកនយោបាយខ្លាំងជាងនៅមូលដ្ឋាន។

ការណ៍ដែល *"សិទ្ធិអំណាចរបស់ក្រុមប្រឹក្សានៅរដ្ឋបាលស្រុក និងនៅក្នុងគណបក្សមានភាពមិនស្របគ្នា បានជះឥទ្ធិពលដោយប្រយោលទៅលើការដឹកនាំ និងការសម្រេចចិត្តនៅមូលដ្ឋាន"។ (សមាជិកក្រុមប្រឹក្សាក្រុង ស្រុក)*។

ផ្អែកតាមការលើកឡើងនេះ យើងអាចសង្កេតឃើញថាក្នុងនាមក្រុមប្រឹក្សាដែលមានតួនាទីតាមដានការអនុវត្តការងាររបស់គណៈអភិបាល អាចនឹងមានការលំបាកក្នុងការណែនាំ និងកែតម្រូវការអនុវត្តការងាររបស់បុគ្គលិករបស់ខ្លួន ប្រសិនបើក្រុមប្រឹក្សាផ្ទាល់មិនទទួលបានសិទ្ធិអំណាចពេញលេញតាមច្បាប់កំណត់។ ជារួម ដើម្បីឱ្យការដឹកនាំនៅរដ្ឋបាលថ្នាក់ក្រោមជាតិអាចប្រព្រឹត្តទៅបានរលូន និងមានប្រសិទ្ធភាពខ្ពស់ ក្រុមប្រឹក្សាត្រូវការសិទ្ធិអំណាចពេញលេញ និងជាក់លាក់ ដើម្បីធានាដល់ដំណើរការនៃការបំពេញការងារក្នុងនាមជាអ្នកតំណាងប្រជាពលរដ្ឋ និងឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

ក្រៅពីបញ្ហាប្រឈមនៃប្រព័ន្ធនយោបាយ មានការលើកឡើងអំពីកង្វះការយល់ដឹងក្នុងការប្រើប្រាស់សិទ្ធិអំណាចរបស់សមាជិកក្រុមប្រឹក្សាចំនួន១៣លើក ស្មើនឹង៣០%។ ចំណុចសំខាន់មួយទៀតដែលទទួលបានពីការសម្ភាស គឺទាក់ទងនឹងបញ្ហានៃការមិនយល់ដឹងគ្រប់គ្រាន់ទាក់ទងនឹងការអនុវត្តសិទ្ធិអំណាចត្រឹមត្រូវដែលច្បាប់បានផ្តល់ជូនដល់សមាជិកក្រុមប្រឹក្សា។

*"តួអង្គនៃក្រុមប្រឹក្សានៅមានកម្រិតក្នុងការអនុវត្តតួនាទី ភារកិច្ច និងសិទ្ធិអំណាចរបស់ខ្លួន [...]"។ (សមាជិកក្រុមប្រឹក្សាក្រុង ស្រុក)។*

*"ក្រុមប្រឹក្សារាជធានី ខេត្តមិនទាន់ប្រើប្រាស់ឥទ្ធិពលក្នុងច្បាប់របស់គាត់អស់នៅឡើយទេការពិតទៅ។" (អភិបាលរងខេត្ត)។*

ស្របពេលដែលច្បាប់បានប្រគល់ជូនសមាជិកក្រុមប្រឹក្សានូវអំណាចជាក់លាក់ សមាជិកក្រុមប្រឹក្សាមួយចំនួននៅមិនទាន់យល់ច្បាស់អំពីរបៀបប្រើប្រាស់សិទ្ធិអំណាចទាំងនោះឱ្យបានត្រឹមត្រូវនៅក្នុងការបំពេញតួនាទីនៅឡើយ។

*"សិទ្ធិអំណាចគាត់មាន ប៉ុន្តែគាត់មិនបានយល់ដឹងគ្រប់ជ្រុងជ្រោយក្នុងការប្រើប្រាស់ឱ្យបានសមស្រប និងតាមតម្រូវការ"។ (អភិបាលក្រុង ស្រុក)។*

ក្រុមគោលដៅដែលភាគច្រើនជាគណៈអភិបាលបានលើកឡើងថា ឥទ្ធិពលនយាបាយមិនមែនជាកត្តាដែលនាំឱ្យមានការកាត់បន្ថយ សិទ្ធិអំណាចរបស់ក្រុមប្រឹក្សាទេ តែការមិនយល់ដឹងពីការប្រើប្រាស់សិទ្ធិអំណាចរបស់ខ្លួនជាក្រុមប្រឹក្សាទៅវិញទេ ដែលធ្វើឱ្យពួកគាត់មិនអាចប្រើប្រាស់សិទ្ធិអំណាចបានពេញលេញ។

*"ខ្ញុំតែងតែបាននិយាយ និងលើកក្នុងអង្គប្រជុំពាក់ព័ន្ធនឹងការបញ្ចូលផែនការរបស់ក្រុមប្រឹក្សាដែលចង់ផ្តួចផ្តើមធ្វើទៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ឱ្យគាត់ជាប្រធាន និងសមាជិកលើកឡើងក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សារបស់គាត់។ ប៉ុន្តែជារាល់ដង គឺគាត់មិនដែលបានលើកដើម្បីស្នើបញ្ចូល រួចគាត់មកនិយាយថា គណៈអភិបាលមិនបានបញ្ចូលសកម្មភាពដែលគាត់បាននិយាយ។ ជារួម ក្រុមប្រឹក្សាគួរសិក្សាបន្ថែមពីសិទ្ធិអំណាច និងតួនាទីរបស់ខ្លួនបន្ថែម ព្រោះសម្រាប់ខ្ញុំជាគណៈអភិបាលគឺចាំតែអនុវត្តតាមការអនុម័តរបស់ក្រុមប្រឹក្សានិងស្តាប់ការណែនាំ តែសូមឱ្យត្រូវតាមច្បាប់។" (អភិបាលក្រុង ស្រុក)។*

*"ក្រុមប្រឹក្សាមានអំណាចរបស់គាត់ ប៉ុន្តែគាត់មិនដឹងយល់ និងចាំតែថ្នាក់លើបញ្ជា។ ជាក់ស្តែង តាមការសង្កេត៤អាណត្តិមកនេះ ការងារគាត់អាចវាយតម្លៃបាន៥០/៥០ ក្រុមគាត់យល់ដឹងច្រើនរឿង ប៉ុន្តែខ្វះការអនុវត្តបន្ថែម និងការចរចាគ្នា។" (អភិបាលក្រុង ស្រុក)។*

ចំណុចនេះបានបង្ហាញឱ្យឃើញពីការយល់ឃើញផ្សេងគ្នារវាងទស្សនៈរបស់ក្រុមប្រឹក្សា និងគណៈអភិបាលទៅលើការដឹកនាំ និងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ ការមានទស្សនៈមិនស្របគ្នារវាងថ្នាក់ដឹកនាំនៅមូលដ្ឋានបែបនេះក៏អាចបង្ហាញឱ្យឃើញថា ការអនុវត្តការងាររបស់បុគ្គលិកនៅរដ្ឋបាលថ្នាក់ក្រោមជាតិ នៅមិនទាន់ស្រុះស្រួលគ្នានៅឡើយ។ ដោយឡែក ផ្អែកតាមការអង្កេតផ្ទាល់ពីការបកស្រាយនូវសំណួរពីក្រុមគោលដៅដែលជាក្រុមប្រឹក្សាបានបង្ហាញពីភាពខ្វះចន្លោះ និងការយល់ដឹងពីសិទ្ធិអំណាចរបស់ខ្លួនក្នុងនាមជាក្រុមប្រឹក្សា ដែលការណ៍នេះស្របទៅនឹងការលើកឡើងរបស់ក្រុមគោលដៅជាគណៈអភិបាល។

ការលើកឡើងចំនួន១១លើកផ្សេងទៀត ស្មើនឹង២១% ពាក់ព័ន្ធនឹងកង្វះសិទ្ធិអំណាចរបស់ក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តតួនាទីរបស់ខ្លួន។ សមាជិកក្រុមប្រឹក្សាបានបង្ហាញពីបញ្ហាប្រឈមក្នុងការតាមដានការអនុវត្តការងាររបស់គណៈអភិបាលដោយសារមូលហេតុនៃការខ្វះខាតសិទ្ធិអំណាចក្នុងការតាក់តែង និងរៀបចំគោលនយោបាយនៅមូលដ្ឋាន។

*"កាលណាអំណាចខាងបញ្ញត្តិមិនមាន សិទ្ធអំណាចខាងនយោបាយមិនគ្រប់គ្រាន់ វាធ្វើឱ្យអំណាចក្នុងការតាក់តែងគោលនយោបាយ ឬការតាមដានការអនុវត្តការងារមិនអាចធ្វើទៅបានរលូន ឬមានសម្ពាធក្នុងការអនុវត្តការងារ។" (សមាជិកក្រុមប្រឹក្សាខេត្ត)។*

ក្រុមគោលដៅបានអះអាងថាសព្វថ្ងៃនេះក្រុមប្រឹក្សាមានការលំបាកក្នុងការណែនាំ និងកែតម្រូវការអនុវត្តរបស់គណៈអភិបាល ដោយសារគណៈអភិបាលមិនសូវយកចិត្តទុកដាក់ និងធ្វើការជ្រៀតជ្រែកច្រើនក្នុងកិច្ចការសម្រេចរបស់ក្រុមប្រឹក្សា។

*"ក្រុមប្រឹក្សាមិនសូវមានសិទ្ធិអំណាចពេញលេញក្នុងការសម្រេច ដោយមានការជ្រៀតជ្រែកពីគណៈអភិបាល និងអ្នកពាក់ព័ន្ធ។" (សមាជិកក្រុមប្រឹក្សាខេត្ត)។*

*"ដោយសារមិនទទួលបានការគាំទ្រពេញលេញពីអង្គភាពអនុវត្ត ការដាក់ចេញនូវដីកានានាមិនអាចធ្វើទៅបាន ឬដាក់ចេញហើយមិនអាចអនុវត្តបាន។" (ប្រធានក្រុមប្រឹក្សាក្រុង ស្រុក)។*

លទ្ធផលខាងលើបង្ហាញថា ក្រុមគោលដៅភាគច្រើនចាត់ទុកឥទ្ធិពលនយោបាយមានសារៈសំខាន់ដោយសារអាចផ្តល់សិទ្ធិអំណាចយ៉ាងទូលំទូលាយក្នុងការដឹកនាំ និងអនុវត្តការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ ការផ្តោតសំខាន់របស់ក្រុមគោលដៅទៅលើបញ្ហានៃកត្តានយោបាយនេះ បានបង្ហាញឱ្យឃើញថាក្រុមប្រឹក្សាដែលកំពុងបម្រើការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបានកើតចេញពីការបោះឆ្នោតជ្រើសរើសដោយប្រជាពលរដ្ឋ និងអ្នកតំណាងប្រជាពលរដ្ឋពិតជាត្រូវការចាំបាច់នូវសិទ្ធិអំណាចខាងនយោបាយដែលដើរតួសំខាន់ក្នុងការផ្សារភ្ជាប់ជាមួយនឹងគោលនយោបាយ ផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលនៅមូលដ្ឋាន។ ដូចនេះ ការពុំមានតុល្យភាពរវាងអំណាចនៃការដឹកនាំក្នុងគណបក្សនយោបាយ និងការដឹកនាំនៅរដ្ឋបាលថ្នាក់ក្រោមជាតិ បានជះឥទ្ធិពលដោយផ្ទាល់ដល់សមត្ថភាពរបស់ក្រុមប្រឹក្សាក្នុងការអនុវត្តការសម្រេចចិត្ត និងការគ្រប់គ្រងការងារនៅមូលដ្ឋាន។ ជាមួយគ្នានេះ ភាពមិនច្បាស់លាស់នៃការបែងចែកតួនាទី ភារកិច្ច និងការជ្រៀតជ្រែកពីផ្នែកនយោបាយលើការសម្រេចចិត្ត និងការអភិវឌ្ឍនៅមូលដ្ឋាននាំឱ្យមានការកាត់បន្ថយសិទ្ធិខាងបញ្ញត្តិ និងខាងប្រតិបត្តិរបស់ក្រុមប្រឹក្សា ដោយសារវិវាទនៃការបម្រើផលប្រយោជន៍ដល់គណបក្ស និងការបម្រើផលប្រយោជន៍ជូនប្រជាពលរដ្ឋ ដែលត្រូវបានលំអៀងទៅខាងគណបក្សនយោបាយ ដោយសារសមាជិកក្រុមប្រឹក្សាត្រូវផ្តោតលើទំនួលខុសត្រូវចំពោះអង្គភាពនយោបាយច្រើនជាងជាមួយប្រជាពលរដ្ឋ ដើម្បីរក្សាតួនាទី និងតំណែងរបស់ខ្លួនក្នុងការឈរឈ្មោះបោះឆ្នោតនាពេលអនាគត។

ជារួម ក្រុមគោលដៅបានបង្ហាញនូវការគាំទ្រចំពោះ ការសន្មតទី១ដែលបានលើកឡើងថាឥទ្ធិពលផ្នែកនយោបាយ និងកង្វះសិទ្ធិអំណាចដឹកនាំនៅមូលដ្ឋាន បានកាត់បន្ថយអំណាចខាងបញ្ញត្តិ និងអំណាចខាងប្រតិបត្តិរបស់ក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

បន្ថែមពីការសន្មតខាងលើ ចំណុចសំខាន់មួយចំនួនទៀតដែលត្រូវបានរកឃើញពីការសម្ភាស គឺកង្វះការយល់ដឹងអំពីសិទ្ធិអំណាចតាមផ្លូវច្បាប់របស់ក្រុមប្រឹក្សា ក៏ជាបញ្ហាចម្បងដូចគ្នា។ បើទោះបីជាមានសិទ្ធិអំណាចតាមច្បាប់ក៏ដោយ សមាជិកក្រុមប្រឹក្សាជាច្រើននៅមិនទាន់អាចអនុវត្តសិទ្ធិអំណាចរបស់ខ្លួនប្រកបដោយប្រសិទ្ធភាពនៅឡើយ ដោយសារការយល់ដឹងអំពីក្របខ័ណ្ឌច្បាប់នៅមានកម្រិត នាំឱ្យក្រុមប្រឹក្សាប្រើប្រាស់ឥទ្ធិពលរបស់ខ្លួនមិនបានពេញលេញនៅក្នុងដំណើរការធ្វើការសម្រេចចិត្ត និងរាំងសមត្ថភាពរបស់ខ្លួនក្នុងការតស៊ូមតិសម្រាប់ការចាត់អាទិភាពនៃការអភិវឌ្ឍនៅមូលដ្ឋាន។ ជាងនេះទៅទៀតស្របពេលដែលច្បាប់បានផ្តល់សិទ្ធិអំណាចគ្រប់គ្រាន់ដល់ក្រុមប្រឹក្សាដើម្បីធ្វើការដាក់ចេញដីកា និងលិខិតបទដ្ឋាននានា ក៏ដូចជាផ្តួចផ្តើមរៀបចំផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ក៏បច្ចុប្បន្នក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិនៅមិនទាន់អាចប្រើប្រាស់សិទ្ធិអំណាចទាំងនេះប្រកបដោយប្រសិទ្ធភាពនៅឡើយទេ។

*ការសន្មតទី២៖ "ការផ្ទេរមុខងារការហិរញ្ញវត្ថុមានកំណត់របស់រាជរដ្ឋាភិបាលបានរាំង ឬបង្អាក់ការផ្តួចផ្តើម និងការដាក់ចេញគោលនយោបាយរបស់ក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិ។"*

ផ្អែកតាមលទ្ធផលក្នុងតារាងទី៣ (ឧបសម្ព័ន្ធ ក) ក្នុងចំណោមក្រុមគោលដៅសម្ភាសន៍ទាំង ៤៣ លើក មានការលើកឡើងដូចគ្នាពាក់ព័ន្ធនឹងភាពខ្វះខាតនៃថវិកាសម្រាប់ការអនុវត្តការងារ ដែលទទួលបានពីការវិភាជន៍ថវិកាពីរដ្ឋបាលថ្នាក់ជាតិ ចំនួន២៨លើក ស្មើនឹង៦៥%។ ក្រុមគោលដៅបានលើកឡើងពីបញ្ហាពាក់ព័ន្ធនឹងការបែងចែកថវិកាពីរដ្ឋបាលថ្នាក់ជាតិ ដោយមតិភាគច្រើនយល់ស្របថាថវិកាដែលទទួលបានពីថ្នាក់ជាតិនៅមានកម្រិតទាបដែលធ្វើឱ្យក្រុមប្រឹក្សា និងអាជ្ញាធរមូលដ្ឋានពិបាកក្នុងការអនុវត្តផែនការនានាទៅតាមចក្ខុវិស័យដែលបានកំណត់។

> *"ថវិកាដែលបានវិភាជន៍ពីថ្នាក់ជាតិនៅមិនទាន់គ្រប់គ្រាន់ទេ គឺនៅតិចនៅឡើយបើយើងក្រលេកមើលទៅផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលនៅឃុំ ពោលគឺកញ្ចប់ថវិកានៅតិចមិនអាចប្រើប្រាស់ស្របតាមតម្រូវការនៅឡើយទេ"។ (អភិបាលក្រុង ស្រុក)។*

អ្នកចូលរួមក្នុងការសម្ភាសបានបញ្ជាក់ថា នៅក្នុងករណីមិនមានកញ្ចប់ថវិកាគ្រប់គ្រាន់ និងអាចទាញយកប្រើប្រាស់បាន ក្រុមប្រឹក្សាមិនអាចធ្វើការរៀបចំ និងដាក់ចេញនូវដីកា ឬគម្រោងធ្វើអ្វីមួយដើម្បីឆ្លើយតបទៅនឹងតម្រូវការប្រជាពលរដ្ឋនៅមូលដ្ឋានបានជាក់ស្តែងឡើយ។

> *"ក្នុងការដាក់ចេញរាល់ដីកាក៏ត្រូវមានកញ្ចប់ថវិកាសម្រាប់គ្រោងទុក បន្ទាប់ពីចេញដីកាសម្រាប់ប្រើប្រាស់តាមសេចក្តីត្រូវការដូចដែលបានកំណត់នៅក្នុងដីកាជាហេតុធ្វើឱ្យដីកាខ្លះបានប្រជុំពិភាក្សាតែពុំបានដាក់ចេញដីកា គឺរង់ចាំទទួលបានកញ្ចប់ថវិកា។ ថវិកាដែលទទួល*

*បានពីរដ្ឋាភិបាលគឺប្រើប្រាស់មិនគ្រប់គ្រាន់នោះទេសម្រាប់យកមកអនុវត្តនៅថ្នាក់ស្រុកក្នុងពេលបច្ចុប្បន្ន" ។ (សមាជិកក្រុមប្រឹក្សាក្រុង ស្រុក)។*

ក្រុមគោលដៅបានបញ្ជាក់បន្ថែមថា ដោយតម្រូវការនៅមូលដ្ឋានមានចំនួនច្រើន ហើយថវិកាដែលបានផ្ទេរមករដ្ឋបាលថ្នាក់ក្រោមជាតិមានចំនួនកំណត់ ក្រុមប្រឹក្សាពុំមានលទ្ធភាពក្នុងការគិតគូរ រៀបចំ ឬដាក់ចេញដីកាដែលមានលក្ខណៈបទបញ្ជាទូទៅអ្វីបន្ថែម ក្រៅតែពីអនុវត្តនូវផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ហើយបើទោះបីជាបានរៀបចំ និងដាក់ចេញក៏មិនអាចអនុវត្តបានដែរ ដោយសារពុំមានកញ្ចប់ថវិកាគាំទ្រ ពីព្រោះកញ្ចប់ថវិកាសព្វថ្ងៃសម្រាប់តែអនុវត្តផែនការប្រចាំឆ្នាំ និងមិនទាន់គ្រប់គ្រាន់នៅឡើយ។ ទោះជាយ៉ាងនេះក្តី ការលើកឡើងនេះមិនត្រឹមត្រូវទាំងស្រុងឡើយ ដោយសារការរៀបចំដីកា និងឬលិខិតបទដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិភាគច្រើន គឺក្នុងគោលដៅជំរុញ និងអនុវត្តផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗឱ្យកាន់តែមានប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងបរិយាបន្ន។

*"ដើម្បីឱ្យការគ្រប់គ្រងលើកិច្ចការ មុខងារ ការបម្រើប្រជាពលរដ្ឋ នឹងអាចសម្រេចសមិទ្ធផលទៅបានទាល់តែមានការផ្តួចផ្តើមនូវគំនិត គោលដៅ និងចក្ខុវិស័យ បន្ទាប់មកគឺរៀបចំដីកា និងសេចក្តីសម្រេច ហើយក្នុងការអនុវត្តសេចក្តីសម្រេច និងដីកាគឺមានការចំណាយជាកញ្ចប់ថវិកាទើបអាចលេចឡើងជារូបរាង និងសមិទ្ធផល ប៉ុន្តែបើមិនមានថវិកាផងតើឱ្យក្រុមប្រឹក្សា និងគណៈអភិបាលដាក់ចេញដីកាដោយរបៀបណា។" (ប្រធានក្រុមប្រឹក្សាស្រុក)។*

*"បញ្ហាដែលមិនមានការដាក់ចេញដីកា គឺដោយសារតែថវិកានៅក្នុងឃុំនៅមានកម្រិតតិចតួចនៅឡើយក្នុងការប្រើប្រាស់ គឺមិនទាន់គ្រប់ជ្រុងជ្រោយទៅតាមតម្រូវការរបស់ប្រជាពលរដ្ឋនោះទេ ជាហេតុធ្វើឱ្យការដាក់ចេញនៅដីកាបានចំនួនតិចតួច ហើយដីកាខ្លះបានត្រឹមតែមានផែនការ ប៉ុន្តែមិនទាន់បានដាក់ចេញ។" (មេឃុំ)។*

ជាមួយគ្នានេះ ក្រុមគោលដៅមួយចំនួនក៏បានបង្ហាញ ពីឆន្ទៈក្នុងការបម្រើការងារជូនប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន ក៏ប៉ុន្តែដោយសារតម្រូវការរបស់ប្រជាពលរដ្ឋ មានច្រើន តែតុល្យភាពនៃថវិកានឹងតម្រូវការមិនសមស្របនាំឱ្យក្រុមប្រឹក្សាមិនអាចបំពេញការងារបាន ពេញលេញតាមសេចក្តីត្រូវការនៅមូលដ្ឋានបានឡើយ។

*"ទាក់ទងជាមួយនឹងឆន្ទៈរបស់សមាជិកក្រុមប្រឹក្សាឃុំនីមួយៗ គឺមានឆន្ទៈនៅក្នុងការជួយសម្របសម្រួលក្នុងការជួយអភិវឌ្ឍន៍ភូមិឃុំជូនប្រជាពលរដ្ឋដោយសេចក្តីស្រឡាញ់ដូចជាឪពុក ម្តាយ និងកូនអញ្ចឹង ក៏ប៉ុន្តែបញ្ហាដែលតែងតែជួបប្រទះនោះគឺទាក់ទងជាមួយបញ្ហាហិរញ្ញវត្ថុមិនអាចប្រើប្រាស់បានជិតដល់ជូនប្រជាពលរដ្ឋ។" (សមាជិកក្រុមប្រឹក្សាឃុំ)។*

ក្រៅពីបញ្ហានៃការខ្វះខាតថវិកា ក្រុមការងារបានកត់សំគាល់ នូវចំណុចមិនប្រក្រតីនៃនីតិវិធីនៃការគ្រោងនិងប្រើប្រាស់មូលនិធិរបស់ឃុំ សង្កាត់ដែលត្រូវបានលើកឡើងថាត្រូវស្នើសុំការអនុញ្ញាត និងឯកភាពពីរដ្ឋបាលស្រុក និងខេត្តដែលផ្ទុយពីនីតិវិធីនៃការគ្រោង និងប្រើប្រាស់មូលនិធិឃុំ សង្កាត់។

*"កញ្ចប់ថវិកាពីរាជរដ្ឋាភិបាលបច្ចុប្បន្ននេះគឺមិនអាចប្រើប្រាស់បានតាមតម្រូវការឬក៏សេចក្តីត្រូវការរបស់ប្រជាពលរដ្ឋភ្លាមៗនោះទេគឺត្រូវមានការស្នើសុំអំពីខាងស្រុក ឬខេត្តជាមុនសិន។ មួយវិញទៀត ថវិកាដែលក្រុមប្រឹក្សាឃុំទទួលបានបច្ចុប្បន្ននេះគឺបានតែចំនួនតួលេខតែប៉ុណ្ណោះ។ ប៉ុន្តែថវិកាដែលគ្រប់គ្រងពិតប្រាកដគឺខាងខេត្ត និងស្រុក។" (មេឃុំ)។*

ឆ្លើយតបនឹងបញ្ហានេះ មានការលើកឡើងពីការចង់បានកញ្ចប់ថវិកាដាច់ដោយឡែកសម្រាប់ ការដាក់ចេញដីកា និងសេចក្តីសម្រេចនានាចំនួន១៩លើក ស្មើនឹង៤៤%។ ក្រុមគោលដៅជាសមាជិកក្រុមប្រឹក្សា បានស្នើសុំឱ្យរដ្ឋបាលថ្នាក់ជាតិ ពិចារណាក្នុងការបែងចែកកញ្ចប់ថវិកាដាច់ដោយឡែកមួយកញ្ចប់ទៀត សម្រាប់តែក្រុមប្រឹក្សាប្រើប្រាស់ ក្នុងការផ្តួចផ្តើមរៀបចំ និងដាក់ចេញនូវដីកា និងសកម្មភាពនានាក្នុងការចុះបេសកកម្មនៅមូលដ្ឋានដើម្បីបម្រើដល់សកម្មភាពក្នុងការរៀបចំគោលនយោបាយនៅមូលដ្ឋាន។

*"កញ្ចប់ថវិកាប្រើបច្ចុប្បន្ននៅមិនគ្រប់ជ្រុងជ្រោយ នៅតែមានការខ្វះខាតប្រសិនបើមានកញ្ចប់ថវិកាសម្រាប់ដាក់ចេញដីកាគឺកាន់តែប្រសើរ។" (សមាជិកក្រុមប្រឹក្សា ក្រុង ស្រុក)។*

*"ថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ គឺរៀបចំមិនទាន់បានច្បាស់លាស់ ទៅលើចំណាយផ្សេងៗ បញ្ហាថវិកាមិនគ្រប់គ្រាន់ បណ្តាលឱ្យពិបាកចេញដីកាផ្សេងៗ ក្រុមប្រឹក្សាបានសូមឱ្យមានកញ្ចប់ថវិកាក្រុមប្រឹក្សាដោយឡែក ដើម្បីឱ្យក្រុមប្រឹក្សានៅថ្នាក់មូលដ្ឋាន ថ្នាក់ស្រុក មានកញ្ចប់សម្រាប់រៀបចំឱ្យដំណើរការអ្វីដែលបានដាក់ចេញឱ្យទៅរលូន។" (សមាជិកក្រុមប្រឹក្សាក្រុង ស្រុក)។*

ការស្នើសុំនេះ លើកឡើងដោយសារ មូលហេតុនៃការខ្វះលទ្ធភាព របស់ក្រុមប្រឹក្សាផ្ទាល់ក្នុងការចាត់ចែងថវិកាប្រចាំឆ្នាំ ដើម្បីអនុវត្តមុខងាររបស់ខ្លួន។

*"ស្នើសុំឱ្យមានកញ្ចប់ថវិកាពីថ្នាក់លើដើម្បីទុកសម្រាប់ដាក់ចេញនូវដីកានានាពីព្រោះថវិកាបច្ចុប្បន្ននេះគឺមិនអាចប្រើប្រាស់បានគ្រប់ជ្រុងជ្រោយ និងតាមតម្រូវការនោះទេ។" (សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់)។*

ជាទូទៅ គ្រប់ក្រុមគោលដៅដែលជាសមាជិកក្រុមប្រឹក្សាបានលើកឡើងស្រដៀងគ្នាពីកញ្ចប់ថវិកានៅមានកម្រិតខ្លាំងក្នុងការគាំទ្រដល់សកម្មភាពរបស់ក្រុមប្រឹក្សាក្នុងការចុះត្រួតពិនិត្យការងារនៅមូលដ្ឋាន និងស្វែងយល់បន្ថែមពីតម្រូវការរបស់ប្រជាពលរដ្ឋដើម្បីមានលទ្ធភាពក្នុងការពិនិត្យ និងរៀបចំតាក់តែងដីកាមួយដែលមានផែនការច្បាស់លាស់ និងឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋប្រកដោយប្រសិទ្ធភាព។

*"ខាងឃុំ នៅមិនមានជាកញ្ចប់ថវិកាគ្រប់គ្រាន់ ក៏ដូចជាថវិកាសម្រាប់ត្រៀមទុកសម្រាប់ចេញដីកា។ រាល់ការចេញនូវដីកានីមួយៗគឺ ត្រូវតែប្រើទៅការចំណាយនៅកញ្ចប់ថវិកា។ ដូច្នេះនៅពេលដែលពុំមានកញ្ចប់ថវិកាសម្រាប់គ្រោងចេញដីកាគឺមិនអាចដាក់ចេញបានឡើយ។" (សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់)។*

ក្រៅពីនេះការលើកឡើងចំនួន៣៤លើកផ្សេងទៀត ស្មើនឹង៧៩% ពាក់ព័ន្ធនឹងបញ្ហាលំបាកក្នុងការកៀរគរថវិកា សម្រាប់ការអភិវឌ្ឍដោយសារមិនមានប្រភពចំណូលពីមូលដ្ឋានផ្ទាល់ដោយពឹងផ្អែកសំខាន់តែទៅលើប្រភពចំណូលពីថ្នាក់ជាតិ។

*"ក្រៅពីថវិកាដែលវិភាជន៍រដ្ឋបាលថ្នាក់ជាតិ រដ្ឋបាលខេត្តមិនមានចំណូលអ្វីជាដុំកំភួនឡើយ។ មានតែចំណូលពីការិយាល័យច្រក តែខេត្តយើងប្រជាជនតិចអញ្ចឹង ចំណូលពីសេវាក៏បានតិចនឹងមិនបានជួយអ្វីដល់ការអភិវឌ្ឍច្រើនឡើយ។ ខេត្តយើងមានព្រំប្រទល់ជាប់ប្រទេសជិតខាងចំនួនពីរ តែយើងមិនមានច្រកព្រំដែនអន្តរជាតិទេ ខ្ញុំក៏ពុំដឹងថាមកពីមូលហេតុអ្វីបានជារាជរដ្ឋាភិបាលមិនសម្រេចឱ្យមានច្រកព្រំដែនអន្តរជាតិនៅទីនេះ។ ប្រសិនបើមានច្រកយើងនឹងមានចំណូលបន្ថែមសម្រាប់ការងារអភិវឌ្ឍន៍ ដោយមិនចាំបាច់រង់ចាំតែថវិកាពីថ្នាក់ជាតិទាំងស្រុង។" (សមាជិកក្រុមប្រឹក្សាខេត្ត)។*

ការគ្មានប្រភពចំណូលផ្ទាល់ពីមូលដ្ឋាន ក៏ជាបញ្ហាដែលបានលើកឡើងច្រើនក្នុងការសម្ភាសពីក្រុមគោលដៅទាំងអស់។

*"មិនមានចំណូលថវិកានៅមូលដ្ឋានឡើយ បានខ្លះមកពីការិយាល័យច្រកតែនៅមានកម្រិតខ្លាំង ហើយបើសួរថាតើមានអ្វីផ្សេងទៀតអត់? ចម្លើយគឺអត់មានទេ។" (ប្រធានក្រុមប្រឹក្សាក្រុង ស្រុក)។*

មួយវិញទៀត ដោយសារអាជ្ញាធរមូលដ្ឋានត្រូវពឹងផ្អែកស្ទើរទាំងស្រុងទៅលើថវិកាពីថ្នាក់ជាតិធ្វើឱ្យការអនុវត្តការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិមិនអាចមានលទ្ធភាពក្នុងការអនុវត្តការងាររបស់ខ្លួនបានពេញលេញ។

*"យើងគ្មានប្រភពចំណូលផ្សេងទេ បានពីចំណូលច្រកចេញចូលបន្តិចបន្តួចតែប្រើបានតែសម្រាប់ជាប្រាក់លើកទឹកចិត្តមន្ត្រីតែប៉ុណ្ណោះ។ បើនិយាយពីរឿងពន្ធសឹងតែមិនមានអ្វីប្រមូលទៅហើយ ជារួមយើងពឹងផ្អែកស្ទើរទាំងស្រុងទៅលើថវិកាវិភាជន៍ពីថ្នាក់ជាតិ។" (ប្រធានក្រុមប្រឹក្សាក្រុង ស្រុក)។*

ក្រុមគោលដៅភាគច្រើនបានលើកឡើងពីការចង់បានប្រភពចំណូលបន្ថែមនៅមូលដ្ឋានផ្ទាល់ជាជាងរង់ចាំ និងពឹងផ្អែកទាំងស្រុងលើចំណូលពីថ្នាក់ជាតិ។ ការទទួលបានចំណូលបន្ថែមនៅមូលដ្ឋានផ្ទាល់ត្រូវបានយល់ស្រប និងគាំទ្រពីក្រុមគោលដៅថានឹងជួយជំរុញការអភិវឌ្ឍនៅមូលដ្ឋាន និងជំរុញការដាក់ចេញនូវដីកា ឬគោលនយោបាយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិផ្ទាល់តាមរយៈចំណូលដែលទទួលបានបន្ថែមនៅមូលដ្ឋាន។

*"សំណូមពរទៅកាន់រាជរដ្ឋាភិបាល គឺសំណូមពរឱ្យរាជរដ្ឋាភិបាលផ្តល់នូវប្រភពថវិកាបន្ថែមដល់ក្រុមប្រឹក្សាឃុំ ជាកញ្ចប់ថវិកាមួយដែលអាចឱ្យឃុំប្រើប្រាស់បានដោយផ្ទាល់ដោយពុំមានការគ្រប់គ្រងពីថ្នាក់មួយទៅថ្នាក់មួយជាហេតុធ្វើឱ្យមានការយឺតយ៉ាវក្នុងការប្រើប្រាស់កញ្ចប់ថវិកាជូនប្រជាពលរដ្ឋ។" (សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់)។*

ផ្អែកតាមលទ្ធផលខាងលើ ការវិភាជន៍ថវិកាដែលនៅមានកម្រិតពីថ្នាក់ជាតិមករដ្ឋបាលថ្នាក់ក្រោមជាតិ ពិតជាបានជះឥទ្ធិពលដល់ក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តមុខងារជាតំណាងប្រជាពលរដ្ឋនៅមូលដ្ឋាន ក៏ដូចជាការប្រើប្រាស់សិទ្ធិអំណាចបានពេញលេញតាមច្បាប់។ កង្វះថវិកាក្នុងការប្រើប្រាស់នៅមូលដ្ឋាន ត្រូវបានចាត់ទុកជាបញ្ហាយ៉ាងសំខាន់ដោយក្រុមគោលដៅថាបានរារាំង ឬបង្អាក់ដល់ការផ្តួចផ្តើមរៀបចំ និងដាក់ចេញនូវដីកា និងសេចក្តីសម្រេចនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ យោងតាមធនាគារអភិវឌ្ឍន៍អាស៊ី (២០១៨) រដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជាពឹងផ្អែកខ្លាំងទៅលើការផ្ទេរសិទ្ធិអំណាចពីរដ្ឋបាលថ្នាក់ជាតិ ក៏ដូចការវិភាជន៍ថវិកាដែលសព្វថ្ងៃនៅមានកម្រិត។ ភាពពឹងផ្អែកនិងខ្វះខាតនេះបានដាក់កម្រិតសមត្ថភាពក្នុងការផ្តល់មូលនិធិដល់គម្រោងក្នុងមូលដ្ឋាន និងការឆ្លើយតបទៅនឹងតម្រូវការសហគមន៍។ ក្នុងន័យនេះ លទ្ធភាពក្នុងការទទួលបានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ និងអាចព្យាករណ៍បានរួមទាំងប្រភពចំណូលផ្ទាល់ខ្លួន គឺជាកត្តាចំបាច់មួយដែលផ្តល់លទ្ធភាពដល់ក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការដាក់ចេញនូវដីកា និងអនុវត្តគោលនយោបាយនៅមូលដ្ឋានប្រកបដោយប្រសិទ្ធភាព។ យោងតាម Rubin & Willoughby (២០២៤) ថវិកាគឺជាឧបករណ៍សំខាន់សម្រាប់រដ្ឋាភិបាល ក្នុងការបង្កើត និងផ្លាស់ប្តូរគោលនយោបាយដែលយើងអាចសន្និដ្ឋានបានថាថវិកាពិតជាមានសារៈសំខាន់សម្រាប់ការផ្តួចផ្តើមរបស់ក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការដាក់ចេញគោលនយោបាយនៅមូលដ្ឋាន ក៏ដូចជាការអភិវឌ្ឍមូលដ្ឋានស្របតាមតម្រូវការរបស់ប្រជាពលរដ្ឋ។

ជាគោលការណ៍ ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវយកទៅប្រើប្រាស់លើចំណាយចរន្ត និងអនុវត្តមុខងារនានា ដែលមានកំណត់នៅក្នុងផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល។ ទោះជាយ៉ាងណា ក្រុមគោលដៅមួយចំនួនបានលើកឡើងថា គម្រោងថវិកាដែលចាំបាច់សម្រាប់ផ្តួចផ្តើមរៀបចំដីកា និងឬសេចក្តីសម្រេចនានា មានការលំបាកក្នុងការដាក់បញ្ចូលទៅក្នុងផែនការថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្នុងន័យនេះ ក្រុមគោលដៅជឿជាក់ថា ភាពបរាជ័យមានកម្រិតខ្ពស់ ពាក់ព័ន្ធការអនុវត្តនូវដីកា និងសេចក្តីសម្រេច បើទោះបីជាបានរៀបចំ ឬអនុម័តរួចហើយក៏ដោយ។ ផ្អែកតាមលទ្ធផលនិងការរំលឹកទ្រឹស្តី ការសន្មតទី២ ដែលលើកឡើងថា ការវិភាជន៍ថវិកាមានកំណត់របស់រាជរដ្ឋាភិបាលបានរារាំង ឬបង្អាក់ការផ្តួចផ្តើម និងការដាក់ចេញគោលនយោបាយរបស់ក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិពិតជាអាចបញ្ជាក់បាន។

ថ្វីដ្បិតថវិកាគាំទ្រពិតជាមានសារៈសំខាន់សម្រាប់ការគ្រោង និងអនុវត្តនូវការដាក់ចេញដីកា និងសេចក្តីសម្រេច ក៏ប៉ុន្តែបើយើងក្រឡេកមើលទៅលើនីតិវិធីនៃការរៀបចំ និងអនុម័តដីកា និងសេចក្តី សម្រេចនានា គឺពុំតម្រូវឱ្យមានការប្រើប្រាស់ថវិកាឡើយ ក្នុងនោះការដាក់ចេញឱ្យអនុវត្តនូវដីកាបទបញ្ជា ទូទៅមួយចំនួនក៏ពុំចាំបាច់មានថវិកាក្នុងការអនុវត្តដែរ។ ផ្អែកតាមការលើកឡើងនេះ យើងអាចធ្វើការកត់ សម្គាល់បានថា រដ្ឋបាលថ្នាក់ក្រោមជាតិពឹងផ្អែកលើសលប់ទៅលើថវិកាក្នុងការរៀបចំ និងអនុវត្តសកម្មភាព នានាដោយខ្វះខាតនូវការផ្តួចផ្តើមជាបុគ្គលនិងជាក្រុម ព្រមទាំងឆន្ទៈក្នុងការរៀបចំ និងអនុវត្តនូវការងារ មួយចំនួនដែលអាចសម្រេចបានត្រឹមកម្រិតនៃការយកចិត្តទុកដាក់ដោយមិនចាំបាច់ក្នុងការប្រើប្រាស់ថវិកាដែលអាចផ្តល់ផលប្រយោជន៍ដល់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

*ការសន្មតទី៣៖ "កង្វះចំណេះដឹង និងជំនាញក្នុងការរៀបចំគោលនយោបាយរបស់សមាជិកក្រុមប្រឹក្សា និងមន្ត្រីរាជការនៅរដ្ឋបាលថ្នាក់ក្រោមជាតិរាំងរាំងដល់ការផ្តួចផ្តើម និងដាក់ចេញគោលនយោបាយនៅមូលដ្ឋាន។"*

យោងតាមលទ្ធផលក្នុងតារាងទី៣ (ឧបសម្ព័ន្ធក) ក្នុងចំណោមការសម្ភាសជាមួយក្រុមគោលដៅទាំង៤៣លើក មានការលើកឡើងដូចគ្នាពាក់ព័ន្ធនឹងសមត្ថភាពនៅមានកម្រិតរបស់សមាជិកក្រុមប្រឹក្សា និងមន្ត្រីរាជការនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ចំនួន២២លើក ស្មើនឹង៥១%។ តាមរយៈលទ្ធផល នៃការសម្ភាសបានបង្ហាញថាសមត្ថភាពរបស់ក្រុមគោលដៅភាគច្រើនជាក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រុង ស្រុក ឃុំ សង្កាត់ នៅមានកម្រិតពាក់ព័ន្ធចំណេះដឹង និងជំនាញក្នុងការផ្តួចផ្តើមរៀបចំ និងដាក់ចេញនូវដីកា ឬគោលនយោបាយនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

*"ពាក់ព័ន្ធជាមួយការដាក់ចេញនៅដីកា ឬគោលនយោបាយរបស់ក្រុមប្រឹក្សាស្រុកដោយខ្លួនឯងនោះ គឺមិនទាន់មាននោះទេដោយសារតែមន្ត្រីនៅថ្នាក់ស្រុកនៅខ្វះការយល់ដឹង និងសមត្ថភាពនៅមានកម្រិត ដូច្នេះប្រសិនជាការដាក់ចេញគោលនយោបាយទៅបានត្រូវមានការណែនាំ ត្រួតពិនិត្យ និងបង្រៀននៅវគ្គសិក្សារយៈពេលខ្លីដល់មន្ត្រីទាំងអស់ឱ្យមានការយល់ដឹងជាងនេះ។"(អភិបាលក្រុង ស្រុក)។*

កង្វះបទពិសោធន៍នៃការរៀបចំការវិភាគតម្រូវការ និងតាក់តែងដីកាបានរាំងស្ទះដល់ការដាក់ចេញនូវដីកានៅមូលដ្ឋានដែលទទួលស្គាល់ដោយសមាជិកក្រុមប្រឹក្សាផ្ទាល់ ទាក់ទងនឹងការយល់ដឹងទៅលើបច្ចេកទេសនៃការរៀបចំការងារទាំងនេះ។

*"បញ្ហាប្រឈមដែលកំពុងកើតមានពេលនេះ គឺសមត្ថភាពរបស់មន្ត្រីរាជការនៅមានកម្រិតទាក់ទងទៅនឹងការយល់ដឹង សមត្ថភាព ជំនាញបច្ចេកទេស នៅក្នុងការចេញសេចក្តីសម្រេច ការយល់ដឹងអំពីលិខិតបទដ្ឋានគតិយុត្ត និងច្បាប់ពាក់ព័ន្ធផ្សេងៗនៅមានកម្រិតក្នុងការរៀបចំ ឬដាក់ចេញដីកា ឬសេចក្តីសម្រេចផ្សេងៗ។" (ប្រធានក្រុមប្រឹក្សាក្រុង ស្រុក)។*

*"សមត្ថភាពរបស់ពួកខ្ញុំនៅមានកម្រិត សមាជិកក្រុមប្រឹក្សាខ្លះគាត់មិនទាន់ទាំងយល់ដឹងពីការរៀបចំផែនការថវិកាផង គាត់មើលមិនយល់អ្វីជាអនុគណនី តែចេះតែលើកដៃអនុម័តដែរ។ ជារួម បើយើងជាអ្នកត្រួតពិនិត្យមិនមានចំណេះដឹងគ្រប់គ្រាន់ ធ្វើម៉េចអាចកែសម្រួលអ្នកអនុវត្តបាន។" (សមាជិកក្រុមប្រឹក្សាក្រុង ស្រុក)។*

ជាមួយគ្នានេះក្រុមគោលដៅជាអភិបាលក៏បានលើកឡើងស្រដៀងគ្នា ពាក់ព័ន្ធបទពិសោធន៍របស់ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិក្នុងការអនុវត្តការងាររបស់ខ្លួនពិតជានៅមានកម្រិតទាំងចំណេះដឹង និងបទពិសោធន៍។

*"សមត្ថភាពការអនុវត្តរបស់គាត់នៅមានកម្រិតទាក់ទងជាមួយបទពិសោធន៍ ការងាររបស់គាត់ ដូចនេះដើម្បីជួយឱ្យការអនុវត្តការងារកាន់តែល្អប្រសើរគឺស្នើសុំទៅថ្នាក់លើឱ្យមានការបើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីថ្នាក់ក្រោមបន្ថែម។" (អភិបាលរងខេត្ត)។*

ការលើកឡើងពាក់ព័ន្ធកង្វះការគាំទ្រការអភិវឌ្ឍសមត្ថភាពពីអង្គភាពសាមី និងអង្គភាព ពាក់ព័ន្ធទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវបានលើកឡើងចំនួន១៩លើក ស្មើនឹង៤៤%។ យោងតាម លទ្ធផលនៃការសម្ភាសផ្ទាល់បានបង្ហាញពីភាពស៊ីសង្វាក់គ្នានៃមូលហេតុដែលសមាជិកក្រុមប្រឹក្សា នៅពុំទាន់មានសមត្ថភាពគ្រប់គ្រាន់ ដោយកង្វះការគាំទ្រការអភិវឌ្ឍសមត្ថភាពពីរដ្ឋបាលសាមី និងពីរដ្ឋបាលថ្នាក់ជាតិ។

*"រដ្ឋបាលស្រុកពុំមានកញ្ចប់ថវិកាសម្រាប់រៀបចំវគ្គបណ្តុះបណ្តាលសម្រាប់មន្ត្រីទេ គឺពឹងផ្អែកលើការបណ្តុះបណ្តាលពីថ្នាក់ខេត្ត និងក្រសួងមហាផ្ទៃ។ ហើយវគ្គដែលទទួលបានក៏មិនច្រើនដែរក្នុងមួយឆ្នាំៗ និងចំនួនមន្ត្រីត្រូវចូលរួមមានកំណត់។" (អភិបាលក្រុង ស្រុក)។*

ជាមួយគ្នានេះ ការពង្រឹងសមត្ថភាពរបស់ក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិ ពាក់ព័ន្ធការងារបច្ចេកទេសចាំបាច់មួយចំនួនដែលច្បាប់បានប្រគល់ជូននៅមានកម្រិតខ្លាំង ក៏ដូចជាកង្វះឆន្ទៈក្នុងការធ្វើស្វ័យសិក្សាស្វែងយល់ផ្ទាល់ពីសមាជិកក្រុមប្រឹក្សាខ្លួនឯង ក្នុងការសិក្សាស្រាវជ្រាវពង្រឹងសមត្ថភាពផ្ទាល់ខ្លួនដោយពឹងផ្អែកទាំងស្រុងតែទៅលើការបណ្តុះបណ្តាលពីខាងក្រៅ។

*"បើនិយាយថាក្រុមប្រឹក្សាមានសមត្ថភាពគ្រប់គ្រាន់ គឺមិនអាចទេ យើងត្រូវការការអភិវឌ្ឍសមត្ថភាពបន្ថែមតាមរយៈការបណ្តុះបណ្តាលនានា។ តែជាក់ស្តែងក្រុមប្រឹក្សាមិនសូវទទួលបានឱកាសក្នុងការចូលរួមវគ្គបណ្តុះបណ្តាលឡើយ។" (ប្រធានក្រុមប្រឹក្សា ក្រុង ស្រុក)។*

ក្នុងនោះ ក្រុមប្រឹក្សា នៅរដ្ឋបាលថ្នាក់ក្រោមជាតិបានអះអាងថា គាត់មានការលំបាកក្នុងការទទួលបានវគ្គបណ្តុះបណ្តាលនានា ដែលជាទូទៅសមាជិកក្រុមប្រឹក្សាត្រូវបានមើលរំលង។

*"ក្រុមប្រឹក្សាពិបាកទទួលបានវគ្គបណ្តុះបណ្តាល ព្រោះតាំងពីខ្ញុំក្លាយជាក្រុមប្រឹក្សាមកខ្ញុំមិនទាន់បានទទួលវគ្គបណ្តុះបណ្តាលទេ។" (ប្រធានក្រុមប្រឹក្សាក្រុង ស្រុក)។*

*"វគ្គបណ្តុះបណ្តាលទទួលបានតែអ្នកថ្មី ប៉ុន្តែសម្រាប់អ្នកចាស់មិនសូវទទួលបានវគ្គបណ្តុះបណ្តាល។" (សមាជិកក្រុមប្រឹក្សាក្រុង ស្រុក)។*

ជាមួយគ្នានេះការលើកឡើងចំនួន២៨លើកផ្សេងទៀត ស្មើនឹង ៦៥% ពាក់ព័ន្ធនឹងសារៈសំខាន់នៃការទទួលបានវគ្គបណ្តុះបណ្តាល និងស្នើសុំឱ្យមានវគ្គបណ្តុះបណ្តាលបន្ថែម ដែលក្រុមគោលដៅ ជឿជាក់ថានឹងជំរុញការរៀបចំ និងការដាក់ចេញដីកា និងគោលនយោបាយនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ សមាជិកក្រុមប្រឹក្សាភាគច្រើន បានលើកឡើងថាពួកគាត់មិនសូវទទួលបានការបណ្តុះបណ្តាលឡើយនៅក្នុងអាណត្តិការងាររបស់ខ្លួន ជាហេតុធ្វើឱ្យពួកគាត់មិនសូវបានយល់ដឹងពី ការវិវត្តនូវការងារមួយចំនួន ឬនៅតែអនុវត្តតាមសម្មភាពដដែលៗ។

*"អត់ទាន់មានការបណ្ដុះបណ្ដាលបន្ថែមនោះទេ ខេត្តនៅតែព្រួយបារម្ភពីសមត្ថភាពរបស់ក្រុមប្រឹក្សា និងមន្ត្រីរដ្ឋបាលក្រុង ស្រុកនៅតែខ្វះខាតក្នុងការបំពេញការងារនៅឡើយ។ ការគាំទ្រការអភិវឌ្ឍសមត្ថភាពគឺសំខាន់ណាស់ បើខ្វះការគាំទ្រដូចសព្វថ្ងៃសមត្ថភាពមន្ត្រីយើងមិនងាយរីកចម្រើនទេ។" (អភិបាលរងខេត្ត)។*

*"រាជរដ្ឋាភិបាលគួរតែដាក់ចេញនូវវគ្គបណ្ដុះបណ្ដាលបន្ថែមដល់មន្ត្រីរាជការនៅថ្នាក់ក្រោមជាតិឱ្យមានការយល់ដឹងកាន់តែទូលំទូលាយទាក់ទងជាមួយនឹងរបៀប របបនៃការគ្រប់គ្រងរដ្ឋបាល ជំនាញបច្ចេកទេសច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ផ្សេងៗ ដើម្បីឱ្យពួកគាត់កាន់តែមានសមត្ថភាពបន្ថែមនៅក្នុងការបម្រើសេវាជូនសាធារណជនក៏ដូចជាការដាក់ចេញនូវដីកាឱ្យកាន់តែមានប្រសិទ្ធភាព និងត្រឹមត្រូវ។" (ក្រុមប្រឹក្សាឃុំ សង្កាត់)។*

ដើម្បីដោះស្រាយនូវបញ្ហាទាំងនេះ ក្រុមគោលដៅបានស្នើសុំឱ្យមានការគាំទ្របន្ថែមពីរដ្ឋបាលថ្នាក់ជាតិ និងភាគីពាក់ព័ន្ធទៅលើការផ្ដល់វគ្គ បណ្ដុះបណ្ដាលជំនាញដល់ក្រុមគោលដៅជាសមាជិកក្រុមប្រឹក្សាដើម្បីក្រុមប្រឹក្សាអាចមានលទ្ធភាព ក្នុងការអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួនកាន់តែមានប្រសិទ្ធភាព។

*"សំណូមពរឱ្យធ្វើការបណ្ដុះបណ្ដាលដល់ក្រុមប្រឹក្សា ពិសេសក្រុមប្រឹក្សាជំនាន់ក្រោយ ដើម្បីឱ្យពួកគាត់យល់ដឹងកាន់តែជ្រៅពីនយោបាយ ព្រោះក្រុមប្រឹក្សាធ្វើការងារច្រើនផ្នែកនយោបាយ ដូចនេះប្រព័ន្ធនយោបាយពិតជាសំខាន់មែនទែន។" (អភិបាលរងក្រុង ស្រុក)។*

ក្នុងនោះ ការរៀបចំឱ្យមានទស្សនកិច្ចសិក្សា នៅតាមបណ្ដាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ដើម្បីផ្លាស់ប្ដូរបទពិសោធន៍ និងទស្សនៈរវាង ក្រុមប្រឹក្សាដើម្បីស្វែងយល់ពីបញ្ហាប្រឈម និងដំណោះស្រាយទុកជាបទពិសោធន៍ ក្នុងការអនុវត្តនៅមូលដ្ឋានដែលក្រុមគោលដៅយល់ស្របថានឹងជួយពង្រឹងសមត្ថភាពរបស់ពួកគាត់បានច្រើនបើប្រៀបធៀបទៅនឹងការបណ្ដុះបណ្ដាលនៅក្នុងថ្នាក់រៀន។

*"ពួកយើងត្រូវការបណ្ដុះបណ្ដាលបន្ថែម ព្រោះបទពិសោធន៍ខុសគ្នា ប្រសិនបើមានវគ្គបណ្ដុះបណ្ដាលសមត្ថភាព ឬទស្សនកិច្ចសិក្សា ខ្ញុំគិតថាទៅថ្ងៃមុខពួកយើងជាក្រុមប្រឹក្សាអាចចេញដីកាបានច្រើន និងបង្កើនចំនួនច្រើនជាងមុន។" (សមាជិកក្រុមប្រឹក្សាក្រុង ស្រុក)។*

ក្នុងនោះ បញ្ហាបច្ចេកវិទ្យា ជំនាញក្នុងការវិភាគគោលនយោបាយ ត្រូវបានក្រុមគោលដៅលើកឡើងថាជាកត្តាមួយសំខាន់ ដែលគួរត្រូវបានយកចិត្តទុកដាក់ និងពង្រឹងបន្ថែមដល់ក្រុមប្រឹក្សា។

*"ត្រូវតែពង្រឹង និងបណ្ដុះបណ្ដាលបន្ថែមនូវបច្ចេកវិទ្យា និងការងារបច្ចេកទេស ដល់មន្ត្រីរដ្ឋបាលឃុំឱ្យមានការយល់ដឹងកាន់តែស៊ីជម្រៅ។ បើគ្មានចំណេះដឹង ក៏មិនអាចរៀបចំ និងដាក់ចេញដីកាបាន។"(ក្រុមប្រឹក្សាឃុំ សង្កាត់)។*

*"ជាការពិត សមត្ថភាពរបស់ក្រុមប្រឹក្សានៅមានកម្រិត។ វគ្គបណ្ដុះបណ្ដាលពិតជាសំខាន់ក្នុងការរៀបចំតាក់តែងដីកា ឬលិខិតបទដ្ឋានគតិយុត្តនានា។ រដ្ឋបាលគ្រប់លំដាប់ថ្នាក់គួរ*

*ពង្រឹងការបណ្តុះបណ្តាលជំនាញការវិភាគ ការរៀបចំគោលនយោបាយដល់ក្រុមប្រឹក្សា និងមន្ត្រីនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។" (សមាជិកក្រុមប្រឹក្សាក្រុង ស្រុក)*

លទ្ធផលស្រាវជ្រាវបានបង្ហាញថា សមាជិកក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិ នៅមានកម្រិតទាក់ទងនឹងសមត្ថភាពក្នុងការរៀបចំ និងដាក់ចេញនូវដីកា សេចក្តីសម្រេច ឬគោលនយោបាយនៅក្នុងមូលដ្ឋានរបស់ខ្លួន។ សមាជិកក្រុមប្រឹក្សាដែលភាគច្រើនជាអតីតមន្ត្រីរាជការដែលចូលនិវត្តន៍ ដែលបច្ចុប្បន្នទទួលបានតួនាទីក្នុងក្រុមប្រឹក្សា បានអះអាងថាមានការខ្វះខាតចំណេះដឹងអំពីការគ្រប់គ្រងរដ្ឋបាល និងការរៀបចំផែនការថវិកា ជាពិសេសចំណេះ និងជំនាញក្នុងការតាក់តែង រៀបចំ វិភាគ និងសរសេរគោលនយោបាយ ឬដីកានៅមូលដ្ឋាន។ កង្វះខាតចំណេះដឹង និងជំនាញទៅលើការអនុវត្តការងារស្នូលរបស់ក្រុមប្រឹក្សានេះ នឹងនាំឱ្យការអនុវត្តមុខងាររបស់ខ្លួននៅមូលដ្ឋានគ្មានប្រសិទ្ធភាព រាំងស្ទះដល់ការរៀបចំនិងអនុវត្តគោលនយោបាយ និងអាចនាំឱ្យការអនុវត្តកំណែទម្រង់នៅរដ្ឋបាលថ្នាក់ក្រោមជាតិមានភាពយឺតយ៉ាវនិងការមិនពេញចិត្តពីប្រជាពលរដ្ឋ។ ការសិក្សារបស់ Abdullah (2019) បានអះអាងថាក្រុមប្រឹក្សាមូលដ្ឋាន បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងដំណើរការបង្កើតគោលនយោបាយ ជាពិសេសក្នុងការកំណត់បញ្ហា ការកំណត់របៀបវារៈ ការរៀបចំគោលនយោបាយ និងការសម្រេចចិត្ត។ កត្តាសំខាន់ដូចជាលទ្ធភាពបច្ចេកទេស មតិយោបល់សាធារណៈ ការពិចារណាអំពីថវិកា និងការរួបរួមគ្នាត្រូវបានរកឃើញថា មានសារៈសំខាន់ក្នុងការបង្កើនប្រសិទ្ធភាពការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្នុងនោះ ចំណុចដែលគួរឱ្យកត់សម្គាល់ សមត្ថភាពរបស់ក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់ត្រូវបានរកឃើញថានៅមានកម្រិតខ្លាំងប្រៀបធៀបនឹងសមត្ថភាពរបស់ក្រុមប្រឹក្សាខេត្តពាក់ព័ន្ធចំណេះដឹង និងជំនាញក្នុងការផ្តួចផ្តើមរៀបចំ និងដាក់ចេញនូវដីកា និងគោលនយោបាយនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ ដោយផ្អែកតាម លទ្ធផលនិងការពិភាក្សានេះ ការសន្មតទី៣ ដែលថាកង្វះចំណេះដឹង និងជំនាញក្នុងការរៀបចំគោលនយោបាយរបស់សមាជិកក្រុមប្រឹក្សា និងមន្ត្រីរាជការនៅរដ្ឋបាលថ្នាក់ក្រោមជាតិរារាំងដល់ការផ្តួចផ្តើម រៀបចំនិងដាក់ចេញនូវគោលនយោបាយនៅមូលដ្ឋានត្រូវបានគាំទ្រតាមរយៈចម្លើយរបស់ក្រុមគោលដៅ។

ក្នុងនោះផងដែរ កត្តាសំខាន់ៗដែលត្រូវបានបង្ហាញក្នុងលទ្ធផលនៃការសម្ភាសក្រៅពីការសន្មតរដ្ឋបាលថ្នាក់ក្រោមជាតិបានអះអាងថា ការគាំទ្រក្នុងការពង្រឹងសមត្ថភាពដល់ក្រុមប្រឹក្សានៅមានភាពខ្វះចន្លោះ។ ភាពខ្វះចន្លោះក្នុងការគិតគូពីការរៀបចំ និងផ្តល់វគ្គបណ្តុះបណ្តាលពីរដ្ឋបាលថ្នាក់ជាតិ នាំឱ្យក្រុមប្រឹក្សាថ្នាក់ក្រោមជាតិមិនអាចអភិវឌ្ឍចំណេះដឹង និងជំនាញរបស់ខ្លួនឱ្យស្របទៅតាមតម្រូវការរបស់ប្រជាពលរដ្ឋ ក៏ដូចជាការវិវឌ្ឍរបស់ប្រទេសបាន។ ផ្ទុយពីអ្វីដែលបានលើកឡើងពីក្រុមគោលដៅ ក្រុមការងារបានសង្កេតឃើញថា ជាទូទៅក្រុមគោលដៅមិនបានបង្ហាញពីការខិតខំស្វ័យសិក្សា និងឬខិតខំផ្តួចផ្តើមដោយខ្លួនឯង ប៉ុន្តែបានបង្ហាញពីទំនោរក្នុងការពឹងផ្អែក និងការដាក់បន្ទុកទៅលើការខ្វះខាតនៃការគាំទ្រពីរដ្ឋបាលថ្នាក់ជាតិ ដែលការណ៍នេះឆ្លុះបញ្ចាំងអំពីកង្វះឆន្ទៈរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអភិវឌ្ឍសមត្ថភាពរបស់ខ្លួន ដែលត្រូវបានចាត់ទុកថាជាវិធានការមួយដែលមានប្រសិទ្ធភាពសម្រាប់ការអនុវត្តការងារប្រចាំថ្ងៃរបស់មនុស្ស។

## ៥. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

### ៥.១ សេចក្តីសន្និដ្ឋាន

ជារួម ការសិក្សាស្រាវជ្រាវនេះបានផ្តោតសំខាន់ទៅលើកត្តានៃបញ្ហាប្រឈមមួយចំនួន ដែលបាននឹងកំពុងកើតមានឡើងក្នុងបរិបទនៃការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ នៅក្នុងប្រទេសកម្ពុជា។ បើទោះបីជាការចាប់ផ្តើមកំណែទម្រង់ត្រូវបានចាប់ផ្តើមតាំងពីឆ្នាំ២០០០ មកក៏ដោយក៏បញ្ហាមួយចំនួនរួមមានភាពមិនទាន់ស៊ីសង្វាក់គ្នាក្នុងការបំពេញតួនាទី ភារកិច្ច និងខ្សែគណនេយ្យភាពរវាងក្រុមប្រឹក្សា និងគណៈអភិបាល ការផ្ទេរបុគ្គលិក ធនធានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ ពុំទាន់មានលក្ខណៈសមស្របតាមចំនួន និងទំហំមុខងារដែលបានផ្ទេរ និងសមត្ថភាពរបស់ថ្នាក់ដឹកនាំនិងមន្ត្រីនៅមានកម្រិតបើធៀបនឹងទំហំ និងភាពស្មុគស្មាញនៃការងារ។

មួយវិញទៀត ក្រុមប្រឹក្សាដែលជាអ្នកមានសិទ្ធិអំណាចខាងបញ្ញត្តិ និងខាងប្រតិបត្តិនៅមិនទាន់មានសមត្ថភាព និងលទ្ធភាពក្នុងការស្វែងយល់អំពីតម្រូវការនៅមូលដ្ឋាន ក៏ដូចភាពចន្លោះប្រហោង ឬភាពខ្វះខាតនៃច្បាប់ លិខិតបទដ្ឋាន គោលនយោបាយ និងស្តង់ដានានាដែលបានកំណត់ដោយរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័ន ដើម្បីជាមូលដ្ឋានក្នុងការរៀបចំដីកា និងសេចក្តីសម្រេចចិត្តនានាដែលមានលក្ខណៈជាបទបញ្ជានោះទេ។ ផ្អែកតាមបញ្ហាខាងលើការងារស្រាវជ្រាវនេះត្រូវបានរចនាឡើងដើម្បីសិក្សាស្វែងយល់អំពីបញ្ហាប្រឈមផ្ទាល់នៃក្រុមគោលដៅមួយចំនួនដែលកំពុងអនុវត្តការងារនៅមូលដ្ឋាន។

យោងតាមលទ្ធផលស្រាវជ្រាវ និងការពិភាក្សា យើងអាចធ្វើការសន្និដ្ឋានជារួមថា ឥទ្ធិពលផ្នែកនយោបាយ កង្វះសិទ្ធិអំណាចដឹកនាំនៅមូលដ្ឋានរបស់ក្រុមប្រឹក្សាគឺជាកត្តាមួយដែលរារាំងដល់សមត្ថភាពក្នុងការអនុវត្តការងារក៏ដូចជាការកាត់បន្ថយសិទ្ធិអំណាចខាងបញ្ញត្តិ ដែលប្រគល់ដោយច្បាប់ដល់ក្រុមប្រឹក្សាក្នុងការរៀបចំតាក់តែងដីកា និងលិខិតបទដ្ឋានគតិយុត្តនានា ដោយក្រុមគោលដៅបានអះអាងថាឥទ្ធិពលនៃកត្តានយោបាយបានគ្របដណ្តប់លើការដឹកនាំ និងការសម្រេចចិត្តនៅមូលដ្ឋានដែលជាហេតុនាំឱ្យការអនុវត្តការងារមិនអាចធ្វើទៅបានស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

កត្តាបន្ទាប់ពាក់ព័ន្ធនឹងថវិកាវិភាជន៍ពីរដ្ឋបាលថ្នាក់ជាតិមិនគ្រប់គ្រាន់ និងមិនមានចំណូលផ្ទាល់នៅមូលដ្ឋាន សម្រាប់ក្រុមប្រឹក្សាក្នុងការផ្តួចផ្តើមរៀបចំដីកា និងគោលនយោបាយនៅមូលដ្ឋាន។ ក្រុមគោលដៅបានផ្តោតយ៉ាងសំខាន់ទៅលើភាពខ្វះខាតនូវថវិកាសម្រាប់ការអនុវត្តការងារចាំបាច់មួយចំនួន និងបានបង្ហាញអំពីភាពពឹងផ្អែកខ្លាំងទៅលើកញ្ចប់ថវិកាដែលបានវិភាជន៍ពីថ្នាក់ជាតិតែមួយមុខ និងបានបង្ហាញផលលំបាកពីការមិនទទួលបានចំណូលផ្ទាល់នៅមូលដ្ឋាន។ ជារួម ក្រុមគោលដៅទាំងអស់ជឿជាក់ថាប្រសិនបើក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិមានថវិកាគ្រប់គ្រាន់នោះក្រុមប្រឹក្សានឹងមានលទ្ធភាពកាន់តែច្រើនក្នុងការសិក្សាផ្តួចផ្តើម និងដឹកនាំរៀបចំដាក់ចេញនូវដីកា ឬគោលនយោបាយបានច្រើននាពេលអនាគត។

កត្តាចុងក្រោយ គឺពាក់ព័ន្ធនឹងការកង្វះសមត្ថភាព ចំណេះដឹង និងជំនាញរបស់សមាជិកក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិបានជះឥទ្ធិពលដល់ដំណើរការនៃការផ្តួចផ្តើមរៀបចំ និងដាក់ចេញនូវដីកាក៏ដូចជាគោលនយោបាយនៅមូលដ្ឋាន។ ក្រុមគោលដៅបានលើកឡើងពីបញ្ហាប្រឈមពីការពុំសូវទទួលបានការគាំទ្រការពង្រឹងសមត្ថភាពតាមរយៈការទទួលបានវគ្គបណ្តុះបណ្តាលពីថ្នាក់ជាតិ និងភាគី

ពាក់ព័ន្ធ។ ជាមួយគ្នានេះ ក្រុមគោលដៅបានបញ្ជាក់ប្រកបដោយជំនឿចិត្តថា ប្រសិនបើរាជរដ្ឋាភិបាលងាកមកយកចិត្តទុកដាក់ ពាក់ព័ន្ធនឹងការអភិវឌ្ឍសមត្ថភាពដល់សមាជិកក្រុមប្រឹក្សាបន្ថែម ពួកគាត់ប្រាកដជាអាចបំពេញការងារយ៉ាងមានប្រសិទ្ធភាព។

## ៥.២ អនុសាសន៍

ឆ្លងតាមការសិក្សាស្រាវជ្រាវនេះ អាចកំណត់នូវអនុសាសន៍គោលនយោបាយមួយចំនួនដូចខាងក្រោម៖

១. ពង្រឹងការអនុវត្តតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សា និងគណៈអភិបាលស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងលិខិតបទដ្ឋានគតិយុត្តមានជាធរមាន។

២. លើកកម្ពស់ភាពជាម្ចាស់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការធ្វើសេចក្តីសម្រេចចិត្ត ពាក់ព័ន្ធការបម្រើសេវាសាធារណៈ និងការអភិវឌ្ឍនៅមូលដ្ឋាន ដោយត្រូវកាត់បន្ថយឥទ្ធិពលពីកត្តាខាងក្រៅនានាទាំងផ្នែកដឹកនាំ និងនយោបាយ។

៣. ជំរុញក្រុមប្រឹក្សា និងបុគ្គលិកនៅរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យពង្រីកគំនិតផ្តួចផ្តើមក្នុងការអនុវត្តមុខងារដែលបានផ្ទេរនៅតាមមូលដ្ឋាន ដោយមិនត្រូវពឹងផ្អែក ឬផ្តោតទាំងស្រុងទៅលើថវិកា ដែលត្រូវបានវិភាជន៍។

៤. លើកកម្ពស់សមត្ថភាពរបស់ក្រុមប្រឹក្សា និងបុគ្គលិកនៅរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធការផ្តួចផ្តើម និងវិភាគរៀបចំគោលនយោបាយ តាមរយៈការបណ្តុះបណ្តាល ការបំពេញការងារ និងការរៀនសូត្រពីបទពិសោធន៍នានាទាំងក្នុងនិងក្រៅប្រទេស។

៥. ផ្តល់លទ្ធភាពបន្ថែមដល់រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យកាន់តែទូលំទូលាយទាំងសមត្ថកិច្ច និងហិរញ្ញវត្ថុ តាមរយៈការផ្ទេរមុខងារជាក់លាក់កាន់តែច្រើន និងការផ្ទេរធនធានហិរញ្ញវត្ថុសមស្របដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។

៦. រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវផ្លាស់ប្តូរឥរិយាបថក្នុងការបំពេញតួនាទី ភារកិច្ចរបស់ខ្លួនដោយពុំត្រូវរង់ចាំការណែនាំលម្អិត ការចង្អុលបង្ហាញបន្ថែមពីថ្នាក់ជាតិ និងឬការរង់ចាំរហូតដល់មានធនធានគ្រប់គ្រាន់។

## ៥.៣ ការស្រាវជ្រាវនាពេលអនាគត

ការស្រាវជ្រាវនាពេលអនាគត គួរផ្តោតលើការសិក្សាស្រាវជ្រាវបែបបរិមាណវិស័យក្នុងលក្ខខណ្ឌទូទាំងប្រទេសដើម្បីបញ្ជាក់ការរកឃើញ ក៏ដូចកំណត់នូវទំនាក់ទំនងរវាងកត្តាសំខាន់ដែលបានរកឃើញក្នុងការសិក្សាស្រាវជ្រាវនេះ ថាតើមានឥទ្ធិពលកម្រិតណាជាមួយការផ្តួចផ្តើមរបស់ក្រុមប្រឹក្សានិងទំនាក់ទំនងរវាងកត្តាទាំងនោះ។ ជាមួយគ្នានេះ ដូចបានបញ្ជាក់នៅក្នុងដែនកំណត់នៃការស្រាវជ្រាវ ក្រុមគោលដៅនៃការសិក្សានេះមិនបានរួមបញ្ចូលអ្នកជំនាញរៀបចំលិខិតបទដ្ឋាន និងគោលនយោបាយនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសនៅក្នុងបរិបទនៃរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា។ ក្នុងន័យនេះ ការស្រាវជ្រាវនាពេលអនាគតគួរពិចារណាត្រង់ចំណុចនេះ។

# គន្ថនិទ្ទេស

ព្រះរាជក្រម លេខ នស/រកម/០១០៣/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

ព្រះរាជក្រម លេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក និង ខណ្ឌ

ព្រះរាជក្រម លេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

ព្រះរាជក្រម លេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីរបបគ្រប់គ្រងហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្នាំ២០១១

ច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤ ចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២៣

ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៧៣ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្ដីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ

អនុក្រឹត្យលេខ ១០ អនក្រ.បក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២៤ ស្ដីពីការកំណត់ចំនួនសមាជិកក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ សម្រាប់អាណត្តិទី៤

អនុក្រឹត្យលេខ ២១៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ ស្ដីពីការផ្ទេរមុខងារក្នុងវិស័យ អប់រំ យុវជន និងកីឡា ទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ

អនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៣ ស្ដីពីការកំណត់មុខតំណែងវិជ្ជាជីវៈ និងការពិពណ៌នាមុខតំណែងនានាក្នុងរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ

អនុក្រឹត្យ លេខ ១៨២ អនក្រ.បក ចុះថ្ងៃទី២ ធ្នូ ឆ្នាំ២០១៩ ស្ដីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង

អនុក្រឹត្យ លេខ ១៨៣ អនុក្រ.បក ចុះថ្ងៃទី២ ធ្នូ ឆ្នាំ២០១៩ ស្ដីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលខណ្ឌនៃរាជធានីភ្នំពេញ

អនុក្រឹត្យ លេខ ១៨៤ អនុក្រ.បក ចុះថ្ងៃទី២ ធ្នូ ឆ្នាំ២០១៩ ស្ដីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុក

អនុក្រឹត្យលេខ១៩៣ អនក្រ.បង ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៩ ស្ដីពីការប្រគល់មុខងារគ្រប់គ្រង និងផ្ដល់សេវាសុខាភិបាលទៅឱ្យរដ្ឋបាលរាជធានី ខេត្ត

រាជរដ្ឋាភិបាលកម្ពុជា (២០០៥) ក្របខ័ណ្ឌយុទ្ធសាស្ត្រស្ដីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

អនុក្រឹត្យលេខ ១១៩ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្ដីពីការកំណត់ចំនួនគណៈអភិបាលរាជធានីភ្នំពេញ គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ

- អនុក្រឹត្យលេខ ២២ អនក្រ.បក ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៩ ស្តីពីការកំណត់ចំនួនសមាជិកក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ សម្រាប់អាណត្តិទី៣
- អនុក្រឹត្យលេខ ៥០ អនក្រ.បក ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៨ ស្តីពីការផ្ទេរធនធានថវិការដ្ឋជូនមូលនិធិក្រុង ស្រុក
- អនុក្រឹត្យលេខ ២៤០ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការធ្វើប្រតិភូកម្មសិទ្ធិអំណាចទៅឱ្យគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុកក្នុងការគ្រប់គ្រងបុគ្គលិកបំពេញការងារនៅថ្នាក់ក្រោមជាតិ
- អនុក្រឹត្យលេខ ១១០៥ អនក្រ.តត ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលបន្ថែម នាយករងរដ្ឋបាលនៅក្នុងរចនាសម្ព័ន្ធសាលារាជធានីភ្នំពេញ
- អនុក្រឹត្យលេខ ១០៩០ អនក្រ.តត ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលបន្ថែមនាយករងរដ្ឋបាលនៅក្នុងរចនាសម្ព័ន្ធសាលាខេត្ត
- អនុក្រឹត្យលេខ ១០៨០ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលចំនួនគណៈអភិបាលខេត្ត
- អនុក្រឹត្យលេខ ៤៩៧ អនក្រ.បក ចុះថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០១៣ ស្តីពីការធ្វើប្រតិភូកម្មអំណាច ដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិល ដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ
- អនុក្រឹត្យលេខ ៦៦៣ អនក្រ.តត ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៣ ស្តីពីការកែសម្រួលបន្ថែមនាយករងរដ្ឋបាលនៅក្នុងរចនាសម្ព័ន្ធសាលារាជធានី សាលាខេត្ត
- អនុក្រឹត្យលេខ ៣៦ អនក្រ.បក ចុះថ្ងៃទី៧ ខែមីនា ឆ្នាំ២០១២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិក្រុង ស្រុក
- អនុក្រឹត្យលេខ ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ
- អនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- អនុក្រឹត្យលេខ ២១៧ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សារាជធានីភ្នំពេញ និងគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខណ្ឌនៃរាជធានីភ្នំពេញ

អនុក្រឹត្យលេខ ២១៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខេត្ត គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាក្រុង និងគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាស្រុក

អនុក្រឹត្យ លេខ ០២២ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ ស្តីពីការធ្វើវិមជ្ឈការអំណាច តួនាទី និងភារកិច្ចទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់

ប្រកាសអន្តរក្រសួងលេខ ០០២ សហវ.ប្រក ចុះថ្ងៃទី៤ ខែមករា ឆ្នាំ២០២២ ស្តីពីការជ្រើសរើស និងការកំណត់តួនាទី និងភារកិច្ចរបស់ជំនួយការហិរញ្ញវត្ថុរដ្ឋបាលឃុំ សង្កាត់

ប្រកាសអន្តរក្រសួងលេខ ០៨៣ ផក ចុះថ្ងៃទី២ ខែមីនា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យប្រើប្រាស់សេចក្តីណែនាំបច្ចេកទេសស្តីពីការរៀបចំ និងការកសាងផែនការអភិវឌ្ឍន៍ក្រុង

ប្រកាសអន្តរក្រសួងលេខ ០៧៧ ផក ចុះថ្ងៃទី២ ខែមីនា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យប្រើប្រាស់សេចក្តីណែនាំបច្ចេកទេសស្តីពីការរៀបចំ និងការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង

ប្រកាសអន្តរក្រសួងលេខ ៣២៤ សហវ.ប្រក ចុះថ្ងៃទី១ ខែមេសា ឆ្នាំ២០១៣ ស្តីពីនីតិវិធីនៃការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

ប្រកាសលេខ ៤៨០៧ ប្រក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈ-កម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ នៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

ប្រកាសលេខ ៣៨៤០ ប្រក ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំសង្កាត់

ប្រកាសលេខ ៦៦០៦ ប្រក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៨ របស់ក្រសួងមហាផ្ទៃ ស្តីពីការអភិវឌ្ឍសមត្ថភាពរបស់មន្ត្រីរាជការស៊ីវិលនៅទីស្តីការក្រសួងមហាផ្ទៃ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

សេចក្តីណែនាំលេខ ០៥៥ សណន ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២០ ស្តីពីនីតិវិធីនៃការជ្រើសរើសបុគ្គលិក ក្រៅក្របខណ្ឌរបស់រដ្ឋបាលឃុំ សង្កាត់

សេចក្តីណែនាំលេខ០០២ សហវ.អលស ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ ស្តីពីវិធីសាស្ត្រ និងនីតិវិធីលទ្ធកម្មរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ

លិខិតលេខ ៧៥៣៧ សហវ.លស.អហក ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការបែងចែកធនធានមូលនិធិឃុំសង្កាត់ទូទាំងប្រទេសសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤

ឯកសាររបស់កិច្ចប្រជុំកិច្ចប្រជុំផ្សព្វផ្សាយការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងការងារគណនេយ្យភាពសង្គម នៅព្រឹកថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២៣ នៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)

Abdullah, R. A. (2019). Factors affecting the role of local councils in local policy-making. *Review of Economics and Political Science, 4*(4), 285–303. https://doi.org/10.1108/reps-12-2018-0035

Asian Development Bank. (2018). *Fiscal decentralization reform in Cambodia: Progress over the past decade and opportunities*. ADB.

Bahl, R., & Bird, R. M. (2018). *Fiscal decentralization and local finance in developing countries*. Edward Elgar Publishing. https://doi.org/10.4337/9781786435309.00006

Eton, M., Sunday, A., & Nkamusiima, D. (2023). Budget implementations in local governments in Uganda: Reflections from Kiruhura and Mbarara. *International Journal of Financial, Accounting, and Management, 5*(2), 235–249. https://doi.org/10.35912/ijfam.v5i2.1423

EU SPACE. (2010). *Multi-level citizen & councilor survey: An index to measure subnational democratic accountability in Cambodia*. EU SPACE Programme.

Fox, J., & Aranda, J. (1996). *Decentralization and rural development in Mexico: Community participation in Oaxaca's municipal funds program*. Unpublished report.

Hlynsdóttir, E. M. (2024). Administrative capacity and long-term policy making at the Icelandic local level. *Icelandic Review of Politics & Administration, 12*(2), 237–258. https://doi.org/10.13177/irpa.a.2016.12.2.3

Hulst, R., Mafuru, W., & Mpenzi, D. (2015). Fifteen years after decentralization by devolution: Political-administrative relations in Tanzanian local government. *Public Administration and Development, 35*(5), 360–371.

Lameck, W. U., & Kinemo, S. (2022). In search of a link between fiscal decentralization and fiscal autonomy in service delivery in urban local government authorities in Tanzania. *Journal of Governance and Development, 17*(2), 22–40.

Niazi, T. (2011). *Deconcentration and decentralization reforms in Cambodia: Recommendations for an institutional framework*. Asian Development Bank.

Rohdewohld, R. (2021). Decentralization, local governance, and localizing the Sustainable Development Goals in Cambodia. In *Decentralization and local governance in developing countries* (pp. 225–252). Routledge.

Rubin, M. M., Bartle, J. R., & Willoughby, K. (2024). Equity in budgeting: U.S. state and local government initiatives. *Journal of Policy Studies*. Advance online publication.

Schneider, A. (2003). Decentralization: Conceptualization and measurement. *Studies in Comparative International Development, 38*(6), 32–56.

Thompson, T., & Shah, A. (2004). *Implementing decentralized local governance: A treacherous road with potholes, detours, and road closures* (Policy Research Working Paper No. 3353). World Bank. http://hdl.handle.net/10986/14178

Ye, Z., Gao, H., & Wu, W. (2024). Local government capacity and response strategies to central policy piloting goals: A case study of China’s new-type urbanization plan. *Humanities and Social Sciences Communications, 11*, 1648. https://doi.org/10.1057/s41599-024-04170-3

# ឧបសម្ព័ន្ធ

(**ក១**) តារាងទី១៖ ស្ដីពីការដាក់ចេញដីកានៅមូលដ្ឋាន




(**ក២**) តារាងទី២៖ ការសន្ទតទី១ "ឥទ្ធិពលផ្នែកនយោបាយ និងកង្វះសិទ្ធិសំណាចដឹកនាំនៅមូលដ្ឋាន បានកាត់បន្ថយ អំណាចនីតិបញ្ញត្តិ និងអំណាចនីតិប្រតិបត្តិរបស់ក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិ។"



**(ក៣) តារាងទី៣៖ ការសន្ទតទី២ "ការវិភាជន៍ថវិកាមានកំណត់របស់រាជរដ្ឋាភិបាលបានរាំង ឬបង្អាក់ការ ផ្តួចផ្តើម និងការដាក់ចេញគោលនយោបាយរបស់ក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិ។"**




**(ក៤) តារាងទី៤៖ ការសន្ទតទី៣ "កង្វះចំណេះ និងជំនាញក្នុងការរៀបចំគោលនយោបាយរបស់ សមាជិកក្រុមប្រឹក្សា និងមន្ត្រីរាជការនៅរដ្ឋបាលថ្នាក់ក្រោមជាតិរាំងដល់ការផ្តួចផ្តើម និងដាក់ចេញ គោលនយោបាយនៅមូលដ្ឋាន។**



## (៦១) តារាងចំនួនរដ្ឋបាលខេត្ត ក្រុង ស្រុក ឃុំ សង្កាត់គោលដៅ

| គោលដៅ | ដីកាឯកត្តភូត | ដីកាបទបញ្ជាទូទៅ |
|---|---:|---:|
| រដ្ឋបាលខេត្ត | ១ | |
| រដ្ឋបាលខេត្ត | ១ | ១ |
| រដ្ឋបាលខេត្ត | ១ | |
| រដ្ឋបាលខេត្ត | ១ | |
| រដ្ឋបាលស្រុក | ១ | |
| រដ្ឋបាលស្រុក | ១ | |
| រដ្ឋបាលស្រុក | ១ | |
| រដ្ឋបាលស្រុក | ១ | |
| រដ្ឋបាលក្រុង | ១ | ១ |
| រដ្ឋបាលក្រុង | ១ | |
| រដ្ឋបាលក្រុង | ១ | |
| រដ្ឋបាលក្រុង | ១ | |
| រដ្ឋបាលឃុំ | ១ | |
| រដ្ឋបាលឃុំ | ១ | |
| រដ្ឋបាលឃុំ | ១ | |
| រដ្ឋបាលឃុំ | ១ | |
| រដ្ឋបាលឃុំ | ១ | |
| រដ្ឋបាលឃុំ | ១ | |
| រដ្ឋបាលឃុំ | ១ | |
| រដ្ឋបាលឃុំ | ១ | |
| រដ្ឋបាលសង្កាត់ | ១ | |
| រដ្ឋបាលសង្កាត់ | ១ | |
| រដ្ឋបាលសង្កាត់ | ១ | |
| រដ្ឋបាលសង្កាត់ | ១ | |
| រដ្ឋបាលសង្កាត់ | ១ | |
| រដ្ឋបាលសង្កាត់ | ១ | |
| រដ្ឋបាលសង្កាត់ | ១ | |
| រដ្ឋបាលសង្កាត់ | ១ | |
| សរុប | ២៨ | ២ |

## (៩២) តារាងចំនួនក្រុមគោលដៅដែលត្រូវបានសម្ភាសន៍

| លេខកូដ | តួនាទី | ទីកន្លែង |
|---|---|---|
| ក1 | អភិបាល | រដ្ឋបាលខេត្ត |
| ក2 | អភិបាលរង | រដ្ឋបាលខេត្ត |
| ក3 | អភិបាលរង | រដ្ឋបាលខេត្ត |
| ក4 | អភិបាលរង | រដ្ឋបាលក្រុង ស្រុក |
| ក5 | អភិបាល | រដ្ឋបាលក្រុង ស្រុក |
| ក6 | អភិបាល | រដ្ឋបាលក្រុង ស្រុក |
| ក7 | អភិបាល | រដ្ឋបាលក្រុង ស្រុក |
| ក8 | អភិបាល | រដ្ឋបាលក្រុង ស្រុក |
| ក9 | អភិបាល | រដ្ឋបាលក្រុង ស្រុក |
| ក10 | អភិបាល | រដ្ឋបាលក្រុង ស្រុក |
| ក11 | អភិបាលរង | រដ្ឋបាលក្រុង ស្រុក |
| ក12 | ប្រធានក្រុមប្រឹក្សា | រដ្ឋបាលខេត្ត |
| ក13 | ប្រធានក្រុមប្រឹក្សា | រដ្ឋបាលខេត្ត |
| ក14 | ប្រធានក្រុមប្រឹក្សា | រដ្ឋបាលខេត្ត |
| ក15 | ប្រធានក្រុមប្រឹក្សា | រដ្ឋបាលខេត្ត |
| ក16 | ប្រធានក្រុមប្រឹក្សា | រដ្ឋបាលក្រុង ស្រុក |
| ក17 | ប្រធានក្រុមប្រឹក្សា | រដ្ឋបាលក្រុង ស្រុក |
| ក18 | ប្រធានក្រុមប្រឹក្សា | រដ្ឋបាលក្រុង ស្រុក |
| ក19 | ប្រធានក្រុមប្រឹក្សា | រដ្ឋបាលក្រុង ស្រុក |
| ក20 | ប្រធានក្រុមប្រឹក្សា | រដ្ឋបាលក្រុង ស្រុក |
| ក21 | ប្រធានក្រុមប្រឹក្សា | រដ្ឋបាលក្រុង ស្រុក |
| ក22 | ប្រធានក្រុមប្រឹក្សា | រដ្ឋបាលក្រុង ស្រុក |
| ក23 | ប្រធានក្រុមប្រឹក្សា | រដ្ឋបាលក្រុង ស្រុក |
| ក24 | សមាជិកក្រុមប្រឹក្សា | រដ្ឋបាលខេត្ត |
| ក25 | សមាជិកក្រុមប្រឹក្សា | រដ្ឋបាលខេត្ត |
| ក26 | សមាជិកក្រុមប្រឹក្សា | រដ្ឋបាលខេត្ត |
| ក27 | សមាជិកក្រុមប្រឹក្សា | រដ្ឋបាលខេត្ត |
| ក28 | សមាជិកក្រុមប្រឹក្សា | រដ្ឋបាលក្រុង ស្រុក |
| ក29 | សមាជិកក្រុមប្រឹក្សា | រដ្ឋបាលក្រុង ស្រុក |
| ក30 | សមាជិកក្រុមប្រឹក្សា | រដ្ឋបាលក្រុង ស្រុក |
| ក31 | សមាជិកក្រុមប្រឹក្សា | រដ្ឋបាលក្រុង ស្រុក |
| ក32 | សមាជិកក្រុមប្រឹក្សា | រដ្ឋបាលក្រុង ស្រុក |
| ក33 | សមាជិកក្រុមប្រឹក្សា | រដ្ឋបាលក្រុង ស្រុក |
| ក34 | សមាជិកក្រុមប្រឹក្សា | រដ្ឋបាលក្រុង ស្រុក |
| ក35 | សមាជិកក្រុមប្រឹក្សា | រដ្ឋបាលក្រុង ស្រុក |
| ក36 | សមាជិកក្រុមប្រឹក្សា | រដ្ឋបាលឃុំ សង្កាត់ |
| ក37 | សមាជិកក្រុមប្រឹក្សា | រដ្ឋបាលឃុំ សង្កាត់ |
| ក38 | សមាជិកក្រុមប្រឹក្សា | រដ្ឋបាលឃុំ សង្កាត់ |
| ក39 | សមាជិកក្រុមប្រឹក្សា | រដ្ឋបាលឃុំ សង្កាត់ |
| ក40 | សមាជិកក្រុមប្រឹក្សា | រដ្ឋបាលឃុំ សង្កាត់ |
| ក41 | សមាជិកក្រុមប្រឹក្សា | រដ្ឋបាលឃុំ សង្កាត់ |
| ក42 | សមាជិកក្រុមប្រឹក្សា | រដ្ឋបាលឃុំ សង្កាត់ |
| ក43 | សមាជិកក្រុមប្រឹក្សា | រដ្ឋបាលឃុំ សង្កាត់ |

## (ខ៣) តារាងចំនួនក្រុមគោលដៅជាសមាជិកក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ដែលត្រូវបានសម្ភាសន៍

| ឈ្មោះ | ភេទ | អាយុ | តួនាទី | រដ្ឋបាល | បទពិសោធន៍ជាក្រុមប្រឹក្សា | មុខរបរមុនក្លាយជាសមាជិកក្រុមប្រឹក្សា |
|---|---|---|---|---|---|---|
| ក1 | ប្រុស | ៧៩ | ប្រធានក្រុមប្រឹក្សា | ក្រុង ស្រុក | ១៥ | អភិបាលស្រុក |
| ក2 | ប្រុស | ៧១ | សមាជិកក្រុមប្រឹក្សា | ក្រុង ស្រុក | ១១ | ប្រធាននាយកដ្ឋាន ក្រសួងកសិកម្ម |
| ក3 | ប្រុស | ៤២ | សមាជិកក្រុមប្រឹក្សា | ក្រុង ស្រុក | ៦ | គ្រូបង្រៀនកម្រិតឧត្តម |
| ក4 | ស្រី | ៣៤ | សមាជិកក្រុមប្រឹក្សា | ក្រុង ស្រុក | ៦ | គ្រូបង្រៀនកម្រិតឧត្តម |
| ក5 | ប្រុស | ៦៧ | ប្រធានក្រុមប្រឹក្សា | ក្រុង ស្រុក | ១០ | អនុប្រធានការិយាល័យមន្ទីរសង្គមកិច្ច |
| ក6 | ប្រុស | ៧២ | សមាជិកក្រុមប្រឹក្សា | ក្រុង ស្រុក | ៧ | មេឃុំ |
| ក7 | ប្រុស | ៦៥ | សមាជិកក្រុមប្រឹក្សា | ក្រុង ស្រុក | ៥ | មន្ត្រីនគរបាល |
| ក8 | ប្រុស | ៦០ | សមាជិកក្រុមប្រឹក្សា | ក្រុង ស្រុក | ១០ | នាយករដ្ឋបាលស្រុក |
| ក9 | ប្រុស | ៧៧ | សមាជិកក្រុមប្រឹក្សា | ក្រុង ស្រុក | ១០ | ប្រធានក្រុមប្រឹក្សាឃុំ |
| ក10 | ប្រុស | ៧២ | ប្រធានក្រុមប្រឹក្សា | ឃុំ/សង្កាត់ | ១៣ | ប្រធានការិយាល័យមន្ទីរសង្គមកិច្ច |
| ក11 | ប្រុស | ៧២ | សមាជិកក្រុមប្រឹក្សា | ឃុំ/សង្កាត់ | ១៥ | មន្ត្រីផែនការស្រុក |
| ក12 | ប្រុស | ៧៥ | សមាជិកក្រុមប្រឹក្សា | ឃុំ/សង្កាត់ | ២២ | គណៈអចិន្ត្រៃយ៍គណបក្សឃុំ |
| ក13 | ប្រុស | ៥២ | សមាជិកក្រុមប្រឹក្សា | ឃុំ/សង្កាត់ | ៧ | មន្ត្រីជំនួយការឃុំ |
| ក14 | ប្រុស | ៦៧ | សមាជិកក្រុមប្រឹក្សា | ឃុំ/សង្កាត់ | ២២ | យោធាឃុំ |
| ក15 | ប្រុស | ៤៨ | សមាជិកក្រុមប្រឹក្សា | ឃុំ/សង្កាត់ | ៧ | គ្មាន |
| ក16 | ស្រី | ៦៩ | សមាជិកក្រុមប្រឹក្សា | ឃុំ/សង្កាត់ | ១២ | មន្ត្រីជំនួយការឃុំ |
| ក17 | ប្រុស | ៦៩ | ប្រធានក្រុមប្រឹក្សា | ក្រុង ស្រុក | ៥ | អភិបាលស្រុក |
| ក18 | ប្រុស | ៦៤ | សមាជិកក្រុមប្រឹក្សា | ក្រុង ស្រុក | ៧ | ប្រជាពលរដ្ឋ |
| ក19 | ប្រុស | ៦៥ | សមាជិកក្រុមប្រឹក្សា | ក្រុង ស្រុក | ៥ | នាយករងរដ្ឋបាលស្រុក |
| ក20 | ប្រុស | ៧០ | សមាជិកក្រុមប្រឹក្សា | ក្រុង ស្រុក | ៦ | អនុប្រធានការិយាល័យអប់រំស្រុក |
| ក21 | ស្រី | ៣៣ | សមាជិកក្រុមប្រឹក្សា | ក្រុង ស្រុក | ៦ | ជំនួយការឃុំ |
| ក22 | ប្រុស | ៦២ | ប្រធានក្រុមប្រឹក្សា | ខេត្ត | ២ | អភិបាលខេត្ត |
| ក23 | ប្រុស | ៧២ | សមាជិកក្រុមប្រឹក្សា | ខេត្ត | ១០ | អភិបាលក្រុង |
| ក24 | ប្រុស | ៦០ | សមាជិកក្រុមប្រឹក្សា | ខេត្ត | ១ | អភិបាលស្រុក |
| ក25 | ស្រី | ៣៦ | សមាជិកក្រុមប្រឹក្សា | ខេត្ត | ១ | អនុប្រធានមន្ទីរ |
| ក26 | ប្រុស | ៦៣ | សមាជិកក្រុមប្រឹក្សា | ខេត្ត | ១០ | បុគ្គលិកក្រុមហ៊ុន |
| ក27 | ប្រុស | ៦៥ | ប្រធានក្រុមប្រឹក្សា | ក្រុង ស្រុក | ៥ | អភិបាលក្រុង |
| ក28 | ប្រុស | ៧៤ | សមាជិកក្រុមប្រឹក្សា | ក្រុង ស្រុក | ១៥ | អភិបាលស្រុក |
| ក29 | ប្រុស | ៥២ | សមាជិកក្រុមប្រឹក្សា | ក្រុង ស្រុក | ១ | មន្ត្រីរដ្ឋបាលខេត្ត |
| ក30 | ស្រី | ៦៤ | សមាជិកក្រុមប្រឹក្សា | ក្រុង ស្រុក | ៥ | ប្រធានការិយាល័យអប់រំក្រុង |
| ក31 | ប្រុស | ៧១ | សមាជិកក្រុមប្រឹក្សា | ក្រុង ស្រុក | ១៥ | អនុប្រធានមន្ទីរពាណិជ្ជកម្ម |
| ក32 | ស្រី | ៥៧ | ប្រធានក្រុមប្រឹក្សា | ឃុំ/សង្កាត់ | ២០ | កសិករ |
| ក33 | ប្រុស | ៥៩ | សមាជិកក្រុមប្រឹក្សា | ឃុំ/សង្កាត់ | ២៥ | ជំនួយការភូមិ |
| ក34 | ប្រុស | ៥៨ | សមាជិកក្រុមប្រឹក្សា | ឃុំ/សង្កាត់ | ៥ | មន្ត្រីនគរបាល |
| ក35 | ប្រុស | ៥៣ | សមាជិកក្រុមប្រឹក្សា | ឃុំ/សង្កាត់ | ២០ | ជំនួយការភូមិ |
| ក36 | ប្រុស | ៦៨ | សមាជិកក្រុមប្រឹក្សា | ឃុំ/សង្កាត់ | ២៥ | កសិករ |
| ក37 | ប្រុស | ៦៨ | សមាជិកក្រុមប្រឹក្សា | ក្រុង ស្រុក | ១៥ | មេឃុំ |
| ក38 | ប្រុស | ៦២ | សមាជិកក្រុមប្រឹក្សា | ក្រុង ស្រុក | ១ | អភិបាលស្រុក |
| ក39 | ស្រី | ៤៩ | សមាជិកក្រុមប្រឹក្សា | ក្រុង ស្រុក | ១៥ | មន្ត្រីការិយាល័យកិច្ចការនារីស្រុក |
| ក40 | ប្រុស | ៦១ | សមាជិកក្រុមប្រឹក្សា | ក្រុង ស្រុក | ៥ | ស្មៀនឃុំ |
| ក41 | ប្រុស | ៦០ | សមាជិកក្រុមប្រឹក្សា | ក្រុង ស្រុក | ១ | នគរបាល |
| ក42 | ស្រី | ៧១ | សមាជិកក្រុមប្រឹក្សា | ខេត្ត | ១១ | នាយិកាមជ្ឈមណ្ឌលគរុកោសល្យ |
| ក43 | ប្រុស | ៦៨ | សមាជិកក្រុមប្រឹក្សា | ខេត្ត | ៦ | ស្នងការរងនគរបាលខេត្ត |
| ក44 | ប្រុស | ៣៩ | ប្រធានក្រុមប្រឹក្សា | ឃុំ/សង្កាត់ | ៧ | ចៅសង្កាត់ព្រះស្តេច |
| ក45 | ស្រី | ៥៤ | សមាជិកក្រុមប្រឹក្សា | ឃុំ/សង្កាត់ | ៧ | គ្មាន |
| ក46 | ស្រី | ៤២ | សមាជិកក្រុមប្រឹក្សា | ឃុំ/សង្កាត់ | ២ | អតីតមេភូមិ |
| ក47 | ស្រី | ៥២ | សមាជិកក្រុមប្រឹក្សា | ឃុំ/សង្កាត់ | ២ | អតីតមេភូមិ |
| ក48 | ប្រុស | ៦៤ | សមាជិកក្រុមប្រឹក្សា | ឃុំ/សង្កាត់ | ១២ | ក្រុមប្រឹក្សាសង្កាត់ព្រះស្តេច |
| ក49 | ប្រុស | ៧៥ | ប្រធានក្រុមប្រឹក្សា | ក្រុង ស្រុក | ១៦ | ប្រធានការិយាល័យស្រុក |
| ក50 | ប្រុស | ៦៥ | សមាជិកក្រុមប្រឹក្សា | ក្រុង ស្រុក | ៦ | មន្ត្រីសាលាក្រុង |
| ក51 | ប្រុស | ៦៦ | សមាជិកក្រុមប្រឹក្សា | ក្រុង ស្រុក | ៦ | ស្នងការរងនគរបាលខេត្ត |
| ក52 | ស្រី | ៦៥ | សមាជិកក្រុមប្រឹក្សា | ក្រុង ស្រុក | ១ | ប្រធានមន្ទីរ |
| ក53 | ស្រី | ៣១ | សមាជិកក្រុមប្រឹក្សា | ក្រុង ស្រុក | ១ | និស្សិត |
| ក54 | ប្រុស | ៧២ | ប្រធានក្រុមប្រឹក្សា | ឃុំ/សង្កាត់ | ២៥ | កសិករ |
| ក55 | ស្រី | ៦៤ | សមាជិកក្រុមប្រឹក្សា | ឃុំ/សង្កាត់ | ១៧ | មេផ្ទះ |
| ក56 | ប្រុស | ៦៣ | សមាជិកក្រុមប្រឹក្សា | ឃុំ/សង្កាត់ | ២ | កសិករ |
| ក57 | ស្រី | ៥៣ | សមាជិកក្រុមប្រឹក្សា | ឃុំ/សង្កាត់ | ១២ | មេផ្ទះ |
| ក58 | ប្រុស | ៦៨ | សមាជិកក្រុមប្រឹក្សា | ឃុំ/សង្កាត់ | ២ | នាយកសាលា |
| ក59 | ប្រុស | | ប្រធានក្រុមប្រឹក្សា | ក្រុង ស្រុក | ១ | អភិបាលស្រុក |
| ក60 | ប្រុស | ៦៣ | សមាជិកក្រុមប្រឹក្សា | ក្រុង ស្រុក | ៥ | គ្មាន |
| ក61 | ស្រី | ២៥ | សមាជិកក្រុមប្រឹក្សា | ក្រុង ស្រុក | ១ | មន្ត្រីកិច្ចសន្យាសាលាស្រុក |
| ក62 | ប្រុស | ៧៣ | សមាជិកក្រុមប្រឹក្សា | ក្រុង ស្រុក | ៤ | អនុប្រធានការិយាល័យស្រុក |
| ក63 | ស្រី | ៦៨ | សមាជិកក្រុមប្រឹក្សា | ក្រុង ស្រុក | ១៦ | គ្រូបង្រៀន |
| ក64 | ប្រុស | ៦៧ | ប្រធានក្រុមប្រឹក្សា | ខេត្ត | ៦ | អភិបាលរងខេត្ត |
| ក65 | ប្រុស | ៧០ | សមាជិកក្រុមប្រឹក្សា | ខេត្ត | ៤ | ប្រធានមន្ទីរធម្មការ |
| ក66 | ប្រុស | ៧០ | សមាជិកក្រុមប្រឹក្សា | ខេត្ត | ៥ | ប្រធានមន្ទីរសាធារណការ |
| ក67 | ប្រុស | ៧០ | សមាជិកក្រុមប្រឹក្សា | ខេត្ត | ៥ | អភិបាលស្រុក |
| ក68 | ស្រី | ៧៣ | សមាជិកក្រុមប្រឹក្សា | ខេត្ត | ៥ | អនុប្រធានមន្ទីរអប់រំ |
| ក69 | ប្រុស | ៦៧ | ប្រធានក្រុមប្រឹក្សា | ក្រុង ស្រុក | ២ | អភិបាលរងស្រុក |
| ក70 | ប្រុស | ៧៤ | សមាជិកក្រុមប្រឹក្សា | ក្រុង ស្រុក | ១៥ | គ្មាន |
| ក71 | ប្រុស | ៧២ | សមាជិកក្រុមប្រឹក្សា | ក្រុង ស្រុក | ១៥ | គ្មាន |
| ក72 | ស្រី | ៣៦ | សមាជិកក្រុមប្រឹក្សា | ក្រុង ស្រុក | ៦ | គ្មាន |
| ក73 | ប្រុស | ៤០ | សមាជិកក្រុមប្រឹក្សា | ក្រុង ស្រុក | ៦ | គ្មាន |
| ក74 | ប្រុស | ៥៥ | ប្រធានក្រុមប្រឹក្សា | ក្រុង ស្រុក | ១ | អធិការរងនគរបាលស្រុក |
| ក75 | ស្រី | ៦៨ | សមាជិកក្រុមប្រឹក្សា | ក្រុង ស្រុក | ១៥ | មន្ត្រីមន្ទីរកិច្ចការនារី |
| ក76 | ប្រុស | ៦៩ | សមាជិកក្រុមប្រឹក្សា | ក្រុង ស្រុក | ១០ | អភិបាលរងស្រុក |
| ក77 | ប្រុស | ៦៤ | សមាជិកក្រុមប្រឹក្សា | ក្រុង ស្រុក | ១៥ | យុវជនឃុំ |
| ក78 | ស្រី | ៤៣ | សមាជិកក្រុមប្រឹក្សា | ក្រុង ស្រុក | ១ | មន្ត្រីសហគមន៍ |
| ក79 | ប្រុស | ៦៥ | ប្រធានក្រុមប្រឹក្សា | ឃុំ/សង្កាត់ | ២៣ | គ្មាន |
| ក80 | ប្រុស | ៥៥ | សមាជិកក្រុមប្រឹក្សា | ឃុំ/សង្កាត់ | ២ | គ្មាន |
| ក81 | ប្រុស | ៧១ | សមាជិកក្រុមប្រឹក្សា | ឃុំ/សង្កាត់ | ២ | គ្មាន |
| ក82 | ប្រុស | ៥៥ | សមាជិកក្រុមប្រឹក្សា | ឃុំ/សង្កាត់ | ៧ | គ្មាន |
| ក83 | ស្រី | ៦៥ | សមាជិកក្រុមប្រឹក្សា | ឃុំ/សង្កាត់ | ៧ | នាយកសាលា |
| ក84 | ស្រី | ៤២ | សមាជិកក្រុមប្រឹក្សា | ឃុំ/សង្កាត់ | ២ | គ្មាន |
| ក85 | ប្រុស | ៦៨ | ប្រធានក្រុមប្រឹក្សា | ឃុំ/សង្កាត់ | ២៣ | មេភូមិ |
| ក86 | ប្រុស | ៦៦ | សមាជិកក្រុមប្រឹក្សា | ឃុំ/សង្កាត់ | ២៣ | យោធាឃុំ |
| ក87 | ស្រី | ៣២ | សមាជិកក្រុមប្រឹក្សា | ឃុំ/សង្កាត់ | ២ | ជំនួយការឃុំ |
| ក88 | ប្រុស | ៤៤ | សមាជិកក្រុមប្រឹក្សា | ឃុំ/សង្កាត់ | ២៣ | ស្មៀនឃុំ |

## (គ១) កម្រងសំណួរសម្ភាសន៍ប្រមូលទិន្នន័យ(អភិបាលខេត្ត ក្រុង ស្រុក)

### I. ប្រព័ន្ធនយោបាយ

1. ក្នុងតួនាទីជាអ្នកអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា តើឯកឧត្តម លោក លោកស្រី មានទស្សនៈយ៉ាងដូចម្តេចចំពោះមុខងារ និងតួនាទីរបស់ក្រុមប្រឹក្សា ក្នុងការដាក់ចេញនូវគោលនយាបាយ ឬលិខិតបទដ្ឋានគតិយុត្តនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ?
2. តើឯកឧត្តម លោក លោកស្រីយល់ឃើញថាក្រុមប្រឹក្សាបានអនុវត្តតួនាទី និងមុខងាររបស់ខ្លួនបានពេញលេញ និងមានប្រសិទ្ធភាពហើយឬនៅ ?
3. តើប្រព័ន្ធនយោបាយនៅរដ្ឋបាលថ្នាក់ក្រោមជាតិ មានឥទ្ធិពលបែបណាខ្លះទៅលើការដាក់ចេញនូវគោលនយាបាយ ឬលិខិតបទដ្ឋានគតិយុត្តរបស់ក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិ ?
4. តើឯកឧត្តម លោកជំទាវ លោក លោកស្រីយល់ឃើញយ៉ាងណាចំពោះសិទ្ធិអំណាចផ្នែកនយោបាយដែលក្រុមប្រឹក្សាថ្នាក់ក្រោមជាតិមាននាពេលបច្ចុប្បន្ន ? គ្រប់គ្រាន់ឬទេ ?
5. តើទំនាក់ទំនងរវាងក្រុមប្រឹក្សា និងគណៈអភិបាលមានឥទ្ធិពលយ៉ាងដូចម្តេចក្នុងដំណើរការរៀបចំ និងដាក់ចេញនៅគោលនយោបាយ ឬលិខិតបទដ្ឋានគតិយុត្តនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ?

### II. ហិរញ្ញវត្ថុ

១. តើឯកឧត្តម លោកជំទាវ លោក លោកស្រីយល់ឃើញថាហិរញ្ញវត្ថុប្រចាំឆ្នាំដែលបានវិភាជន៍ពីរដ្ឋបាលថ្នាក់ជាតិទៅរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់គ្រាន់ដែរឬទេ សម្រាប់គាំទ្រការរៀបចំ និងដាក់ចេញនូវគោលនយោបាយ ឬលិខិតបទដ្ឋានគតិយុត្តសម្រាប់ការអភិវឌ្ឍនៅមូលដ្ឋាន ?

២. ក្រៅពីថវិកាប្រចាំឆ្នាំ តើរដ្ឋបាលខេត្ត ក្រុង ស្រុកមានប្រភពចំណូលផ្សេងៗដែរឬទេ ? អ្វីខ្លះ ? ប្រើប្រាស់ទៅលើការងារអ្វីខ្លះ ?

៣. តើការវិភាជន៍ថវិកាបានគ្រប់គ្រាន់ ឬមិនទាន់គ្រប់គ្រាន់មានផលប៉ះពាល់យ៉ាងដូចម្តេចដល់ដំណើរការផ្តួចផ្តើម និងការដាក់ចេញនូវគោលនយោបាយឬលិខិតបទដ្ឋានគតិយុត្តសម្រាប់ការអភិវឌ្ឍនៅមូលដ្ឋាន ?

៤. តើឯកឧត្តម លោក លោកស្រីអាចបញ្ជាក់អំពីសិទ្ធិអំណាចរវាងក្រុមប្រឹក្សា និងគណៈអភិបាលក្នុងការគ្រោង ឬប្រើប្រាស់ថវិការបស់រដ្ឋបាលខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ ?

### III. ការអភិវឌ្ឍសមត្ថភាព

១. តើឯកឧត្តម លោកជំទាវ លោក លោកស្រីយល់ឃើញថាសមាជិកក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិមានសមត្ថភាពគ្រប់គ្រាន់ក្នុងការផ្តួចផ្តើមរៀបចំ និងការដាក់ចេញនូវលិខិតបទដ្ឋាន គតិយុត្ត ឬគោលនយោបាយហើយឬនៅ ?

២. តើការពង្រឹង ឬជំរុញការបណ្តុះបណ្តាលអភិវឌ្ឍន៍សមត្ថភាពរបស់សមាជិកក្រុមប្រឹក្សា និងជួយជំរុញការរៀបចំ និងដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយនៅមូលដ្ឋានឬទេ ? ហេតុអ្វី ?

៣. តើគួរមានការគាំទ្របែបណាដើម្បីបង្កើន ឬពង្រឹងនូវសមត្ថភាពរបស់សមាជិកក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិ? តើគួរពង្រឹងលើប្រធានបទ ឬជំនាញអ្វីខ្លះ?

IV. **អនុសាសន៍ និងសំណូមពរ**

១. តើឯកឧត្តម លោក លោកស្រី យល់ឃើញថាគួរមានការគាំទ្របន្ថែម ដើម្បីជំរុញការផ្តួចផ្តើមរៀបចំ និងដាក់ចេញគោលនយោបាយរបស់ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ។

២. តើឯកឧត្តម លោក លោកស្រីមានអនុសាសន៍បែបណាដើម្បីអាចសម្រួលដល់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តួចផ្តើម និងការដាក់ចេញនូវដីកា ឬគោលនយោបាយនៅមូលដ្ឋាន។

## (គ២) កម្រងសំណួរសម្ភាសន៍ប្រមូលទិន្នន័យ (ប្រធាន និងសមាជិកក្រុមប្រឹក្សា)

I. **ព័ត៌មានផ្ទាល់ខ្លួន និងសាវតា** (សូមបំពេញក្នុងតារាង)

១. ឈ្មោះ ភេទ និងអាយុ។

២. កម្រិតសញ្ញាប័ត្រ។

៣. តើឯកឧត្តម លោកជំទាវ លោក លោកស្រីមានបទពិសោធន៍ការងារជាក្រុមប្រឹក្សារយៈប៉ុន្មានឆ្នាំ?

៤. តើឯកឧត្តម លោកជំទាវ លោក លោកស្រីប្រកបការងារអ្វីមុនក្លាយជាសមាជិកក្រុមប្រឹក្សា?

II. **ប្រព័ន្ធនយោបាយ**

១. តើប្រព័ន្ធនយោបាយមានឥទ្ធិពលបែបណាខ្លះទៅលើការដាក់ចេញនូវគោលនយាបាយ ឬចលិខិតបទដ្ឋានគតិយុត្តរបស់ក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិ?

២. តើឯកឧត្តម លោកជំទាវ លោក លោកស្រីយល់ឃើញយ៉ាងណាចំពោះសិទ្ធិអំណាចផ្នែកនយោបាយដែលក្រុមប្រឹក្សាថ្នាក់ក្រោមជាតិមាននាពេលបច្ចុប្បន្ន? គ្រប់គ្រាន់ឬទេ?

៣. តើមានបញ្ហាប្រឈមផ្នែកនយោបាយអ្វីខ្លះដែលរារាំ ឬបង្អាក់ក្រុមប្រឹក្សាក្នុងការរៀបចំ ឬដាក់ចេញនូវគោលនយោបាយ ឬលិខិតបទដ្ឋានគតិយុត្តនៅមូលដ្ឋាន?

៤. តើក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិសព្វថ្ងៃបានជួបបញ្ហាប្រឈមអ្វីខ្លះ ពាក់ព័ន្ធនឹងសិទ្ធិអំណាចផ្នែកនយោបាយក្នុងការរៀបចំ ឬដាក់ចេញនូវគោលនយោបាយ ឬលិខិតបទដ្ឋានគតិយុត្តនៅមូលដ្ឋាន?

៥. តើទំនាក់ទំនងរវាងក្រុមប្រឹក្សា និងគណៈអភិបាលមានឥទ្ធិពលយ៉ាងដូចម្តេចក្នុងដំណើរការរៀបចំ និងដាក់ចេញនៅគោលនយោបាយ ឬលិខិតបទដ្ឋានគតិយុត្តនៅរដ្ឋបាលថ្នាក់ក្រោមជាតិ?

## III. ហិរញ្ញវត្ថុ

១. តើធនធានហិរញ្ញវត្ថុមានសារសំខាន់យ៉ាងដូចម្ដេចខ្លះសម្រាប់គាំទ្រការរៀបចំផ្ដួចផ្ដើម ឬការដាក់ចេញនូវគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តសម្រាប់ការអភិវឌ្ឍនៅរដ្ឋបាលមូលដ្ឋាន?

២. តើឯកឧត្តម លោកជំទាវ លោក លោកស្រីយល់ឃើញថាហិរញ្ញវត្ថុប្រចាំឆ្នាំដែលបានវិភាជន៍ពីថ្នាក់ជាតិទៅរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់គ្រាន់ដែរឬទេសម្រាប់គាំទ្រការរៀបចំ និងដាក់ចេញនូវគោលនយោបាយ ឬលិខិតបទដ្ឋានគតិយុត្តសម្រាប់ការអភិវឌ្ឍនៅមូលដ្ឋាន?

៣. ក្រៅពីថវិកាប្រចាំឆ្នាំ តើរដ្ឋបាលរបស់ឯកឧត្តម លោកជំទាវមានប្រភពចំណូលផ្សេងៗដែរឬទេ? អ្វីខ្លះ? ប្រើប្រាស់ទៅលើការងារអ្វីខ្លះ?

៤. តើការវិភាជន៍ថវិកាបានគ្រប់គ្រាន់ ឬមិនទាន់គ្រប់គ្រាន់មានផលប៉ះពាល់យ៉ាងដូចម្ដេចដល់ដំណើរការផ្ដួចផ្ដើម និងការដាក់ចេញនូវគោលនយោបាយឬលិខិតបទដ្ឋានគតិយុត្តសម្រាប់ការអភិវឌ្ឍនៅមូលដ្ឋាន?

៥. តើឯកឧត្តម លោកជំទាវ លោក លោកស្រីអាចបញ្ជាក់អំពីសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាក្នុងការគ្រោង ឬប្រើប្រាស់ថវិការបស់រដ្ឋបាលខេត្ត ក្រុង ស្រុក ឃុំ សង្កាត់?

## IV. ការអភិវឌ្ឍន៍សមត្ថភាព

១. តើការអភិវឌ្ឍចំណេះដឹង និងជំនាញផ្ទាល់ខ្លួនមានឥទ្ធិពលយ៉ាងដូចម្ដេចចំពោះសមត្ថភាពផ្ដួចផ្ដើមរបស់ឯកឧត្តម លោកជំទាវ លោក លោកស្រីក្នុងការដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយ នៅមូលដ្ឋាន?

២. តើចំណេះដឹង និងជំនាញពាក់ព័ន្ធនឹងការរៀបចំគោលនយោបាយ មានឥទ្ធិពលយ៉ាងដូចម្ដេចចំពោះសមត្ថភាពផ្ដួចផ្ដើមរបស់ក្រុមប្រឹក្សាក្នុងការដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយនៅមូលដ្ឋាន?

៣. តើឯកឧត្តម លោកជំទាវ លោក លោកស្រីយល់ឃើញថាសមាជិកក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិមានសមត្ថភាពគ្រប់គ្រាន់ក្នុងការផ្ដួចផ្ដើមរៀបចំ និងការដាក់ចេញនូវលិខិតបទដ្ឋាន គតិយុត្ត ឬគោលនយោបាយហើយឬនៅ?

៤. តើគួរមានការគាំទ្របែបណាដើម្បីបង្កើន ឬពង្រឹងនូវសមត្ថភាពរបស់សមាជិកក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិ?

៥. តើការពង្រឹង ឬជំរុញការបណ្ដុះបណ្ដាលអភិវឌ្ឍន៍សមត្ថភាពរបស់សមាជិកក្រុមប្រឹក្សា និងជួយជំរុញការរៀបចំ និងដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយនៅមូលដ្ឋានឬទេ? ហេតុអ្វី?

V. **អនុសាសន៍ និងសំណូមពរ**

១. តើឯកឧត្តម លោកជំទាវ លោក លោកស្រី ត្រូវការការគាំទ្រ ឬមានតម្រូវការអ្វីផ្សេងទៀត ដើម្បីជំរុញការផ្តួចផ្តើមរៀបចំ និងដាក់ចេញគោលនយោបាយនៅរដ្ឋបាលរបស់ឯកឧត្តម លោកជំទាវ លោក លោកស្រី? សូមបញ្ជាក់។

2. តើឯកឧត្តម លោកជំទាវ លោក លោកស្រីមានជាអនុសាសន៍ និងសំណូមពរអ្វីខ្លះ ដើម្បីជំរុញការផ្តួចផ្តើមរៀបចំ និងដាក់ចេញគោលនយោបាយនៅរដ្ឋបាលរបស់ឯកឧត្តម លោកជំទាវ លោក លោកស្រី? សូមបញ្ជាក់។